វិទ្យាស្ថាន
បណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០០៧-០៨





ការបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

វិទ្យាស្ថាន
បណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០០៧-២០០៨

*Annual Development Review*
*2007 - 2008*

ភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០០៨

*ក្នុងលក្ខណៈជា វិទ្យាស្ថានឯករាជ្យមួយរបស់កម្ពុជាខាងការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ CDRI មានបេសកកម្មចូលរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយចិរភាព និងការលើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយ ចំណេះដឹង និងការកសាងសមត្ថភាព ។*

*CDRI ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការងារជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។*

© ២០០៨ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៧-២០០៨
*Annual Development Review 2007-08*
ភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០០៨

ការបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
☞ អាស័យដ្ឋាន ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤/៧០១, ៨៨៣-៦០៣, ៨៨១-៩១៦ / ០១២ ៨៦៧-២៧៨
🖷 (៨៥៥-២៣) ៨៨០ ៧៣៤
អ៊ីមែល: cdrimail@online.com.kh website: http://www.cdri.org.kh

កែសម្រួល និងរចនាដោយ: យូ-សិទ្ធីរិទ្ធ អ៊ុំ-ចាន់ថា យេន-សុផានី និង គីម-ចិត្រា
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ពជប៉ុន

# មាតិកា


បុព្វកថា ............................................................................................................ ៧

បញ្ជីអក្សរកាត់........................................................................................................ ៨

ជំពូក ១. សេចក្តីផ្តើម ................................................................................................... ៩

សេចក្តីបន្ថែម ១. ការចាកផុតភាពក្រីក្រ.................................................................. ១៣

សេចក្តីបន្ថែម ២. ការវាយតម្លៃភាពក្រីក្រដោយមានការចូលរួមនៅតំបន់បឹងទន្លេសាប...............២១

ជំពូក ២. ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចប្រទេសកម្ពុជា .................................................................២៥

ជំពូក ៣. ការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រក្នុងខេត្តតាកែវ៖ បញ្ហាចោទ ទំនាស់ និងដំណោះស្រាយ ....៣៣

ជំពូក ៤. កត្តាកំណត់ការចូលរួមក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ ........................ ៣៧

ជំពូក ៥. ការលូតលាស់ពីទីផ្សារដីធ្លីមិនផ្លូវការទៅជាផ្លូវការ៖ ដំណើរការកាន់កាប់ដីធ្លី
នៅប្រទេសកម្ពុជា .....................................................................................................៤៣

ជំពូក ៦. របាយការណ៍សង្ខេបអំពីស្ថាប័ន គោលនយោបាយ និងក្របខ័ណ្ឌច្បាប់
ស្តីពីការគ្រប់គ្រងទេសន្តប្រវេសពលករកម្ពុជា.................................................................... ៤៧

បញ្ជីឯកសារបោះពុម្ពផ្សាយរបស់ CDRI.................................................................... ៥៦

# បុព្វកថា

របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៧-០៨ របស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានចេញផ្សាយនាឱកាសបើក សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា លើកទី២ ដែលបានរៀបចំឡើងក្នុងកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និងធនាគារ អេអិនហ្សេតរ៉ូយ៉ាល់ នៅសណ្ឋាគារភ្នំពេញ នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៨ ។ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ក្រោមប្រធានបទរួម *ការកេណ្ឌប្រមូលធនធាននៅកម្ពុជា - ធនធានមនុស្ស ធម្មជាតិ ហិរញ្ញវត្ថុ - សំរាប់ការអភិវឌ្ឍ ការរីកលូតលាស់ និងវិបុលភាព* មានការអញ្ជើញចូលរួមពីសំណាក់ភ្ញៀវសំខាន់ៗ ដែលជាអ្នកដឹកនាំក្នុងស្ថាប័នរដ្ឋាភិបាល ក្រុមហ៊ុនឯកជន ស្ថាប័នស្រាវជ្រាវ អង្គការសង្គមស៊ីវិល សហគមន៍អភិវឌ្ឍន៍អន្តរជាតិនានា ដើម្បីពិភាក្សាពីសមិទ្ធិផល និងអនាគតរបស់ប្រទេសកម្ពុជា ។ សុន្ទរកថាគន្លឹះបើកសន្និសីទ ថ្លែងដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់នូវគោលគំនិតសំរាប់កិច្ចពិភាក្សាក្នុងសន្និសីទ។

របាយការណ៍ប្រចាំឆ្នាំលើកទី ៣ របស់វិទ្យាស្ថាន CDRI ស្តីពីបញ្ហាអភិវឌ្ឍន៍សំខាន់ៗនៅកម្ពុជា បានផ្តោតលើ ១) សកម្មភាពម៉ាក្រូសេដ្ឋកិច្ច ២) ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធស្រោចស្រព ជាកត្តាគន្លឹះនៃការអភិវឌ្ឍជនបទ និងកសិកម្ម ៣) កម្មសិទ្ធិដីធ្លី និងតួនាទីរបស់វា ក្នុងការគ្រប់គ្រងដីធ្លី និង ៤) ការរៀបចំគោលនយោបាយសំរាប់គ្រប់គ្រងកំណើនពលករចំណាកស្រុកឆ្លងកាត់ព្រំដែន ព្រមទាំងបញ្ហានានាដែលមានសារៈសំខាន់សំរាប់ការរីកលូតលាស់ ការអភិវឌ្ឍមានចីរភាព និងការកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា ។ របាយការណ៍ជាភាសាអង់គ្លេស ក៏បានចេញផ្សាយស្របគ្នានឹងឯកសារជាភាសាខ្មែរនេះដែរ ដើម្បីផ្តល់ព័ត៌មានបន្ថែមសំរាប់អ្នកអាន និងពង្រីកការផ្សព្វផ្សាយឱ្យធំទូលាយ ។

វិទ្យាស្ថាន CDRI យើងខ្ញុំសង្ឃឹមថា សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ដែលប្រារព្ធធ្វើជារៀងរាល់ឆ្នាំ ព្រមទាំងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំជាភាសាខ្មែរ និងអង់គ្លេស អាចចូលរួមចំណែកជួយផ្សព្វផ្សាយបានយ៉ាងច្រើននូវលទ្ធផលស្រាវជ្រាវខាងគោលនយោបាយអភិវឌ្ឍន៍ ដែលជាប់ទាក់ទិននឹងបញ្ហាសំខាន់ៗសំរាប់អនាគតប្រទេសកម្ពុជា និងធ្វើឱ្យលទ្ធផលទាំងនេះ កាន់តែមានប្រយោជន៍សំរាប់ការកសាងគោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍អន្តរជាតិ និងអ្នកពាក់ព័ន្ធថ្នាក់ជាតិទាំងអស់ ។

*ឡារី ស្ត្រេនួ*
*នាយកប្រតិបត្តិ CDRI*
*ភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០០៨*

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADI | គំរោងវិភាគបញ្ហាអភិវឌ្ឍន៍ (Analysing Development Issues) |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (Council for the Development of Cambodia) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CPR | ធនធានទ្រព្យរួម (Common Property Resource) |
| FWUC | សហគមន៍កសិករប្រើប្រាស់ទឹក (Farmer Water User Community) |
| FWUCC | គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក (FWUC Committees) |
| LMAP | គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (Land Management and Administration Project) |
| MFA | កិច្ចព្រមព្រៀងវាយនភ័ណ្ឌចំរុះ (Multi-Fibre Agreement) |
| MFIs | ស្ថាប័នមីក្រូហិរញ្ញវត្ថុ (Micro-Finance Institutes) |
| MOPS | ការសិក្សាពីការចាកផុតភាពក្រីក្រ (Moving Out of Poverty Study) |
| NGO | អង្គការមិនមែនរដ្ឋាភិបាល (Non-Government Organisation) |
| NIS | វិទ្យាស្ថានជាតិស្ថិតិ (National Institute of Statistics) |
| O&M | ប្រតិបត្តិការ និង ការថែទាំជួសជុល (Operation and Maintenance) |
| PPA | ការវាយតំលៃភាពក្រីក្រដោយមានការចូលរួម (Participatory Poverty Assessment) |

# ជំពូក ១
# សេចក្ដីផ្ដើម

ទោះបីក្នុងមួយទសវត្សរ៍កន្លងមក សេដ្ឋកិច្ចជាតិមានអត្រាកំណើនខ្ពស់ក្ដី ក៏ប្រទេសកម្ពុជានៅតែមានអត្រាក្រីក្រកំរិតខ្ពស់ ។លើសពីនេះវិសមភាពបានកើនឡើងហើយវាជារឿងសំខាន់ណាស់ដែលត្រូវស្វែងយល់ពីហេតុផលនៃកំនើននេះ ។

ការកាត់បន្ថយភាពក្រីក្រមានសារៈសំខាន់ទាំងសំរាប់រដ្ឋាភិបាល អ្នកផ្ដល់ជំនួយនិងសង្គមស៊ីវិល ។ការស្រាវជ្រាវ និងការផ្ដល់មតិខាងគោលនយោបាយ លើបញ្ហាភាពក្រីក្រ និងសុខមាលភាព គឺជាសកម្មភាពស្នូលរបស់ CDRI ។ នៅក្នុងសេចក្ដីប្រកាសបេសកកម្មរបស់ខ្លួន CDRI បានសង្កត់ធ្ងន់លើការរីកចំរើន ការធ្វើចំរុះកម្មសេដ្ឋកិច្ច និងការអភិវឌ្ឍកសិកម្ម ថាជាវិធីដោះស្រាយបញ្ហាដែលកម្ពុជាកំពុងប្រឈមមុខ ។

ក្នុងឆ្នាំកន្លងទៅ CDRI បានបោះពុម្ពរបាយការណ៍សំខាន់ពីរស្ដីអំពីភាពក្រីក្រ និងវិសមភាព ។ ការសិក្សាទាំងនេះបានរកឃើញភស្ដុតាងជាច្រើនដែលថា ការរីកចំរើនសេដ្ឋកិច្ចនៅកម្ពុជានាពេលថ្មីៗ មិនបានផ្ដល់ឱ្យប្រជាជនក្រីក្រនូវផលប្រយោជន៍ច្រើន ដូចក្រុមឯទៀតដែលរកប្រាក់ចំណូលបានច្រើនជាងនោះទេ ហើយការសិក្សាក៏បានផ្ដល់ទិន្នន័យស្ថិតិអំពីកំណើនវិសមភាពនៃប្រាក់ចំណូលនេះដែរ ។ ម្យ៉ាងទៀតក៏មានកំណើនវិសមភាពក្នុងការកាន់កាប់ដីដែលអាចមានផលប៉ះពាល់ច្រើនណាស់ ដល់សេដ្ឋកិច្ចនយោបាយ និងការអភិវឌ្ឍប្រទេស ។ ប្រជាជនក្រីក្រមានការចាញ់ប្រៀបលើចំណុចជាច្រើន:

- កត្តាផ្ទាល់ខ្លួន ដូចជា ជំនាញទាប កំរិតអក្ខរកម្មអន់ គ្រួសារមានសមាជិកច្រើន កង្វះទ្រព្យធន ហើយអាចមានកត្តាខាងជនជាតិ និងយេនឌ័រទៀតផង ។
- កត្តាទីតាំង ដូចជា លទ្ធភាពតិចក្នុងការបានប្រើប្រាស់ហេដ្ឋាចនាសម្ព័ន្ធរូបវន្ត និងសង្គមកិច្ច ដែលមានផ្លូវថ្នល់ ការផ្គត់ផ្គង់សាធារណៈ ការថែទាំសុខភាព និងការអប់រំជាដើម ។
- កត្តារចនាសម្ព័ន្ធ ដូចជា ទំនាក់ទំនងទីផ្សារមិនសូវមានការរីកចំរើន ទាំងខាងផ្នែកព័ត៌មាន ហិរញ្ញវត្ថុ និងលទ្ធភាពទទួលបានឥណទាន ។

ការចាញ់ប្រៀបទាំងអស់នេះ អាចធ្ងន់ធ្ងរខ្លាំងរហូតធ្វើឱ្យប្រជាជនក្រីក្រធ្លាក់ចូលក្នុងភាពក្រីក្រតោកយ៉ាកបំផុតហើយគ្មានលទ្ធភាពទ្រទ្រង់ជីវភាពបាន ។ វាក៏អាចក្លាយជាអន្ទាក់គ្មានច្រកចេញ ដោយកូនដែលកើតមកក្នុងគ្រួសារក្រីក្រគឺ ត្រូវតែក្លាយជាអ្នកក្រនៅពេលពេញវ័យ ។ អន្តរាគមន៍ពីខាងក្រៅប្រហែលជាចាំបាច់បំផុត ដើម្បីបំបែកអន្ទាក់ទាល់ច្រកនេះ ។ ម្យ៉ាងទៀតកំរិតស្ដង់ដារជីវភាពជាទូទៅនៅកម្ពុជា មិនទាន់ខ្ពស់គ្រប់គ្រាន់ដើម្បីលើកស្ទួយប្រជាជនក្រីក្រទាំងអស់បានទេ ។ សកម្មភាពសេដ្ឋកិច្ចត្រូវតែបង្កើនឡើង ដើម្បីបង្កើតធនធានសំរាប់កាត់បន្ថយភាពក្រីក្រ ។ ជំនួយពីខាងក្រៅគឺត្រូវការជាចាំបាច់សំរាប់ការងារនេះ ។

កត្តាកំណត់សំខាន់ៗសំរាប់ការរីកចំរើន រួមមាន ការវិនិយោគលើមូលធនរូបវន្ត និងមូលធនមនុស្ស ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងហេដ្ឋារចនាសម្ព័ន្ធសង្គមកិច្ច ការអភិវឌ្ឍនិងអភិបាលកិច្ចល្អនូវទីផ្សារហិរញ្ញវត្ថុនិងក្របខ័ណ្ឌស្ថាប័ន ។ កំណើនសកម្មភាពសេដ្ឋកិច្ច វាបង្កើនតំរូវការកំលាំងពលកម្ម និងអាចផ្ដល់អត្ថប្រយោជន៍

ជាប្រយោលដល់ប្រជាជនក្រីក្រ តាមរយៈការបានប្រើប្រាស់ធនធានទាំងនេះ ។ កំណែលំអអភិបាលកិច្ច នឹងជួយដល់សេដ្ឋកិច្ច ក៏ដូចជាប្រជាជនក្រីក្រ ។

ប្រទេសកំពុងអភិវឌ្ឍ ឥឡូវនេះត្រូវធ្វើប្រតិបត្តិការនៅក្នុងបរិស្ថានទីផ្សារតំបន់ និងទីផ្សារសាកល ។ ប្លុកពាណិជ្ជកម្មតាមតំបន់នឹងមានផលប៉ះពាល់ច្រើនណាស់ លើការរីកចំរើនរបស់ប្រទេសកម្ពុជា ហើយគោលនយោបាយបើកចំហពាណិជ្ជកម្មរបស់កម្ពុជាក៏សំខាន់ដូចគ្នាដែរ ។ ប៉ុន្តែផលប៉ះពាល់អាចក្លាយជាអវិជ្ជមាន បើសិនប្រទេសកម្ពុជាមិនកែលំអសមត្ថភាពប្រកួតប្រជែងរបស់ខ្លួនទេ ។

ការរីកចំរើនសេដ្ឋកិច្ចអាចកាត់បន្ថយភាពក្រីក្របានប៉ុណ្ណា វាអាស្រ័យលើប្រភេទនៃការរីកចំរើន ។ បើសិនការរីកចំរើន វា "រាប់បញ្ចូល (inclusive)" ដោយផ្តល់អត្ថប្រយោជន៍ឱ្យគ្រប់ៗគ្នា ដូច្នេះវានឹងជួយកាត់បន្ថយភាពក្រីក្រ ។ បើមិនដូច្នេះទេ ការរីកចំរើនអាចបង្កើនវិសមភាពដែលអាចធ្វើឱ្យខូចខាតដល់សក្តានុពលសំរាប់ធ្វើការអភិវឌ្ឍរយៈពេលវែង ហើយការរីកចំរើនអាចមានលក្ខណៈរាប់បញ្ចូល រឺអត់ វាជាប់ទាក់ទងជាសំខាន់ទៅនឹងរចនាសម្ព័ន្ធស្ថាប័ន និងរចនាសម្ព័ន្ធអភិបាលកិច្ចរបស់ប្រទេស ។

ការចាញ់ប្រៀបរបស់ប្រជាជនក្រីក្រ ដូចជា ការចាញ់ប្រៀបខាងជនជាតិ និងយេនឌ័រ ទីតាំងមិនល្អ និងកត្តារចនាសម្ព័ន្ធ អាចត្រូវមានគោលនយោបាយកំរិតម៉ាក្រូសំរាប់កាត់បន្ថយភាពក្រីក្រ ដោយគួបផ្សំជាមួយនឹងការផ្តោតកាន់តែខ្លាំងឡើងទៅលើក្រុមនានាដែលក្រីក្រជាងគេ ។

ដើម្បីបកស្រាយពីកំហិតមួយចំនួនចំពោះភាពរីកចំរើន និងការកាត់បន្ថយភាពក្រីក្រ គួរប្រៀបធៀបប្រទេសកម្ពុជាជាមួយនឹងប្លុកតំបន់មួយចំនួន និងជាមួយប្រទេសចិន ។ ក្នុងទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាបានរីកចំរើនលឿនបើធៀបនឹងអាស៊ីខាងកើតនិងប្រទេសចិន ។ប៉ុន្តែអត្រាកាត់បន្ថយភាពក្រីក្ររបស់កម្ពុជានៅទាបជាងអាស៊ីខាងកើត និងប្រទេសចិន គឺបានត្រឹមស្មើនឹងតំបន់ខាងត្បូងវាលខ្សាច់សាហារ៉ានៅអាហ្វ្រិក និងតំបន់អាស៊ីខាងត្បូង ។

កំរិតដែលភាពរីកចំរើន "វាហូរចុះដល់" ប្រជាជនក្រីក្រប៉ុណ្ណា គឺអាស្រ័យទៅលើលក្ខណៈផ្ទាល់នៃភាពរីកចំរើនសមាសភាពតាមវិស័យនៃភាពរីកចំរើន និងចំណងទាក់ទងរវាងវិស័យផ្សេងៗនៃសេដ្ឋកិច្ច។ ការសិក្សាមួយចំនួនបានស្នើថា ការរីកចំរើនផ្តល់អត្ថប្រយោជន៍ដល់ទាំងក្រុមប្រជាជនក្រីក្រ និងក្រុមប្រជាជនមិនក្រីក្រ ។ ប៉ុន្តែរូបភាពជាទូទៅនេះ អាចមិនត្រឹមត្រូវសំរាប់ប្រទេសមួយចំនួនឡើយ ។ នៅកម្ពុជាប្រជាជនក្រីក្រប្រហែលទទួលផលប្រយោជន៍ពីភាពរីកចំរើននៅទសវត្សរ៍ចុងក្រោយនេះ មិនបានច្រើនដូច ប្រជាជនមិនក្រីក្រទេ ហើយរឿងនេះបណ្តាលពីសមាសភាពតាមវិស័យនៃការរីកចំរើន ។

វិស័យនានានៃសេដ្ឋកិច្ចកម្ពុជា ដែលមានការរីកចំរើនជាប់រហូតក្នុងមួយទសវត្សរ៍ចុងក្រោយគឺ វិស័យឧស្សាហកម្ម (កាត់ដេរ និងសំណង់ជាចំបង) និង វិស័យសេវាកម្ម (ទេសចរណ៍ជាចំបង) ។វិស័យដែលរីកចំរើនទាំងនេះបានជះឥទ្ធិពលស្ទើរទាំងអស់ដល់សេដ្ឋកិច្ចជាទូទៅ តែតាមរយៈការបង្កើតការងារ ។ អត្រារីកលូតលាស់កសិកម្មជួនលឿន ជួនយឺត ហើយជួនកាលអវិជ្ជមានទៀតផង ។ ដោយសារប្រជាជនភាគច្រើន រស់នៅក្នុងតំបន់ជនបទ ហើយចំណងទាក់ទងរឹងមាំរវាងវិស័យកសិកម្ម នឹងវិស័យមានកំណើនខ្លាំងៗនៃសេដ្ឋកិច្ចក៏គ្មានដែរ ដូច្នេះប្រជាជនក្រីក្រនៅជនបទមានឱកាសតិចតួចណាស់ ដើម្បីបានទទួលចំណែកពីផលប្រយោជន៍នៃភាពរីកចំរើន ។ ឧទាហរណ៍ ការសិក្សានាពេលថ្មីៗរបស់ CDRI ស្តីពីឥទ្ធិពលនៃទេសចរណ៍ទៅលើការកាត់បន្ថយភាពក្រីក្រ បានរកឃើញថា ទេសចរណ៍មិនបានដើរតួអ្វីសំខាន់ទេក្នុងរឿងនេះ ។

ការពិភាក្សាលំអិតពីវិធីញ៉ាំងអោយការរីកចំរើននៅប្រទេសកម្ពុជា កាន់តែមានលក្ខណៈ "រាប់បញ្ចូល" នឹងត្រូវធ្វើនៅពេលក្រោយទៀត ប៉ុន្តែអត្ថបទនេះអាចផ្តល់នូវកំណត់សំគាល់មួយចំនួន ។ វិស័យឯកជន ត្រូវដើរតួនាទីធំជាងនេះ ជាពិសេសក្នុងឧស្សាហកម្ម ប៉ុន្តែចំណាយធ្វើអាជីវកម្មនៅកម្ពុជា មានកំរិតខ្ពស់ បើធៀបនឹងប្រទេសមួយចំនួនក្នុងតំបន់ ដោយសារហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ បញ្ហាផ្សេងៗខាងថាមពល ការិយាធិបតេយ្យ ការទារកំរៃក្រៅផ្លូវការ និងអំពើពុករលួយ ។

អត្រាសន្សំប្រាក់និងវិនិយោគនៅកម្ពុជា មានកំរិតខ្ពស់ក៏ពិតមែនប៉ុន្តែវិនិយោគភាគច្រើនអាចមិនបានជំរុញខ្លាំងដល់ការអភិវឌ្ឍនោះទេ ។ វិនិយោគលើគ្រឿងម៉ាស៊ីន និងការដឹកជញ្ជូន អាចជួយជំរុញការរីកចំរើន បានច្រើនជាងវិនិយោគលើសំណង់អគារដែលកំពុងមានកំរិតខ្ពស់ណាស់នៅកម្ពុជា រឺក៏វិនិយោគទិញដីសំរាប់លក់កេញយកចំណេញ ។

ជាការសំខាន់ណាស់ដែលត្រូវកែលំអកំណើននិងផលិតភាពកសិកម្មឱ្យបានច្រើនថែមទៀត ។ដើម្បីពង្រឹងពង្រីកកសិកម្ម ការចុះបញ្ជីដីធ្លីត្រូវពន្លឿនថែមទៀត ហើយវិសមភាពនៃការកាន់កាប់ដីធ្លីត្រូវតែដោះស្រាយ ។ បើសិនប្រជាជនមួយភាគធំមានកម្មសិទ្ធិលើដីធ្លី ពួកគេនឹងមានទឹកចិត្តកែលំអផលិតភាពដី ។ សិទ្ធិកាន់កាប់ដីធ្លីដែលច្បាស់លាស់ និងកំណត់យ៉ាងត្រឹមត្រូវ វាលើកទឹកចិត្តកសិករឱ្យកែលំអដីធ្លី និងប្រើប្រាស់ដី កាន់តែមានប្រសិទ្ធភាព ។ កត្តាលើកទឹកចិត្តឯទៀតមានដូចជា ការកសាងប្រព័ន្ធធារាសាស្ត្រ ការបណ្តុះបណ្តាលពីការប្រើប្រាស់គ្រាប់ពូជ បច្ចេកទេសប្រើប្រាស់ដីទំនើបជាងមុន លទ្ធភាពទទួលបានហិរញ្ញវត្ថុ សាលារៀន និងមណ្ឌលសុខភាព ។

នៅកម្ពុជា ស្ថាប័នផ្សេងៗ (ដូចជា ការចុះបញ្ជីដីធ្លី) ដែលជួយពង្រឹងសិទ្ធិកាន់កាប់ដី ជាទូទៅនៅទន់ខ្សោយ ដូច្នេះត្រូវយកចិត្តទុកដាក់ជាអាទិភាពធ្វើយ៉ាងណាឱ្យសំរេចបានកំណើនដ៏ត្រឹមត្រូវ ។

អ្នកផ្តល់ជំនួយអន្តរជាតិអាចសង្កត់ធ្ងន់ខ្លាំងពេកលើរបបប្រជាធិបតេយ្យ និងវិធានការប្រឆាំងអំពើពុករលួយថាជាបុរេលក្ខខណ្ឌសំរាប់ការអភិវឌ្ឍ ពីព្រោះមានប្រទេសជាច្រើនក្នុងតំបន់បានអះអាងថា គេសំរេចបានជោគជ័យ ដោយសារមានរដ្ឋាភិបាលខ្លាំង និងផ្តាច់ការ ដែលភាគច្រើនជួយគាំទ្រដល់វិស័យឯកជនតាមខ្សែរយៈទំនាក់ទំនងផ្សេងៗដែលពុំមានតម្លាភាព ។ សំរាប់ប្រទេសភាគច្រើនដែលមានការអភិវឌ្ឍលឿន រដ្ឋាភិបាលបានដើរតួនាទីគន្លឹះ ។ ក្នុងនេះអ្វីដែលសំខាន់គឺ កត្តានានាដែលនាំមកនូវការរីកចំរើន ការអភិវឌ្ឍ និងទំនាក់ទំនងរវាងស្ថាប័ននានាជាមួយនឹងការអភិវឌ្ឍ ។

អ្នកផ្តល់ជំនួយអាចដើរតួនាទីដ៏សំខាន់ជំរុញឱ្យកម្ពុជាមានការរីកចំរើនប្រកបដោយចីរភាព ។ដោយសារធនធានសំរាប់អនុវត្តគំរោងហេដ្ឋារចនាសម្ព័ន្ធធំៗវាមានកំរិត ដូច្នេះអ្នកផ្តល់ជំនួយអាចគាំទ្រដល់វិនិយោគក្នុងវិស័យទាំងនេះ ជាពិសេសផ្លូវថ្នល់ ថាមពល និងហេដ្ឋារចនាសម្ព័ន្ធខាងបច្ចេកវិទ្យាព័ត៌មាន ។

ឯកសារសង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំនេះ បែងចែកជា ៥ជំពូកធំៗ ហើយជំពូកនីមួយៗពិនិត្យពីប្រធានបទដោយឡែកៗពីគ្នា ។

ជំពូក ២ ពិភាក្សាពីលទ្ធផលម៉ាក្រូសេដ្ឋកិច្ចកម្ពុជា រួមទាំង ចំណងទាក់ទងរវាងវិស័យដែលរីកចំរើនទៅនឹងវិស័យឯទៀតៗក្នុងសេដ្ឋកិច្ច ការផ្លាស់ប្តូរដែលទំនងកើតឡើងក្នុងបរិយាកាសជំនួញ ប្រភពដ៏ចង្អៀតនៃកំណើន និងតំរូវការវិនិយោគក្នុងស្រុកច្រើនថែមទៀត ជាពិសេសលើសហគ្រាសធុនតូច និងមធ្យម ។

ជំពូក ៣ សិក្សាពីប្រព័ន្ធធារាសាស្ត្រ និងការប្រើប្រាស់ទឹក ដោយផ្អែកលើ ករណីសិក្សានៅខេត្តតាកែវ ដែលបង្ហាញពីបញ្ហារចនារៀបចំបច្ចេកទេសអន់ និងកង្វះការថែទាំសមស្របលើប្រព័ន្ធធារាសាស្ត្រ ។

ជំពូក ៤ ពិនិត្យពីប្រព័ន្ធធារាសាស្ត្រក្នុងចំណុចការចូលរួមក្នុងការអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធ ហើយសន្និដ្ឋានថា ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់ទឹកពីប្រព័ន្ធធារាសាស្ត្រ គឺជំរុញឡើងមួយភាគធំដោយហេតុផលខាងសេដ្ឋកិច្ច តែរាំងស្ទះដោយកង្វះធនធាន សំភារៈបរិក្ខារ ហិរញ្ញវត្ថុ និងជូនកាលកំលាំងពលកម្ម ។

ជំពូក ៥ វិភាគពីការទិញលក់ដីធ្លី ទាំងផ្លូវការ និងមិនផ្លូវការ ព្រមទាំងបញ្ហាជាទូទៅនៃការកាន់កាប់ដីធ្លី ហើយពិនិត្យ ពីផលប៉ះពាល់ដែលអាចទទួលបានពីការចុះបញ្ជីដីធ្លី ។

ជំពូក ៦ ពិនិត្យពីការគ្រប់គ្រងចំណាកស្រុកឆ្លងកាត់ព្រំដែន ជាពិសេស ចំណាកស្រុកពលករកម្ពុជាទៅប្រទេសថៃ ដែលភាគច្រើនឆ្លងដែនតាមមធ្យោបាយខុសច្បាប់ ទោះបីរដ្ឋាភិបាលប្រទេសទាំងពីរបានខិតខំគ្រប់គ្រងលើដំណើរការនេះក្តី ។

# សេចក្តីបន្ថែម ១
# ការចាកផុតភាពក្រីក្រ

## សេចក្តីសង្ខេប

ការសិក្សាពីការចាកផុតភាពក្រីក្រ (The Moving Out of Poverty Study: MOPs) គឺជាការសិក្សាលើប្រធានបទនេះលើកទី១ នៅប្រទេសកម្ពុជា និងជាការសិក្សាមួយក្នុងចំណោមការសិក្សាទាំង ១៨ ដែលធនាគារពិភពលោកបានចុះកិច្ចសន្យាប្រគល់ឱ្យធ្វើ ដើម្បីពិនិត្យពីនិន្នាការ និងឌីណាមិកនៃភាពក្រីក្រ ។ ការសិក្សានេះធ្វើឡើងក្នុងឆ្នាំ២០០៤/០៥ នៅតាមភូមិចំនួន ៩ ដែល CDRI បានចុះស្រាវជ្រាវម្តងរួចមកហើយ កាលពីឆ្នាំ២០០១ ដោយប្រើវិធីសាស្ត្របែបគុណភាព និងបរិមាណ ដើម្បីតាមដានពីកិរិតដែលភូមិទាំងនេះ ក៏ដូចជាគ្រួសារនីមួយៗអាចចាកផុតពីភាពក្រីក្រ និងបានធូរធារឡើង រឺក៏បានចុះក្រីក្រថែមទៀត ។

ការសិក្សាមានគោលដៅពិនិត្យថាតើសហគមន៏រឺក្រុមណាមួយបានចាកផុតពីភាពក្រីក្រនិងតើសហគមន៏រឺក្រុមណាមួយនៅតែជាប់ផុងក្នុងភាពក្រីក្រ ហើយហេតុអ្វី? តើប្រជាជនមានការវិវត្តខុសគ្នានៅក្នុងស្ថានភាពសេដ្ឋកិច្ចខុសៗគ្នារឺយ៉ាងណា? តើអភិបាលកិច្ច និងបណ្តាញសង្គមកិច្ចវាសំខាន់ប៉ុណ្ណាក្នុងការវិវត្តឡើងរបស់ប្រជាជន ហើយហេតុអ្វី? តើកត្តាអ្វីខ្លះ ជួយឱ្យសហគមន៏ និងគ្រួសាររីកចំរើននិងវិវត្តឡើង រឺក៏ចុះក្រនិងជាប់ផុង? តើមានអន្តរកម្មអ្វីខ្លះរវាងកត្តាសហគមន៏ និងគ្រួសារ រឺក៏មានការប្រែប្រួលខុសគ្នាអ្វីដែររវាងភូមិនានា និងគ្រួសារប្រភេទខុសៗគ្នា?

ការសិក្សាប្រើវិធីសាស្ត្រតាមបណ្តោយពេល (longitudinal) ដោយចុះសិក្សាលើគ្រួសារដែលធ្លាប់បញ្ចូលក្នុងការសិក្សាឆ្នាំ២០០១ រួចហើយ (ប្រើវិធីអង្កេតជាក្រុម) និងការសិក្សាពីបរិបទដោយធ្វើការស្រាវជ្រាវពីប្រវត្តិ ភូមិសាស្ត្រ និងនិន្នាការប្រែប្រួល ព្រមទាំងស្រាវជ្រាវពីឥទ្ធិពលនៃកត្តាទាំងនេះទៅលើសហគមន៏និងគ្រួសារ ព្រមទាំងប្រើវិធីសាស្ត្រចំរុះ ដែលមានទាំងការអង្កេតគ្រួសារជាក្រុម និងការពិភាក្សាស៊ីជំរៅនៃក្រុមគោលដៅ និងបទសំភាសន៏ពាក់កណ្តាលរៀបរយ ។ ភូមិទាំង ៩ ដែលបានជ្រើសរើសសំរាប់ការសិក្សាដំបូងនៅឆ្នាំ២០០១ តំណាងអោយតំបន់កសិ-អេកូឡូស៊ីជនបទ សំខាន់ៗចំនួន ៤ នៅកម្ពុជា ដូចជា វាលទំនាបទន្លេសាប វាលទំនាបទន្លេមេគង្គ តំបន់ភ្នំ/ខ្ពង់រាប និងតំបន់ឆ្នេរ ។ ក្រុម ៨៩០គ្រួសារ ដែលស្រង់យកពីភូមិសិក្សាទាំង ៩ តំណាងអោយកំរងទិន្នន័យសំខាន់មួយ ហើយអាចបង្កើតនូវការអះអាងអំពីនិន្នាការសរុប និងនិន្នាការតាមភូមិ ដែលមានតំលៃគ្រប់គ្រាន់ខាងស្ថិតិ ។ អង្កេតជាក្រុម ត្រូវបានបំពេញបន្ថែមដោយ ទិន្នន័យគុណភាពបានមកពីបទសំភាសន៏ និងក្រុមគោលដៅ ដែលមានអ្នកចូលរួម ៤៧៧នាក់ មកពីភូមិទាំង ៩ ដូចជា អ្នកដឹកនាំផ្លូវការនិងមិនផ្លូវការក្នុងភូមិ ក្រុមចលនា (គឺមានអ្នកចូលរួមដែលចាកផុត រឺមិនចាកផុតពីភាពក្រីក្រ រឺក្រុមមានស្ថានភាពនៅដដែល) និង បុរស-នារីវ័យក្មេង ។

ក្របខ័ណ្ឌសំរាប់ការវិភាគ រួមមាន ការពិនិត្យពីការផ្លាស់ប្តូរ និងនិន្នាការសំខាន់ៗដែលជះឥទ្ធិពលលើភូមិសិក្សាដូចជា បំរែបំរួលក្នុង ការប្រើប្រាស់ប្រាក់ចំណូល និងអត្រាក្រីក្ររបស់ភូមិ ព្រមទាំងការវិភាគពីកត្តាជួយជំរុញ រឺរារាំងការរីកចំរើន/ការអភិវឌ្ឍសហគមន៏ និងចលនាគ្រួសារធ្លាក់ចូលរឺចាកផុតពីភាពក្រីក្រ ។ ការវិភាគអនុវត្តលើកត្តាសហគមន៏ ដូចជា ស្ថានភាពនៅមូលដ្ឋាន និងបរិបទអភិវឌ្ឍន៏និងអភិបាលកិច្ច ដែលកំណត់ពីការវិវត្តតាមភូមិ

នីមួយៗ និងអនុវត្តលើកត្តាគ្រួសារ ដូចជា យុទ្ធសាស្ត្រសំរាប់ការបង្កើតប្រាក់ចំណូល និងភាពងាយទទួលរងគ្រោះដ៏ជាក់លាក់របស់គ្រួសារនីមួយៗ ។ កត្តាភូមិ និងកត្តាគ្រួសារ ដែលនាំឱ្យមានចលនាចាកផុតពីភាពក្រីក្រ រឺកាន់តែក្រីក្ររឺនៅដដែល ត្រូវបានស្រាវជ្រាវយ៉ាងលំអិតក៏ពិតមែន ប៉ុន្តែបទពិសោធន៏តាមបុគ្គល ដូចជា ឥទ្ធិពលខាងយេនឌ័រទៅលើភាពក្រីក្រ និងចលនាឈានឡើង មិនត្រូវបានស្រាវជ្រាវស៊ីជំរៅទេ ។ ដោយឱណាមិកក្នុងរង្វង់គ្រួសារកំពុងមានការយកចិត្តទុកដាក់ច្រើនឡើង ក្នុងការស្រាវជ្រាវពីភាពក្រីក្រ (Fuwa et al. 2000) ដូច្នេះវាជាប្រធានបទដ៏ល្អមួយសំរាប់ធ្វើអង្កេតក្នុងការសិក្សាលើកក្រោយអំពីការចាកផុតពីភាពក្រីក្រ ។

## ការសិក្សាកំណត់ឃើញពីនិន្នាការខាងសុខមាលភាព និងការរីកចំរើន ព្រមទាំងកត្តាជំរុញ រឺរាំងការរីកចំរើនក្នុងភូមិ និងចលនាឈានឡើងរបស់គ្រួសារ

និន្នាការខាងសុខមាលភាពប្រែប្រួលខុសគ្នាគួរអោយកត់សំគាល់រវាងភូមិ និងគ្រួសារនានា ។ គិតជាតួលេខសរុប ប្រាក់ចំណូល និងចំណាយលើការប្រើប្រាស់កើនឡើង ហើយភាពក្រីក្រថយចុះបន្តិច ដែលតំណាងអោយភាពប្រសើរឡើងនៃសុខមាលភាពជារួម ។ ប្រាក់ចំណូលកើនឡើងនៅគ្រប់ភូមិសិក្សា រីឯចំណាយលើការប្រើប្រាស់ថយចុះក្នុង ៣ ភូមិ និងកើនឡើងក្នុង ៦ភូមិទៀត ។ ចំនួនគ្រួសារក្រីក្រ ធ្លាក់ចុះក្នុង ៦ភូមិ និងកើនឡើងក្នុង ៣ភូមិដែលមានការថយចុះចំណាយលើការប្រើប្រាស់ ។ ក្នុងឆ្នាំ២០០៤/០៥ សូម្បីតែក្នុងភូមិដែលមានប្រាក់ចំណូល និងចំណាយលើការប្រើប្រាស់កើនឡើង និងភាពក្រីក្រថយចុះក្តី ក៏ភាពក្រីក្រនៅតែមានកំរិតខ្ពស់ និងលើសពីតួលេខមធ្យមសំរាប់ខេត្តទាំងមូលលើកលែងតែភូមិមួយប៉ុណ្ណោះ ។ ក្នុងឆ្នាំ២០០៤/០៥ ភូមិចំនួន ៤ មានចំណាយលើការប្រើប្រាស់ទាបជាខ្លាំងជាងខ្សែបន្ទាត់ក្រីក្ររបស់ភូមិ ។ សំរាប់ការងារវិភាគ ភូមិនានាបានយកមកផ្គុំគ្នាជាបីកញ្ចុំៈ ភូមិដំណើរការខ្លាំង ដែលមានប្រាក់ចំណូលនិងចំណាយលើការប្រើប្រាស់កើនឡើង និងអត្រាភាពក្រីក្រថយចុះ, ភូមិដំណើរការបង្គួរ ដែលមានកំណើនប្រាក់ចំណូលនិង/រឺកំណើនចំណាយលើការប្រើប្រាស់រឺការកាត់បន្ថយភាពក្រីក្រ, ហើយនិងភូមិដំណើរការខ្សោយដែលពុំអាចសំរេចបានកំនើនប្រាក់ចំនូល រឺកំនើនចំនាយលើការប្រើប្រាស់គួរឱ្យកត់សំគាល់ រឺការកាត់បន្ថយភាពក្រីក្រ ។

ក្នុងអំឡុងឆ្នាំ២០០១ និង ២០០៤/០៥ គ្រួសារជាង ៥០% គ្មានការផ្លាស់ប្តូរស្ថានភាពទេ គឺនៅតែក្រីក្រខ្លាំង ក្រីក្របង្គួរ និងធូធារ ។ ក្នុងចំណោម ៤៨% ដែលនៅសល់ គឺមាន ២៦% មានជីវភាពប្រសើរឡើង និង ២២% កាន់តែចុះក្រ ដូច្នេះសរុបមកគឺមានចលនាឈានឡើងសុទ្ធ ៤% ក្នុងអំឡុង ៣,៥ឆ្នាំ ដែលជាចន្លោះពេលរវាងអង្កេតទាំងពីរ ។ ក្នុងចំណោមគ្រួសារគ្មានចលនា មាន ២៤% នៃគំរូតាងសរុប នៅតែធូធារ ១៤% នៅតែក្រីក្របង្គួរ និង ១៤% នៅតែជាប់ផុងក្នុងភាពក្រីក្រ (ក្ររហូត) ។ ក្នុងចំណោមគ្រួសារមានចលនា មានគ្រួសារ ១៤% (នៃគំរូតាងទាំងមូល) ដែលកាលពីមុនក្រីក្រខ្លាំងហើយបានឈានឡើងជាក្រីក្របង្គួរ រឺធូធារ (ចាកផុតភាពក្រីក្រ)នៅឆ្នាំ២០០៤/០៥, គ្រួសារ ៧% ដែលពីមុនក្រីក្របង្គួរហើយក្លាយជាក្រីក្រខ្លាំង (ចុះក្រ) និង ១២% ក្លាយជាអ្នកធូរធារ ។ ម្យ៉ាងទៀតមានគ្រួសារ ១៥% ដែលកាលពីមុនជាអ្នកធូរធារ ហើយក្លាយជាក្រីក្របង្គួរ រឺក្រីក្រខ្លាំង (ចុះក្រ) ។ គ្រួសារមានចលនាទាំង ៧ក្រុម (ធូរធាររហូត ឡើងជាធូធារ ចាកផុតពីភាពក្រីក្រ ផ្ទាក់កណ្តាលគ្មានចលនា ធ្លាក់ក្នុងភាពក្រីក្រ កាន់តែក្រីក្រថែម និង ក្រីក្ររហូត) ហើយភូមិទាំង ៣កញ្ចុំ គឺជាកម្មវត្ថុចំបងនៃការវិភាគក្នុងការសិក្សានេះ ។

បើគិតតាមការវាស់វែងផ្សេងៗទៀតក្រៅពីចំណាយប្រើប្រាស់ ជាអាទិ៍ ប្រាក់ចំណូល ទ្រព្យធន និងការវាស់វែងខាងនយោបាយ-សង្គមកិច្ច (ដូចជា ការមានបណ្តាញប្រើប្រាស់ធនធាន និងការសំរេចចិត្ត) វិសមភាពបានកើនឡើង

ពីឆ្នាំ២០០១ ដល់ ២០០៤/០៥ ។ ខណៈដែលវិសមភាពចំណាយប្រើប្រាស់នៅថេរ និងវិសមភាពកាន់កាប់ដីធ្លីវាថយចុះ វិសមភាពប្រាក់ចំណូលវាកើនឡើង ហើយអនុបាតរវាង តំលៃទ្រព្យកាន់កាប់ដោយ អ្នកធូរធាររហូត និងអ្នកក្រីក្ររហូត ក៏កើនឡើងដែរ ។ គ្រួសារក្រីក្រកាន់តែក្រដាច់ឆ្ងាយពីគេខ្លាំងឡើង ដោយចំណាយប្រើប្រាស់កាន់តែទាបឆ្ងាយពីបន្ទាត់ក្រីក្រ ។ កំណើនវិសមភាព ជាការព្រួយបារម្ភសំរាប់គ្រប់ភូមិសិក្សា ហើយអ្នកចូលរួមក្នុងក្រុមគោលដៅ បានផ្តល់មតិថា ការគួបផ្សំគ្នារវាងធនធានសេដ្ឋកិច្ច និងអំណាចខាងសង្គមកិច្ច-នយោបាយ វាបង្កនិន្នាការនេះឡើង ពីព្រោះ ធនធាន ឱកាសល្អ និងសេវាកម្ម កាន់តែប្រមូលផ្តុំច្រើនឡើងក្នុងដៃគ្រួសារធូរធារនានា ។

ចុងបញ្ចប់នៃជំលោះដោយប្រើអាវុធនៅចុងទសវត្សរ៍១៩៩០ ជាកត្តាមួយដ៏សំខាន់សំរាប់ការអភិវឌ្ឍភូមិក៏ពិតមែន ប៉ុន្តែទីតាំង ផ្លូវទាក់ទង និងលក្ខណៈភូមិសាស្ត្រនៃភូមិសិក្សា កាន់តែសំខាន់ថែមទៀតសំរាប់សុខមាលភាពរបស់សហគមន៍ ។ ភូមិមានដំណើរការខ្លាំង តែងមានទីតាំងនៅជិតផ្លូវជាតិ និងទីរួមខេត្តដែលមានផ្លូវល្អ មានដីជីជាតិល្អ និងមានប្រព័ន្ធធារាសាស្ត្រ រីឯភូមិមានដំណើរការបង្គួរ គឺនៅដាច់ស្រយាលជាង មានដីអន់ជាង ដីសំរាប់ដាំដុះតិចជាង និងគ្មានប្រព័ន្ធធារាសាស្ត្រទេ ។ ទិន្នផលបានខ្ពស់បំផុតនៅតាមភូមិមានដំណើរការខ្លាំង និងភូមិដែលមានប្រព័ន្ធធារាសាស្ត្រធម្មជាតិ រីឯភូមិមានដំណើរការបង្គួរ និងអន់ ជាទូទៅគ្មានសន្តិសុខស្បៀងទេ ។ ភូមិមានដំណើរការខ្លាំងក៏មានអន្តរាគមន៍ជួយការងារអភិវឌ្ឍច្រើនជាងដែរ ដូចជា ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ហើយប្រព័ន្ធទឹកស្អាត និងអនាម័យ ក៏ឃើញមានច្រើនជាងគេដែរ ។ សេវាកម្មដល់មនុស្សផ្ទាល់ (សុខភាព និង អប់រំ) មានការរីកចំរើននៅគ្រប់ភូមិសិក្សា ប៉ុន្តែ សហគមន៍ដែលនៅដាច់ស្រយាលជាងនេះ បន្តមានស្ថានភាពសុខភាពអន់ជាង សេវាកម្មថែទាំសុខភាពមានគុណភាពមិនទៀងទាត់ ហើយកុមារនៅក្នុងគ្រួសារក្រីក្រជាងគេ ជាពិសេសក្មេងស្រី នៅតែមិនបានទទួលការអប់រំ ។

ការយល់ដឹងពីអភិបាលកិច្ចល្អ និងតួនាទីរបស់ស្ថាប័នសាធារណៈ មានកំរិតទាបក្នុងចំណោមអ្នកភូមិធម្មតា ។ ការចូលរួមក្នុងដំណើរការសង្គម និងនយោបាយ ភាគច្រើនមានត្រឹមតែការបោះឆ្នោត ការចូលរួមកិច្ចប្រជុំសហគមន៍ និងសមាជិកភាពក្នុងសមាគមនានា (ជាទូទៅខាងសាសនា) ។ ឧទាហរណ៍នៃអភិបាលកិច្ចអន់ និងសមត្ថភាពស្ថាប័នខ្សោយមានលើកឡើងនៅគ្រប់ភូមិសិក្សា ហើយភូមិដែលពឹងផ្អែកលើធនធានធម្មជាតិមានការប៉ះពាល់ខ្លាំងជាងគេពីអំពើពុករលួយ ការបំភិតបំភ័យ និងទំនាស់អំពីការប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិ ។ ទំនុកចិត្តនិងការពេញចិត្តលើអាជ្ញាធរ មានកំរិតទាប ជាពិសេសលើមន្ត្រីថ្នាក់ខ្ពស់ដូចជា នគរបាល និងមន្ត្រីជលផលនិងព្រៃឈើ ។ អាជ្ញាធរមូលដ្ឋានទទួលបានទំនុកចិត្តច្រើនជាង ប៉ុន្តែអ្នកភូមិចាត់ទុកថា មិនអាចការពារផលប្រយោជន៍របស់អ្នកភូមិ រឺក៏ឆ្លើយតបយ៉ាងសក្តិសិទ្ធិទៅនឹងទំរង់ថ្មីៗនៃអសន្តិសុខដូចជា ការប្រើប្រាស់គ្រឿងញៀន ក្រុមក្មេងពាល អំពើហិង្សាក្នុងគ្រួសារ និងបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត ។ កាលពីមុន សន្តិភាព និងសុវត្ថិភាពជាបញ្ហាសំខាន់បំផុត ប៉ុន្តែបច្ចុប្បន្នអ្នកភូមិតាមជនបទកាន់តែរំពឹងសង្ឃឹមលើមេដឹកនាំថាអាចជួយកែលំអកំរិតជីវភាពរបស់ប្រជាជន ហើយអ្នកភូមិបានបង្ហាញនូវការខកចិត្តអំពីឧបសគ្គជាច្រើនដែលរារាំងការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រដ៏យឺតនេះ ។

គ្រួសារនានាពឹងផ្អែកកាន់តែច្រើនលើការបំរើអាជីពឱ្យខ្លួនឯង (self-employment) និងការងារស៊ីប្រាក់ឈ្នួល ហើយពឹងផ្អែកកាន់តែតិចលើកសិកម្ម និងធនធានទ្រព្យរួម (CPR) ដែលមានដូចជាជលផល និងព្រៃឈើ ។ គ្រួសារអ្នកធូរធាររកចំណូលបានកាន់តែច្រើនពីកសិកម្ម និងការងារបំរើអាជីពឱ្យខ្លួនឯង រីឯគ្រួសារក្រីក្រកាន់តែពឹងផ្អែកច្រើនលើការងារស៊ីប្រាក់ឈ្នួល ។ ទ្រព្យសកម្មសំរាប់បង្កើតទ្រព្យធន ដូចជា ដីកសិកម្ម ឥណទាននិងធាតុចូលសំរាប់ធ្វើកសិកម្ម និងពាណិជ្ជកម្ម បានប្រមូលផ្តុំនៅតាមភូមិមានដំណើរការខ្លាំង និងក្នុងដៃគ្រួសារធូរធារនានា ។ គ្រួសារធូរធារ និងគ្រួសារ

ដែលឈានឡើង មានដីកាន់កាប់ធំៗជាង និងទទួលបានទិន្នផល/ប្រាក់ចំណេញ ខ្ពស់ជាងគ្រួសារក្រីក្រដែលកាន់តែមិនអាចរកបានប្រាក់ចំណេញពីការធ្វើស្រែ ដូច្នេះហើយក៏លក់ដីធ្លី ហើយពឹងផ្អែកលើពលកម្មយកប្រាក់ឈ្នួល។ ផ្ទុយទៅវិញ គ្រួសារគ្មានដីមិនមែនសុទ្ធតែក្រីក្រនោះទេ ហើយការបាត់បង់ដីក៏មិនមែនសុទ្ធតែធ្វើអោយក្រនោះដែរ បើសិនមានប្រភពចំណូលផ្សេងទៀតដូចជា ពលកម្មយកប្រាក់ឈ្នួល និងការបំរើអាជីពឱ្យខ្លួនឯង ។ សព្វថ្ងៃ ការងារមិនមែនកសិកម្មកាន់តែសំខាន់ខ្លាំងឡើងនៅគ្រប់ភូមិ ហើយមនុស្សពេញវ័យជាអ្នកធ្វើការភាគច្រើន តែងមានការងារបន្ថែមក្រៅពីធ្វើស្រែចំការ ។ ស្ត្រីជាទូទៅធ្វើការងារស៊ីប្រាក់ឈ្នួល និងលក់ដូរតូចតាច ហើយភាគច្រើននិយមលក់ពលកម្មនៅក្នុងមូលដ្ឋាន ។ ផ្ទុយទៅវិញ បុរសៗច្រើនទៅនេសាទ កាប់ឈើ និងធ្វើចំណាកស្រុកស្វែងរកការងារធ្វើ ។ ការធ្វើចំណាកស្រុក ដូចជាទៅប្រទេសថៃ គឺជាប្រភពចំណូលដ៏សំខាន់សំរាប់គ្រួសារធូរធារ និងគ្រួសារដែលឈានឡើង ។

គ្រួសារភាគច្រើនជំពាក់បំណុលគេ ហើយបន្តខ្ចីពីមិត្តភក្តិ រឺសាច់ញាតិ រឺពីអ្នកចងការប្រាក់ ជាជាងទៅខ្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) រឺពីធនាគារភូមិ ។ ខណៈដែលភូមិមានដំណើរខ្លាំង និងគ្រួសារធូរធារ តែងប្រើឥណទានសំរាប់គោលបំណងផលិត សហគមន៏និងគ្រួសារក្រីក្រច្រើនប្រើវាសំរាប់ដោះស្រាយវិបត្តិ ហើយជាញឹកញាប់ច្រើនជាប់ខ្លួនក្នុងបែបបទឥណទានចាក់ស្រេះគ្នា ។ គ្រួសារភាគច្រើនមានវិបត្តិផ្សេងៗ ហើយការឈឺថ្កាត់ ឃើញមានទូទៅជាងគេបន្ទាប់មកគឺការខូចខាតផលដំណាំ និងការស្លាប់សត្វចិញ្ចឹម ។ គ្រួសារធូរធារមានលទ្ធភាពប្រើ ប្រាក់សន្សំ និងទ្រព្យធនដើម្បីដោះស្រាយវិបត្តិ រីឯគ្រួសារក្រីក្រច្រើនតែកាត់បន្ថយចំណាយប្រើប្រាស់ រឺឱ្យសមាជិកគ្រួសារធ្វើចំណាកស្រុកទៅរកការងារធ្វើ ដោយសារគ្រួសារក្រីក្រទទួលរងការបាត់បង់ប្រាក់ចំណូលធ្ងន់ធ្ងរជាង ។ ទោះបីវិបត្តិ និងព្រឹត្តិការណ៏ខ្លះក្នុងឆាកជីវិតអាចទស្សទាយបានក្តី ក៏គ្រួសារក្រីក្រពុំមានធ្វើផែនការ រឺត្រៀមអ្វីសំរាប់ទប់ទល់នឹងបញ្ហាទាំងនោះទេ ។

ការផ្លាស់ប្តូរខាងប្រជាសាស្ត្រ ដូចជាចំណាកស្រុក និងកំណើនប្រជាជន បានដាក់សំពាធលើធនធាន ដូចជាដីធនធានទ្រព្យរួម នៅគ្រប់ភូមិសិក្សា ។ គ្រួសារធ្វើចំណាកស្រុកច្រើនតែជាអ្នកក្រីក្រ និងគ្មានដីធ្លី ។ ការរៀបការកូនមានតំលៃថ្លៃពីព្រោះមានចំណាយច្រើនក្នុងពិធីមង្គលការតាមបែបប្រពៃណី ហើយជាទូទៅនាំឱ្យមានការជ្រៀកដីចែកកូន ។ គ្រួសារក្រីក្រមានអត្រាអ្នកក្នុងបន្ទុកខ្ពស់ រីឯគ្រួសារធូរធារមានអ្នករកចំណូលច្រើននាក់ និងអ្នកក្នុងបន្ទុកតិច ។ ឥរិយាបថបំផ្លិចបំផ្លាញរបស់សមាជិកគ្រួសារបុរស ដូចជា អំពើហិង្សាក្នុងគ្រួសារ ការសេពសុរា ក្រុមក្មេងពាល វាជះឥទ្ធិពលមកលើសហគមន៏ និងគ្រួសារ ។ អំពើហិង្សាក្នុងគ្រួសារហាក់ដូចបានថយចុះក្នុងភូមិសិក្សាភាគច្រើន ប៉ុន្តែវានៅចោទបញ្ហាធ្ងន់ធ្ងរក្នុង ៣ភូមិយ៉ាងតិច ហើយវារួមចំណែកដល់ការធ្លាក់ខ្លួនក្រដោយសារការបាត់បង់ចំណូលនិងទ្រព្យចំណាយលើថ្លៃព្យាបាលជំងឺ/របួស ចំណាយលើការលែងលះ និងការបែកបាក់គ្រួសារ ។ ការសេពសុរា និងក្រុមក្មេងពាល ជាបញ្ហាដែលភូមិសិក្សាទាំងអស់បានលើកឡើងថាគួរអោយព្រួយបារម្ភយ៉ាងខ្លាំង ដោយក្នុងនេះ គ្រួសារធូរធារមានលទ្ធភាពច្រើនជាង ក្នុងការរ៉ាប់រងបន្ទុកចំណាយជាប់ទាក់ទិននឹងសកម្មភាពទាំងនោះ (ដូចជាបង់ថ្លៃឱ្យអាជ្ញាធរនៅពេលដែលយុវជនទាំងនោះត្រូវចាប់ខ្លួន រឺបង្កការខូចខាត) ។

## ការសិក្សាពីការចាកផុតភាពក្រីក្រ ផ្តល់ចំលើយដល់សំនួរសំខាន់ៗដែលការស្រាវជ្រាវត្រូវពិនិត្យ

លើកលែងតែបទពិសោធន៏នៃភាពក្រីក្ររបស់បុគ្គលម្នាក់ៗ សំនួរសំខាន់ៗដែលការស្រាវជ្រាវនេះត្រូវពិនិត្យ គឺមានចំលើយ នៅក្នុងរបកគំហើញនៃការសិក្សា ។ ភូមិដែលមានកំរិតជីវភាពខ្ពស់ តែងមានទីតាំងល្អងាយស្រួលទាក់ទងមានផ្លូវថ្នល់ចរាចរបានពេញៗមួយឆ្នាំ មានដីល្អ និងទ្រព្យពីធម្មជាតិដូចជា ការស្រោចស្រពដោយយកទឹកពីបឹង/អូរ ។

គ្រួសារដែលបានកែលំអជីវភាព គឺជាគ្រួសារដែលមានឱកាស និងធនធាន (ដូចជាមូលធនខាងសេដ្ឋកិច្ច និងនយោបាយ-សង្គមកិច្ច) និងសមត្ថភាពបង្កើតប្រភពចំណូលថ្មីៗ និងការធ្វើចំរុះកម្មប្រភពប្រាក់ចំណូល ។ ចំពោះភូមិដែលធ្លាក់ចុះជីវភាព គឺភូមិដែលពឹងផ្អែកលើធនធានទ្រព្យរួម ស្ថិតនៅឆ្ងាយពីទីប្រជុំជន មានផ្ទៃដីតិចសំរាប់ដាំដុះ ដីមិនសូវមានជីជាតិ និងគ្មានធារាសាស្ត្រ ។ គ្រួសារដែលគ្មានការប្រែប្រួលជីវភាព រឺធ្លាក់ចុះ គឺជាគ្រួសារមានដីធ្លីកាន់កាប់តិច អ្នករកចំណូលតិចនាក់ អ្នកក្នុងបន្ទុកច្រើន និងត្រូវពឹងផ្អែកលើប្រភពចំណូលតែមួយរឺពីរ ហើយនិងគ្រួសារដែលជួបវិបត្តិ រឺទទួលរងផលប៉ះពាល់ពីឥរិយាបថបំផ្លិចបំផ្លាញរបស់សមាជិកគ្រួសារបុរស ។

ដូចការរំពឹងទុក កំណើនសេដ្ឋកិច្ចជួយអោយគ្រួសារខ្លះចាកផុតពីភាពក្រីក្រ ហើយគ្រួសារដែលឈានឡើងឃើញមានច្រើន នៅតាមភូមិដែលមានដំណើរការខ្លាំង រីឯគ្រួសារដែលធ្លាក់ចុះ និងក្រីក្រ ឃើញមានច្រើននៅតាមភូមិមានកំណើនយឺត រឺធ្លាក់ចុះសេដ្ឋកិច្ច ។ ក្នុងបរិបទដែលមានអភិបាលកិច្ចអន់ និងស្ថាប័នទន់ខ្សោយ ផលប្រយោជន៏នៃកំណើនមិនបានបែងចែកស្មើគ្នាល្អទេ ។ វិសមភាព (ជាពិសេសលើប្រាក់ចំណូល និងទ្រព្យ) កើនឡើងគួរឱ្យកត់សំគាល់ក្នុងភូមិ ដែលមានកំនើនសេដ្ឋកិច្ច (ប្រាក់ចំនូលសរុបមានកំរិតខ្ពស់ជាង និងកើនលឿនជាង ពីឆ្នាំ២០០១ ដល់ ២០០៤/០៥) ។ អភិបាលកិច្ចអន់ និងស្ថាប័នខ្សោយ គឺជាហ្រាំងទប់ការកាត់បន្ថយភាពក្រីក្រ និងបង្កកំណើនវិសមភាព ។ វិសមភាពអាចធ្វើឱ្យកម្ពុជាបាត់ស្ថិរភាព ដោយអ្នកក្រីក្រកាន់តែបាត់បង់ឱកាស ស្ថាប័នមានទំនោរជួយអ្នកធូរធារជាងអ្នកក្រ ហើយទំនុកចិត្តលើមន្ត្រីសាធារណៈត្រូវធ្លាក់ចុះ ។ ដូចនេះ ការយកចិត្តទុកដាក់ជាពិសេសដល់ទិដ្ឋភាពខាងនយោបាយ-សង្គមកិច្ចនៃភាពក្រីក្រ ជាចំនុចសំខាន់បំផុតសំរាប់ការសិក្សាពីភាពក្រីក្រទៅអនាគត និងគំនិតផ្តួចផ្តើមផ្សេងៗដើម្បីកាត់បន្ថយភាពក្រីក្រ ។

បញ្ហា "ខ្នង" (ខ្នងបង្អែក) គឺជាប្រធានបទស្នូលក្នុងកិច្ចពិភាក្សាពីអំណាច និងឱកាស នៅតាមក្រុមគោលដៅនានា ។ "ខ្នង" សំដៅដល់តំណភ្ជាប់ និងបណ្តាញ នៅក្នុង "ខ្សែ" នៃទំនាក់ទំនងជួយឧបត្ថម្ភ ដែលក្នុងនេះ អ្នកមានឋានៈខ្ពស់នៅក្នុងខ្សែរយៈផ្តល់ការអនុគ្រោះនិងកិច្ចការពារ ដើម្បីទទួលបានវិញនូវភក្តីភាពពលកម្មនិងសេវាផ្សេងៗពីអ្នកនៅខាងក្រោម ។ ទោះបីទំរង់ជាប្រពៃណីនៃមូលធនសង្គម ដូចជា ការប្រវាស់ដៃ ជាដើម បានបាត់បង់ច្រើនណាស់ក្តី ប៉ុន្តែទំនាក់ទំនងជួយឧបត្ថម្ភបែរជាកាន់តែសំខាន់ខ្លាំងឡើងសំរាប់ការឈានឡើងរបស់គ្រួសារនានា ពីព្រោះវាផ្តល់ឱកាសល្អជួយដល់គ្រួសារក្នុងការបង្កើនទ្រព្យធន និងជួយពួកគេឱ្យទទួលបានលទ្ធផលជាទីពេញចិត្តក្នុង សេចក្តីសំរេចចិត្តនៅតាមមូលដ្ឋាន ទំនាស់ និងវិវាទតាមផ្លូវច្បាប់ផ្សេងៗ ។

កត្តាចំបងៗដែលជួយទ្រទ្រង់គ្រួសារឱ្យរំដោះខ្លួនចេញពីភាពក្រីក្រ រួមមាន ទីតាំងក្នុងភូមិដែលមានដំណើរការខ្លាំង មានអ្នករកចំណូលច្រើននាក់ មានឱកាសច្រើនដើម្បីបង្កើតចំណូល និងមានសមត្ថភាពសន្សំប្រាក់និងវិនិយោគលើទ្រព្យរបស់ដែលអាចជួយការពារគ្រួសារទប់ទល់ការប៉ះទង្គិច រឺវិបត្តិផ្សេងៗ និងមានការវិនិយោគទុនទៅលើមូលធនមនុស្ស (សុខភាព និងការអប់រំ) ។ កត្តាចំបងដែលរុញច្រានគ្រួសារឱ្យធ្លាក់ខ្លួនក្រ គឺមាន ទីតាំងក្នុងភូមិដែលមានដំណើរការអន់ថយ រឺបង្គួរ គួបផ្សំនឹងអ្នករកចំណូលមានតិចនាក់ អ្នកក្នុងបន្ទុកមានច្រើននាក់ ការប៉ះទង្គិច/វិបត្តិមានជួបច្រើន និងឥរិយាបថបំផ្លិចបំផ្លាញ/បង្កគ្រោះថ្នាក់របស់សមាជិកគ្រួសារ ។ សំខាន់ជាងនេះទៀត គ្រួសារដែលមានជីវភាពធ្លាក់ចុះ ជាញឹកញាប់គឺជាគ្រួសារដែលមិនបានប្រមើលទុកពីការប៉ះទង្គិច/វិបត្តិផ្សេងៗ រឺមិនបានសន្សំទ្រព្យ/ប្រាក់គ្រប់គ្រាន់ សំរាប់ទប់ទល់ហេតុការណ៏ចៃដន្យទាំងនេះ ។ គ្រួសារក្រីក្រខ្លាំងមានលក្ខណៈខុសប្លែកពីនេះ ។ ពួកគេច្រើន

រស់នៅក្នុងភូមិក្រីក្រ និងភូមិដែលពឹងផ្អែកលើធនធានទ្រព្យរួម មានអ្នករកចំណូលមានតិចនាក់ និងអ្នកក្នុងបន្ទុកច្រើននាក់ ។ យោងតាមកិច្ចពិភាក្សានៃក្រុមគោលដៅ គ្រួសារទាំងនោះច្រើនមានមេគ្រួសារជាស្ត្រីគ្មានប្តី មានវ័យចំណាស់ រឺពិការ ។ ពួកគេមានដីតិច រឺគ្មានសោះ ហើយជាញឹកញាប់ពឹងផ្អែកលើធនធានទ្រព្យរួម ។ ពួកគេគ្មានសមត្ថភាពធ្វើវិនិយោគលើមូលធនមនុស្ស រឺក៏ធនធានផ្សេងៗដើម្បីចាប់យកឱកាសថ្មីៗ ដូចជាពលកម្មយកប្រាក់ឈ្នួល ហើយជារឿយៗជំពាក់បំណុលជាច្រើនដោយត្រូវសងវិញជាកំលាំងពលកម្ម ។ អសន្តិសុខស្បៀង និងពលកម្មកុមារឃើញមានជាទូទៅក្នុងគ្រួសារទាំងនេះ ។

កត្តាដែលជួយអោយគ្រួសារនានារួចផុតពីភាពក្រីក្រ ច្រើនមានដំណើរការនៅក្នុងភូមិ និងរួមមាន លទ្ធភាពប្រសើរឡើង ក្នុងការទាក់ទងប្រើប្រាស់ទីផ្សារនិងសេវាកម្មផ្សេងៗ កំណើនផលិតភាពកសិកម្ម និងឱកាសទទួលបានការងារស៊ីប្រាក់ឈ្នួល ហើយតាមនេះងាយស្រួលនឹងជួយបានតាមរយៈអន្តរាគមន៍ខាងគោលនយោបាយផ្តោតលើសហគមន៍ (ដូចជា ការកសាងផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ) ។ ផ្ទុយទៅវិញ លក្ខណៈផ្ទៃក្នុង ដូចជា មហិច្ឆតា ការហ៊ានប្រថុយគ្រោះថ្នាក់ វត្តមានមនុស្សពេញវ័យរកចំណូលច្រើននាក់ និងសេវាកម្មខាងសុខភាពនិងអប់រំល្អប្រសើរ វាពិតជាជួយឱ្យគ្រួសារអាចឆក់យកឱកាសល្អបាននៅពេលវាផុសឡើង ហើយការមានខ្សែរយៈតភ្ជាប់ និងខ្នង ក៏សំខាន់ដូចគ្នាដែរ ។ កត្តាដែលនាំអោយគ្រួសារធ្លាក់ចុះ រឺនៅក្រីក្ររហូត មានដូចជា វត្តមានការប៉ះទង្គិច/ជំងឺ តរិយាបថបំផ្លិចបំផ្លាញរបស់សមាជិកគ្រួសារ និងបញ្ហាតុល្យភាពរវាងចំនួនអ្នករកចំណូល និងអ្នកក្នុងបន្ទុក ។ អសមត្ថភាពធ្វើវិនិយោគលើមូលធនមនុស្ស និងកង្វះខ្សែរយៈតភ្ជាប់ និងបណ្តាញ ក៏ជាកត្តាសំខាន់ដែរ ដែលធ្វើអោយគ្រួសារនៅតែក្រីក្រ និងត្រូវទទួលរ៉ាប់រងនូវបន្ទុកចំណាយលើអំពើពុករលួយនៅក្នុងដំណើរការប្រចាំថ្ងៃរបស់ខ្លួន ។ គ្រួសារក្រីក្រ និងធ្លាក់ខ្លួនក្រពិតជារងឥទ្ធិពលពីកត្តាសហគមន៍ ពិសេសទីតាំង និងភូមិសាស្ត្រភូមិ ព្រមទាំងគ្រោះធម្មជាតិដែលប៉ះពាល់ដល់ភូមិជាច្រើននៅប្រទេសកម្ពុជាពីឆ្នាំ២០០១ ដល់ ២០០៤/០៥ ។ លក្ខណៈផ្ទៃក្នុងធ្វើអោយគ្រួសារក្រីក្រ ងាយរងគ្រោះដោយកត្តាខាងក្រៅ ជាងគ្រួសារឯទៀត ។

ទំនាក់ទំនងរវាងកត្តានានា ប្រែប្រួលយ៉ាងខ្លាំងទៅតាមស្ថានភាពភូមិនីមួយៗ ពីព្រោះបំរែបំរួលខ្លាំងអ្វីមួយ (ដូចជាកំណើនការទិញលក់ដីធ្លីរឺការថយចុះព្រៃឈើ) អាចផ្លាស់ប្តូរជោគវាសនារបស់សហគមន៍ទាំងមូល ។ផ្ទុយទៅវិញ បំរែបំរួលនៅទូទាំងប្រទេស (ដូចជា កំណើនយុវជន) អាចមានផលប៉ះពាល់ខុសគ្នាក្នុងភូមិខុសៗគ្នា ពីព្រោះភូមិនីមួយៗមានលក្ខណៈផ្ទាល់រៀងៗខ្លួន (ដែលនាំអោយមានចំណាកស្រុក និងកំណើនប្រាក់ចំណូលក្នុងសហគមន៍ខ្លះ ហើយមានបញ្ហាសង្គម និងការខកចិត្តក្នុងភូមិផ្សេងទៀត) ។ ដូច្នេះជួនកាលគេពិបាកនឹងធ្វើការសន្និដ្ឋានជារួម យោងតាមលទ្ធផលរកឃើញក្នុងការសិក្សាដែរ ដោយសារបទពិសោធន៍ដោយឡែកៗពីគ្នារបស់សហគមន៍នីមួយៗនេះ ។

ទោះបីជាការសិក្សាមិនអាចពិនិត្យបានស៊ីជំរៅលើបញ្ហាយេនឌ័ររបស់បុគ្គលម្នាក់ៗក៏ដោយ ក៏វាបានបង្ហាញពីនិន្នាការសំខាន់ៗមួយចំនួនទាក់ទងនឹងយេនឌ័រ ដូចជា ភាពខុសគ្នារវាងគ្រួសារមានបុរសជាមេគ្រួ និងគ្រួសារមានស្ត្រីជាមេគ្រួ ។ គ្រួសារស្ត្រីមេគ្រួមានលក្ខណៈផ្ទាល់ បទពិសោធន៍ពីភាពក្រីក្រ និងការឈានឡើងខុសគ្នាពីគ្រួសារបុរសមេគ្រួ ។ គ្រួសារស្ត្រីមេគ្រួមិនមែនសុទ្ធតែក្រីក្រជាងគេនោះទេ ហើយជាក់ស្តែងមានគ្រួសារខ្លះបានចាកផុតពីភាពក្រីក្រ រឺនៅតែធូរធារដដែល ។ ជារឿយៗ ស្ត្រីជាមេគ្រួសារដែលធូរធារ ច្រើនតែពុំមានប្តីទេ ហើយស្ត្រីជាមេគ្រួសារដែលមានប្តីជាមនុស្សមិនអាចរកចំណូល/មនុស្សក្នុងបន្ទុក ច្រើនតែមានជីវភាពគ្រួសារក្រីក្រណាស់ ។ ទោះយ៉ាងនេះក្តី

ចលនាឈានឡើងរបស់គ្រួសារស្ត្រីមេគ្រួក្នុងការសិក្សានេះ ច្រើនតែគ្មានស្ថិរភាព ពីព្រោះពួកគេមានចំណាយច្រើនជាង និងចំណូលតិចជាងគ្រួសារបុរសមេគ្រួ ដូច្នេះហើយមានលទ្ធភាពសន្សំទ្រព្យ/ប្រាក់បានតិចជាង ។

## លទ្ធផលសំរាប់ការងារខាងគោលនយោបាយ និងអនុសាសន៍សំរាប់ការស្រាវជ្រាវនៅពេលអនាគត

ភូមិ និងគ្រួសារនៅជនបទ គឺមិនដូចគ្នាទេ ហើយអន្តរាគមន៍ខាងគោលនយោបាយច្រើនមានផលប៉ះពាល់ខុសគ្នាខ្លាំងទៅលើសហគមន៍ និងគ្រួសារ អាស្រ័យលើប្រវត្តិ ស្ថានភាព និងលក្ខខណ្ឌបច្ចុប្បន្នរបស់សហគមន៍ និងគ្រួសារ ។ ការសិក្សាបង្ហាញថា ភាពខុសគ្នារវាងភូមិ និងគ្រួសារនៅជនបទ ត្រូវតែស្វែងយល់ និងយកមកគិតគូរ ដើម្បីធ្វើអន្តរាគមន៍អោយចំគោលដៅ និងកាន់តែមានប្រសិទ្ធភាព ។ វាក៏បង្ហាញពីតំរូវការធ្វើចំណាយសាធារណៈឱ្យកាន់តែច្រើន ព្រមទាំងផ្ទេរសិទ្ធិធ្វើចំនាយ និងប្រមូលចំណូលទៅឱ្យថ្នាក់មូលដ្ឋាន ។ ផ្ទុយទៅវិញ ការសិក្សាបង្ហាញថា សមត្ថភាពស្ថាប័នទន់ខ្សោយ និងអភិបាលកិច្ចអន់ ទាមទារការឆ្លើយតបថ្នាក់ជាតិ ពីព្រោះស្ថាប័នថ្នាក់មូលដ្ឋានមិនមានសមត្ថភាពរដ្ឋបាល វិធិរញ្ញវត្ថុ វិអំណាច ដើម្បីញ៉ាំងឱ្យមានការផ្លាស់ប្តូរពិតៗនៅក្នុងវប្បធមិនយោបាយផ្អែកលើការជួយឧបត្ថម្ភរបស់ប្រទេសកម្ពុជានេះទេ ។

ការសិក្សាគាំទ្រឱ្យមានវិនិយោគកាន់តែច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជា ផ្លូវថ្នល់ និងកសិកម្មដែលក្នុងនេះ មានទាំងប្រព័ន្ធធារាសាស្ត្រ និងសេវាផ្សព្វផ្សាយបច្ចេកទេសផង ។ ដោយហេតុថា ភូមិទាំងអស់មិនមែនសុទ្ធតែពឹងផ្អែកជាសំខាន់លើកសិកម្មនោះទេ ការសិក្សាបង្ហាញពីតំរូវការធ្វើវិនិយោគកាន់តែច្រើនទៅលើឱកាសការងារនៅជនបទ ព្រមទាំងកិច្ចការពារជាមូលដ្ឋានតាមផ្លូវច្បាប់ ។ សំរាប់ភូមិដែលពឹងផ្អែកលើធនធានទ្រព្យរួម និងមានដីកសិកម្មតិច គឺមានតំរូវការជាបន្ទាន់នូវជំរើសផ្សេងក្រៅពីការធ្វើកសិកម្ម និងការប្រមូលធនធានទ្រព្យរួម ពីព្រោះទោះបីធនធានធម្មជាតិមានការគ្រប់គ្រងបានល្អក្នុងពេលអនាគតក្តី កំណើនចំនួនប្រជាជន នឹងដាក់សំពាធកាន់តែខ្លាំងឡើងលើធនធានទ្រព្យរួម ។

ការសិក្សាគាំទ្រការកំណត់គោលដៅឱ្យកាន់តែជាក់លាក់ទៅលើគ្រួសារនៅជនបទ ពិសេសគ្រួសារក្រីក្រ និងក្រីក្រខ្លាំង ។ ការសិក្សានេះស្នើថា ការកំណត់គោលដៅអន្តរាគមន៍ទៅលើហេដ្ឋារចនាសម្ព័ន្ធជនបទ និងផលិតភាពកសិកម្ម នឹងផ្តល់ផលប្រយោជន៍ច្រើនបំផុតដល់ពួកគ្រួសារធូរធារ ក៏ដូចជាឱកាសធ្វើជំនួញ ការងារប្រើជំនាញ និងឥណទានថោកអាចបត់បែនស្រួល ។ ទោះបីគ្រួសារដែលចុះក្រខ្លះ អាចទទួលបានផលប្រយោជន៍ពីអន្តរាគមន៍ទាំងនេះក្តី ប៉ុន្តែត្រូវមានវិធានការសំរាប់ការពារ ដូចជា វិនិយោគសាធារណៈកាន់តែច្រើនលើការអប់រំនិងថែទាំសុខភាព កិច្ចការពារខាងសង្គមកិច្ចនិងតាមផ្លូវច្បាប់ (ឧ. ធានារ៉ាប់រងសុខភាព/គ្រោះធម្មជាតិ ប្រព័ន្ធថែទាំសុខភាពមានសមធម៌ និងកិច្ចការពារពលកម្មជាមូលដ្ឋាន) ដើម្បីទប់ស្កាត់គ្រួសារកុំឱ្យធ្លាក់ចូលក្នុងភាពក្រីក្រ ។ គ្រួសារក្រីក្រខ្លាំង ត្រូវការជាចាំបាច់នូវអន្តរាគមន៍សំរាប់បញ្ចាជាប់ផុងក្នុងភាពក្រីក្រ និងជួយពួកគេដោះស្រាយស្ថានភាពបច្ចុប្បន្នដូចជា កម្មវិធីសន្តិសុខស្បៀង ការផ្តល់សេវាអប់រំនិងថែទាំសុខភាពនៅតាមមូលដ្ឋានដោយឥតគិតថ្លៃ វិមានឧបត្ថម្ភធនច្រើន ជំរើសការងារមានច្រើននៅមូលដ្ឋាន និងកិច្ចការពារពលកម្មជាមូលដ្ឋាន ។ អាជ្ញាធរមូលដ្ឋានដែលរឹងមាំ និងមានគណនេយ្យភាពខ្ពស់ គឺសំខាន់ខ្លាំងណាស់ ដើម្បីការពារផលប្រយោជន៍ និងដោះស្រាយតំរូវការរបស់គ្រួសារក្រីក្រ ។

មកទល់សព្វថ្ងៃ មានការប្រឹងប្រែងច្រើនណាស់ក្នុងការសិក្សាពីការចាកផុតភាពក្រីក្រ ដោយមានការចុះអង្កេត ២វគ្គ ក្នុងភូមិសិក្សា នៅឆ្នាំ២០០១ និង ២០០៤/០៥ ។ ការអង្កេតតាមក្រុមនេះ នឹងមានតំលៃជាក់លាក់លុះត្រាតែមានវគ្គទី៣ រឺវគ្គច្រើនបន្តទៀត ដូច្នេះមានហេតុផលច្រើនណាស់ដែលត្រូវធ្វើការសិក្សាស្រាវជ្រាវជាបន្តបន្ទាប់តាមបណ្តោយពេល (longitudinal research) ។ ការសិក្សាទៅអនាគតដែលមានលក្ខណៈតាមបណ្តោយពេលប្រើវិធីសាស្ត្រចំរុះ និងគិតគូរពីបរិបទ អាចរួមចំណែកយ៉ាងច្រើនដល់ការវិភាគ និងការពិនិត្យតាមដានពីភាពក្រីក្រកំរិតជាតិ ព្រមទាំងជួយផ្តល់ការយល់ដឹងពីតុល្យភាពរវាងភាពក្រីក្របណ្តោះអាសន្ន និងភាពក្រីក្ររហូត និងការមើលឃើញពីនិន្នាការនៃភាពក្រីក្រនៅកម្ពុជា ។ វគ្គនានាទៅអនាគតនៃការសិក្សាពីការចាកផុតភាពក្រីក្រ អាចយកចំណេញពីមេរៀនដែលបានមកពីការសិក្សានេះ ហើយបន្ស៊ីលទ្ធផលនៃការសិក្សានេះ និងការស្រាវជ្រាវនាអនាគតឱ្យជាប់ទាក់ទងកាន់តែខ្លាំងទៅនឹងការវិភាគ និងការពិនិត្យតាមដានពីភាពក្រីក្រថ្នាក់ជាតិ ។ ដោយនៅក្នុងពិភពលោក ការសិក្សាពីឌីណាមិកនៃភាពក្រីក្រ នៅមានតិចតួចនៅឡើយ ដូច្នេះការសិក្សាការចាកផុតភាពក្រីក្រដែលកំពុងដំណើរការនេះ អាចមានប្រយោជន៍ច្រើនដល់ប្រទេសកម្ពុជា និងប្រទេសដទៃទៀត ។

# សេចក្ដីបន្ថែម ២
# ការវាយតម្លៃភាពក្រីក្រដោយមានការចូលរួមនៅតំបន់បឹងទន្លេសាប

## សេចក្ដីសង្ខេប

ការវាយតំលៃភាពក្រីក្រដោយមានការចូលរួម (Participatory Poverty Assessment: PPA) នៅតំបន់បឹងទន្លេសាប បានប្រតិបត្តិដោយវិទ្យាស្ថាន CDRI វិទ្យាស្ថានជាតិស្ថិតិ (NIS) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ ការសិក្សានេះ បានប្រើប្រាស់វិធីសាស្ត្របែបគុណភាព និងធ្វើនៅ ២៤ភូមិ ជ្រើសរើសពី ៦ខេត្ត នៅជុំវិញបឹងទន្លេសាប ។ គោលបំណងចំបងនៃការសិក្សានេះ គឺដើម្បីផ្ដល់ការយល់ដឹងស៊ីជំរៅថែមទៀត ជូនដល់អ្នកតាក់តែងគោលនយោបាយ ម្ចាស់ជំនួយនិងសង្គមស៊ីវិល ស្ដីអំពី ១) ចំណងទាក់ទងរវាងយុទ្ធសាស្ត្រចិញ្ចឹមជីវិតរបស់អ្នកក្រ ជាមួយនឹងការប្រើប្រាស់ និងការគ្រប់គ្រងធនធានធម្មជាតិ ២) ទិដ្ឋភាពយេនឌ័រនៃភាពក្រីក្រ និង ៣) តួនាទីនៃអភិបាលកិច្ចមូលដ្ឋាននៅក្នុងការកាត់បន្ថយភាពក្រីក្រ ។

ការវាយតំលៃភាពក្រីក្រដោយមានការចូលរួមបង្ហាញថា អ្នកក្រនិងអ្នកក្រខ្លាំងជាច្រើននាក់នៅតំបន់ទន្លេសាប មិនបានទទួលផលចំណេញពីកំណើនសេដ្ឋកិច្ចយ៉ាងលឿននៅកម្ពុជាទេ ហើយជារឿយៗ ច្រើនតែនៅឆ្ងាយផុតពីឥទ្ធិពលនៃគោលនយោបាយសាធារណៈ ។ ការកត់សំគាល់នេះ ចោទបញ្ហាជាច្រើនដល់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដើម្បីកាត់បន្ថយភាពក្រីក្រឱ្យបានជាក់ស្ដែងនិងសក្ដិសិទ្ធិ ស្របតាមគោលដៅនានាដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ នាសម័យប្រជុំស្ដីពី គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

ការសិក្សា PPA បានបង្ហាញថា អ្នកក្រ និងអ្នកក្រខ្លាំង មានការពឹងផ្អែកកាន់តែខ្លាំងទៅលើដីធ្លី ទឹក និងធនធានធម្មជាតិ ដើម្បីទ្រទ្រង់ជីវភាពដ៏ផុយស្រួយរបស់ខ្លួន ។ ប៉ុន្តែគ្រោះរាំងស្ងួត និងទឹកជំនន់ជាច្រើនឆ្នាំ ព្រមទាំងដីខ្វះជីជាតិ និងកង្វះសមត្ថភាពគ្រប់គ្រងទឹក បានកាត់បន្ថយផលិតភាពកសិកម្ម រីឯលទ្ធភាពជាប្រពៃណីរបស់ប្រជាជនក្នុងការប្រើប្រាស់ធនធានព្រៃឈើ និងត្រី ក៏កាន់តែទទួលរងសំពាធនៃកំណើនប្រជាជន ហើយនិងទំនាស់ជាមួយអ្នកមានឋានៈខ្ពស់នៅក្នុងមូលដ្ឋាន និងតួអង្គមានអំណាចដែលមកពីក្រៅភូមិ ។ ជាលទ្ធផល មានអ្នកក្រីក្រកាន់តែច្រើនកំពុងលក់ពលកម្មទៅឱ្យអ្នកគ្រាន់បើជាងនៅក្នុងមូលដ្ឋាន ឬត្រូវធ្វើចំណាកស្រុកទៅកន្លែងផ្សេងក្នុងប្រទេស ឬទៅប្រទេសក្រៅ ដូចជាថៃ និងម៉ាឡេស៊ី ដើម្បីរកការងារធ្វើ ។

ការសិក្សាក៏បង្ហាញដែរថា អ្នកក្រ និងអ្នកក្រខ្លាំង ពុំមានលទ្ធភាពប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជាប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជាដើម ហើយតែងត្រូវផាត់ចេញពីសេវាកម្មខាងការអប់រំ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការថែទាំសុខភាព ពីព្រោះពុំអាចបង់ថ្លៃសេវាកម្មទាំងនេះបាន ។ ដោយសារចំនាយដ៏ខ្ពស់ គួបផ្សំនឹងប្រាក់កំរៃក្រៅផ្លូវការរបស់គ្រូបង្រៀនផង កូនចៅអ្នកក្រីក្រតែងតែត្រូវឈប់រៀនតាំងពីក្មេង ជាពិសេសកុមារី ដែលត្រូវឈប់រៀនយ៉ាងឆាប់ ។ តំលៃដ៏ខ្ពស់នៃការថែទាំសុខភាព ក៏បានរុញច្រាន អ្នកក្រ និងអ្នកក្រខ្លាំង ឱ្យធ្លាក់ខ្លួនត្រូវលក់ទ្រព្យសម្បត្តិដូចជាដីធ្លីជាដើម ដើម្បីបង់ថ្លៃសេវាថែទាំសុខភាព ដែលជំរុញឱ្យពួកគេកាន់តែងាយអស់ដីធ្លី ឬកាន់តែក្រជាងមុន ។

អ្នកក្រ និងអ្នកក្រខ្លាំង ក៏ត្រូវផាត់ចេញពីសេវាកម្មខាងសង្គមកិច្ចផ្សេងៗ ពីព្រោះពុំមានព័ត៌មាន និងការយល់ដឹងពីសេវាកម្មទាំងនេះ ហើយនិងសិទ្ធិត្រូវទទួលបានសេវាកម្មបែបនេះ ។ ដូច្នេះហើយ ស្ថានភាពរបស់អ្នកក្រីក្រ ជាពិសេសអ្នកក្រីក្របំផុត គឺនៅតែក្រហើយក្រទៀតរហូតទៅ ។

ការសិក្សាក៏បានបង្ហាញពីមនុស្សជាច្រើនដែលមានអារម្មណ៍ថា សន្តិសុខផ្ទាល់ខ្លួនមានលក្ខណៈផុយស្រួយ ហើយអ្នកក្រ និងអ្នកក្រខ្លាំងងាយរងគ្រោះ ជាពិសេសចំពោះអំពើហិង្សាក្នុងគ្រួសារ វិសាធារណៈក្នុងគ្រប់រូបភាព ។ ការភ័យព្រួយរបស់ស្ត្រីអំពីការចាប់រំលោភ និងការភ័យព្រួយរបស់ឪពុកម្តាយពីកង្វះសុវត្ថិភាពក្នុងការបញ្ជូនកូនស្រីឱ្យទៅរៀន គឺជាកត្តារាំងស្ទះមួយដែលការសិក្សា PPA បានពិនិត្យឃើញនៅគ្រប់កន្លែង ។ នៅគ្រប់ភូមិ ប្រជាជនបានកត់សំគាល់ពីអំពើហិង្សាដែលបង្កឡើងដោយយុវជន និងក្រុមអ្នកលេង ។ នៅភូមិខ្លះ គេបានពិនិត្យឃើញមានយុវជនប្រើប្រាស់គ្រឿងញៀន ។ ចំពោះអំពើហិង្សាក្នុងគ្រួសារទៅលើស្ត្រី វាជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងភាពក្រីក្រ ។

ការសិក្សាបានបង្ហាញផងដែរថា មន្ត្រីមូលដ្ឋានតែងតែប្រឈមនឹងកង្វះខាតព័ត៌មាន កង្វះខាតធនធាន និងអំណាចមិនច្បាស់លាស់ ។ មន្ត្រីមូលដ្ឋានជាញឹកញាប់ នៅក្រោមសម្ពាធពីអ្នកមានអំណាចថ្នាក់លើ ឬមន្ត្រីថ្នាក់ខ្ពស់ ដោយត្រូវបំរើ ឬផ្គាប់ចិត្តពួកគេ ។ អំពើពុករលួយនៅថ្នាក់មូលដ្ឋានមានលក្ខណៈធ្ងន់ធ្ងរ និងជាឧបសគ្គមិនឱ្យអ្នកក្រនិងអ្នកក្រខ្លាំងអាចប្រើប្រាស់សេវាសង្គម ហើយធ្វើឱ្យពួកគេគ្មានសមត្ថភាពបង្កើនជីវភាពរបស់ខ្លួន ។ អ្នកក្រ និងអ្នកក្រខ្លាំង ត្រូវបានផាត់ចេញពីដំណើរការសំរេចចិត្ត ហើយទទួលបានចំលើយតិចតួច ឬគ្មានសោះ ចំពោះសំណើឱ្យមានការដោះស្រាយ ចំពោះការកើតទុក្ខមិនសុខចិត្តរបស់ខ្លួន ។ ពួកគេច្រើនតែជៀសវាងរដ្ឋាភិបាល ដោយពឹងផ្អែកលើអង្គការសង្គមស៊ីវិល និងបណ្តាញសង្គម ឱ្យជួយពួកគេទៅវិញ ។ ការណ៍ដែលអ្នកក្រ និងអ្នកក្រខ្លាំងដែលអាចមើលឃើញថា ស្ថាប័នរដ្ឋាភិបាលមួយចំនួន គឺជាអ្នកបង្កបញ្ហា ជាជាងជាអ្នកដោះស្រាយ គួរតែជាការបារម្ភមួយសំរាប់រដ្ឋាភិបាល និងភាគីអភិវឌ្ឍន៍ដទៃទៀត ។

អំពើពុករលួយ និងការសូកប៉ាន់នៅកំរិតមូលដ្ឋាន ឃើញមានពាសពេញ ។ គ្រួសារធូរធារ និងមធ្យម ត្រូវរ៉ាប់រងដូចគ្នានូវអំពើពុករលួយនៅកំរិតមូលដ្ឋាន ប៉ុន្តែអ្នកក្រ និងអ្នកក្រខ្លាំង ងាយរងគ្រោះជាងគេ ដោយសារឥទ្ធិពលរបស់វា ។ អំពើពុករលួយបានកាត់បន្ថយសមត្ថភាពរបស់អ្នកក្រីក្រ និងអ្នកក្រីក្រណាស់ ក្នុងការកែលំអជីវភាពរបស់ខ្លួន ហើយវាមានចំណែកផ្ទាល់ក្នុងការរុញច្រានមនុស្សជាច្រើនទៀតឱ្យធ្លាក់ក្នុងភាពក្រីក្រ ។

ការសិក្សា PPA ក៏បានបង្ហាញដែរពីក្រុមប្រឹក្សាឃុំជាច្រើនដែលធ្វើការបានយ៉ាងសក្តិសិទ្ធិក្នុងវិស័យនានា ដូចជាហេដ្ឋារចនាសម្ព័ន្ធជនបទដែលមានការកសាងផ្លូវ និងស្ពានជាដើម ។ នៅក្នុងភូមិខ្លះ អ្នកក្រីក្រ ក៏បានទទួលផលចំណេញអំពីកិច្ចសហការរវាងស្ថាប័នអភិបាលកិច្ចនៅក្នុងមូលដ្ឋាន ហើយនិងអង្គការសង្គមស៊ីវិលនានា ក្នុងវិស័យដូចជា ការថែទាំសុខភាព និងឥណទានខ្នាតតូចជាដើម ។ ឧទាហរណ៍ទាំងនេះបង្ហាញថា សមាជិកក្រុមប្រឹក្សាឃុំ និងមន្ត្រីថ្នាក់មូលដ្ឋានជាច្រើននាក់ នៅតែមានការតាំងចិត្តកែលំអស្ថានភាពរបស់អ្នកក្រីក្រ ហើយការកែលំអអភិបាលកិច្ចនៅកំរិតមូលដ្ឋានពិតជាអាចធ្វើបាន ឱ្យតែអ្នកពាក់ព័ន្ធនានា អាចសហប្រតិបត្តិការជាមួយគ្នា ។

## ចំណុចទាក់ទងនឹងការគាក់តែងគោលនយោបាយ

ការសិក្សាពីការវាយតំលៃភាពក្រីក្រដោយមានការចូលរួម (PPA) បានកំណត់វិស័យជាច្រើន ដែលអភិបាលកិច្ចល្អត្រូវមានចាំបាច់ដើម្បីទទួលបានជោគជ័យលើគោលដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។ វិស័យអាទិភាព

សំខាន់ៗជាច្រើនពាក់ព័ន្ធនឹងតំរូវការនូវ ១) ការបែងចែកកាន់តែច្រើន និងកំណត់គោលដៅកាន់តែប្រសើរនៃធាតុចូលសំរាប់អភិវឌ្ឍន៍ជនបទនិងកសិកម្ម ២) ការដាក់បង្ខំអនុវត្តច្បាប់ និងវិធានឱ្យបានខ្លាំងក្លា និងត្រឹមត្រូវ លើការប្រើប្រាស់ និងគ្រប់គ្រងលើធនធានធម្មជាតិ និង ៣) ការបែងចែកកាន់តែច្រើន និងកំណត់គោលដៅកាន់តែប្រសើរលើសេវាកម្មខាងសង្គមកិច្ច ជាពិសេសទឹកស្អាត និងលទ្ធភាពទទួលបានការថែទាំសុខភាពសំរាប់ស្ត្រី ក៏ដូចជាឱកាសអប់រំបន្ត និងការបណ្តុះបណ្តាលវិជ្ជាជីវៈសំរាប់យុវជនគ្រប់គ្នា ដោយយកចិត្តទុកដាក់ជាពិសេសទៅលើស្ត្រី និងក្មេងស្រី ។ វិស័យអាទិភាពផ្សេងទៀតពាក់ព័ន្ធនឹងតំរូវការច្បាប់ និងវិធាន ដែលការពារកម្មករចំណាកស្រុក និងពង្រឹងការអនុវត្តច្បាប់ដើម្បីលើកស្ទួយសុវត្ថិភាពសាធារណៈ ដោយមានការយកចិត្តទុកដាក់ពិសេសចំពោះអំពើហិង្សាទៅលើស្ត្រី និងការប្រើប្រាស់គ្រឿងញៀនក្នុងចំណោមយុវជន ។ ជាទូទៅ គឺមានតំរូវការពិតៗដើម្បីកាត់បន្ថយផលប៉ះពាល់មិនល្អនៃអំពើពុករលួយ និងពង្រឹងភាពទទួលខុសត្រូវនៃអ្នកកសាងគោលនយោបាយថ្នាក់ជាតិ និងមន្ត្រីមូលដ្ឋានចំពោះបញ្ហា និងតំរូវការរបស់អ្នកក្រីក្រ និងអ្នកក្រីក្រខ្លាំង ។ បើគ្មានការពង្រឹងគណនេយ្យភាពវិស័យសាធារណៈទេ កិច្ចខំប្រឹងប្រែងដើម្បីកាត់បន្ថយភាពក្រីក្រ និងពង្រឹងសុខមាលភាពនៃអ្នកក្រ និងអ្នកក្រខ្លាំង នៅតំបន់ទន្លេសាប និងកន្លែងផ្សេងទៀតនឹងពុំមានប្រសិទ្ធិភាពទេ ។

ការផ្តល់សេវាជួយគាំទ្រការអភិវឌ្ឍវិស័យកសិកម្ម និងជនបទមានការដាច់គ្នាជាដុំៗនៅក្នុងភូមិនៃតំបន់សិក្សា PPA ជុំវិញបឹងទន្លេសាប ។ វាអាចនឹងមានប្រសិទ្ធិភាពច្រើនជាងទៅលើសុខមាលភាព និងការកាត់បន្ថយភាពក្រីក្រ បើសិនមានការផ្តល់នូវកញ្ចប់សេវាកម្មបំពេញគ្នាទៅវិញទៅមក រួមមានធារាសាស្ត្រ ប្លង់ដី សេវាផ្សព្វផ្សាយកសិកម្ម និងឥណទានដែលមានការប្រាក់សមរម្យ ជាមួយនឹងសេវាសុខភាពទៅឱ្យអ្នកក្រ ។ ការធ្វើដូចនេះ នឹងបង្កើនតំរូវការប្រឹងប្រែងសំរបសំរួលការធ្វើផែនការ តាមខ្សែបណ្តោយ និងខ្សែទទឹងនៅក្នុងរដ្ឋាភិបាល និងរវាងរដ្ឋាភិបាល ម្ចាស់ជំនួយអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ។ បច្ចុប្បន្ននេះ មានឧទាហរណ៍មួយចំនួននៃការអភិវឌ្ឍសហគមន៍ចំរុះដែលអាចយកជាគំរូសំរាប់ការអនុវត្តទ្រង់ទ្រាយធំនៅកន្លែងផ្សេងទៀត ។

ទោះបីជាគោលនយោបាយថ្នាក់ជាតិ ក្នុងការគ្រប់គ្រងធនធានធម្មជាតិត្រូវបានតាក់តែងឡើង ដើម្បីជំរុញការគ្រប់គ្រងមានចីរភាពលើធនធានទឹក និងដីក្តី ការអនុវត្តនិងការពង្រឹងការអនុវត្តច្បាប់មានកំរិតខ្សោយនៅថ្នាក់មូលដ្ឋាន កំពុងជំរុញឱ្យធនធានធម្មជាតិនៅមូលដ្ឋានមានការរេចរិលយ៉ាងរហ័ស និងធ្វើឱ្យខូចខាតដល់ការគោរពរបស់ប្រជាជនចំពោះស្ថាប័នសាធារណៈ ។ អ្វីដែលត្រូវធ្វើជាបន្ទាន់ គឺការពង្រឹងឱ្យបានកាន់តែខ្លាំង និងស្មើភាពនូវការអនុវត្តច្បាប់ និងវិធានដែលមានស្រាប់នៅក្នុងក្របខ័ណ្ឌគោលនយោបាយសំរាប់គ្រប់គ្រងធនធានធម្មជាតិ ។គេក៏ត្រូវពិចារណាឡើងវិញជាបន្ទាន់ដែរ ពីវិធីសំរាប់គ្រប់គ្រងទំនាស់ ដើម្បីជួយអ្នកក្រីក្រ និងអ្នកក្រីក្រខ្លាំង ឱ្យមានលទ្ធភាពទទួលបានដំណោះស្រាយយុត្តិធម៌ និងមិនលំអៀង ។ តំរូវការនេះពាក់ព័ន្ធទាំងទំនាស់ក្នុងមូលដ្ឋាននៅកំរិតភូមិ ក៏ដូចជាទំនាស់ពាក់ព័ន្ធនឹងអ្នកនៅខាងក្រៅ ដូចជាអ្នកធូរធារ និងអ្នកមានអំណាច ។

គួរមានបទប្បញ្ញត្តិពិសេស ដើម្បីជួយបង្កើនលទ្ធភាពរបស់អ្នកក្រីក្រជាពិសេសស្ត្រី ក្នុងវិស័យសេវា-សង្គមកិច្ច ដូចជាការថែទាំសុខភាពនិងការអប់រំ ។ត្រូវតែបែងចែកជាបន្ទាន់និងច្រើនថែមទៀតនូវថវិកាជាតិសំរាប់វិស័យទឹកស្អាត អនាម័យសាធារណៈ ការថែទាំសុខភាព ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការដឹកជញ្ជូនសាធារណៈ ។ គំរោងធានារ៉ាប់រងសុខភាព សំរាប់អ្នកក្រ និងអ្នកក្រខ្លាំង គួរដំណើរការសាកល្បង ហើយអាហារូបករណ៍សំរាប់កុមារា-កុមារី

ក្នុងគ្រួសារក្រីក្រ គួរត្រូវពង្រីកបន្ថែម ។ ច្រកមួយសំរាប់បញ្ជូនធនធានឱ្យបានច្រើន ទៅដល់ថ្នាក់មូលដ្ឋាន គឺត្រូវបង្កើនទំហំនៃការផ្ទេរថវិកាអន្តរក្រសួងប្រចាំឆ្នាំ ទៅក្នុងមូលនិធិឃុំ-សង្កាត់ ។ ហើយមួយចំណែកនៃការផ្ទេរនេះ ក៏អាចកំណត់មុខសញ្ញាសំរាប់សកម្មភាពអាទិភាពខ្លះៗ ដូចជា ទឹកស្អាតជាដើម ។

អប្រសិទ្ធភាព និងកង្វះភាពយុត្តិធម៌ ពាក់ព័ន្ធនឹងគោលនយោបាយសាធារណៈនៅតំបន់ទន្លេសាប គឺជាបញ្ហាសំខាន់នៃការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ ។ គេត្រូវយកចិត្តទុកដាក់កាន់តែច្រើនថែមទៀត ក្នុងការពង្រឹងស្ថាប័ននានានៅកំរិតមូលដ្ឋានតាមបែបបទណាមួយដែលជួយបំផុស និងបើកលទ្ធភាពឱ្យមានការចូលរួមជាសាធារណៈកាន់តែច្រើន ក្នុងនេះមានទាំងស្ត្រីផង ក្នុងការកាត់បន្ថយអំពើពុករលួយ និងការបង្កើនគណនេយ្យភាព និងការឆ្លើយតបរបស់វិស័យសាធារណៈ ។ ត្រូវចាត់វិធានការជាជំហានៗ ដើម្បីពង្រឹងការពិភាក្សាគ្នារវាងប្រជាពលរដ្ឋ និងស្ថាប័នគ្រប់គ្រងទៅតាមបែបបទដែលជួយកសាងទំនុកចិត្ត និងការគោរពគ្នាទៅវិញទៅមក ។

មានវិធីច្រើនណាស់សំរាប់ដោះស្រាយបញ្ហាខាងលើ ។ តួនាទី ការទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ប៉ូលីសនិងយោធា ចំពោះការគ្រប់គ្រងធនធានធម្មជាតិ និងការអនុវត្តច្បាប់ ត្រូវតែមានការបញ្ជាក់ឱ្យច្បាស់ ។ ការពង្រឹងសិទ្ធិអំណាចក្រុមប្រឹក្សាឃុំក្នុងការរកថវិកាពីប្រភពចំណូលផ្ទាល់ និងការធ្វើផែនការសំរាប់ឆ្លើយតបនឹងតំរូវការក្នុងមូលដ្ឋាន គឺជាសមាសភាគសំខាន់មួយទៀតសំរាប់កសាងស្ថាប័នគ្រប់គ្រងឱ្យមានកំលាំងខ្លាំងនៅថ្នាក់មូលដ្ឋាន ។ ដំណើរការបែបនេះ ត្រូវតែមានផងដែរនូវការងារកសាងសមត្ថភាពឱ្យបានខ្លាំងឡើង សំរាប់មន្ត្រីថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដែលពាក់ព័ន្ធនឹងការធ្វើផែនការ និងការផ្តល់សេវាកម្ម ដើម្បីឆ្លើយតបនឹងតំរូវការរបស់អ្នកក្រ និងអ្នកក្រខ្លាំង ។

ច្បាស់ហើយ វិស័យសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិល សុទ្ធតែមានកំលាំងទាំងអស់គ្នា ។ បញ្ហាចោទចំពោះអ្នកកសាងគោលនយោបាយ និងអ្នកពាក់ព័ន្ធឯទៀតៗនៅក្នុងតំបន់ទន្លេសាប ក៏ដូចជានៅតំបន់ឯទៀតៗក្នុងប្រទេសកម្ពុជា គឺត្រូវរចនារៀបចំ និងពង្រឹងរបៀបរបបសហការគ្នារវាងវិស័យទាំងបីនេះ តាមបែបណាមួយដែលធ្វើឱ្យចំណុចខ្លាំងរបស់វិស័យនីមួយៗ អាចជួយបំពេញឱ្យគ្នាទៅវិញទៅមកបាន ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចដែលអំណោយផលដល់អ្នកក្រ និងមិនបង្កការខូចខាតដល់ប្រព័ន្ធអេកូឡូស៊ី ។

# ជំពូក ២
# ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចប្រទេសកម្ពុជា

សេដ្ឋកិច្ចប្រទេសកម្ពុជា បន្តដំណើរការយ៉ាងល្អក្នុងឆ្នាំ២០០៦ ។ ដោយសារមានកំណើនសេដ្ឋកិច្ចរឹងមាំកាលពីឆ្នាំមុនៗ ផសស ពិតរបស់កម្ពុជា កើនឡើង ១០,៦% ក្នុងឆ្នាំ២០០៦ ដែលជាឆ្នាំទី៣ជាប់ៗគ្នា ដែលមានអត្រាកំណើនជាលេខពីរខ្ទង់ (ក្រាហ្វិក ១) ។ ការកើនឡើង ផសស ភាគច្រើនបានមកពីវិស័យឧស្សាហកម្ម ដែលមានសន្ទុះយ៉ាងខ្លាំងក្នុងអនុវិស័យកាត់ដេរ និងសំណង់ និងពីវិស័យសេវាកម្មដែលមានកំណើនគួរអោយកត់សំគាល់ក្នុងផ្នែកទេសចរណ៍ សេវាកម្មជំនួញអចលនទ្រព្យ ព្រមទាំងសេវាកម្មផ្សេងៗទៀត ។ វិស័យកសិកម្មក៏រួមចំណែកដល់កំណើននេះផងដែរ ប៉ុន្តែក្នុងមួយភាគតូចប៉ុណ្ណោះ ។ ទោះបីយ៉ាងណាក៏ដោយ វិស័យនេះនៅតែដើរតួយ៉ាងសំខាន់ក្នុងការជួយទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជននៅតាមជនបទ ដោយប្រជាជនភាគច្រើននៅតែពឹងផ្អែកលើដំណាំស្រូវដើម្បីចិញ្ចឹមជីវិត ។

*ក្រាហ្វិក ១: កំណើន ផសស ២០០០-២០០៦*




*ប្រភព: វិទ្យាស្ថានជាតិស្ថិតិ ២០០៧*

## ១. វិស័យកសិកម្ម

នៅឆ្នាំ២០០៦ វិស័យកសិកម្មកម្ពុជា រួមចំណែក ២៨% នៃ ផសស និងផ្តល់ការងារបាន ៥៧,៤% ដល់កំលាំងពលកម្មសរុប ។ តំលៃបន្ថែមពិតរបស់វិស័យនេះកើន ៥,៥% និងរួមចំណែក ១,៦% ដល់កំណើន ផសស សរុប នៅឆ្នាំ២០០៦ ធៀបនឹងកំណើន ១៥,៧% និងការរួមចំណែក ៤,៥% ដល់កំណើន ផសស សរុប នៅឆ្នាំ២០០៥ ។ កំណើនយឺត និងការរួមចំណែកតិចជាងមុននេះ បណ្តាលជាសំខាន់មកពី ផលិតកម្មស្រូវដែលកើនលើសធម្មតាជាខ្លាំងក្នុងឆ្នាំ២០០៥ ដោយសារមានភ្លៀងធ្លាក់អំនោយផលណាស់ ។ ជាទូទៅអត្រាកំនើននៃអនុវិស័យដំណាំនៅតែប្រែប្រួលខ្លាំង ដោយកើន

ឡើងដល់កំពូល និងធ្លាក់ចុះដល់បាត ដែលបញ្ជាក់ពីការពឹងផ្អែកយ៉ាងខ្លាំងលើទឹកភ្លៀង និងភាពងាយប៉ះពាល់ដោយកត្តាធាតុអាកាសមិនអំណោយផល ដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម ។ គួរកត់សំគាល់ដែរថា តំលៃបន្ថែម ផសស អាចកើនខ្ពស់ជាងនេះ ប្រសិនបើមានការកែច្នៃផលិតផលកសិកម្មជាច្រើនទៀតនៅក្នុងស្រុក មុនពេលធ្វើការនាំចេញ ។ ការធ្វើចំរុះកម្មដំណាំដាំដុះ ដូចជា ការដាំដំណាំមានតំលៃបន្ថែមខ្ពស់ក្រៅពីការធ្វើស្រែ មាន ដំឡូងឈើ និងពោត ជាដើម ស្របតាមកំណើនតម្រូវការរបស់ប្រទេសជិតខាង និងប្រទេសចិន វាក៏អាចជួយបង្កើនកំរិតប្រាក់ចំណូលបច្ចុប្បន្នរបស់ប្រជាជនកម្ពុជាដែរ ។

សមាសភាគដទៃទៀតនៃវិស័យកសិកម្ម ក៏កើនឡើងគួរអោយកត់សំគាល់ក្នុងអំឡុងពេលដូចគ្នានេះ ។ ប៉ុន្តែផលិតកម្មសត្វចិញ្ចឹម និងបសុបក្សីនៅតែជួបឧបសគ្គនៃការរីករាលដាលនៃជំងឺឆ្លង និងការបន្តអនុវត្តវិធីចិញ្ចឹមសត្វតាមបែបប្រពៃណី ។ ក្នុងអនុវិស័យជលផល ការចិញ្ចឹមត្រីខ្នាតតូច និងចិញ្ចឹមតាមគ្រួសារ កើនឡើងយ៉ាងខ្លាំង ពិសេសក្នុងរយៈពេល ៤ឆ្នាំចុងក្រោយ ។ ការខិតខំបន្ថែមទៀតក្នុងការពង្រឹង និងពង្រីកវារីវប្បកម្ម មិនត្រឹមតែអាចជួយជំរុញបង្កើនប្រាក់ចំណូលគ្រួសារតាមជនបទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចជួយដោះស្រាយបញ្ហាកំណើនប្រជាជន និងការចាប់ត្រីលើសកំរិតទៀតផង ។តំលៃបន្ថែមក្នុងអនុវិស័យព្រៃឈើ ជាទូទៅច្រើនប៉ាន់ស្មានទាប ដោយសារភាពលំបាកក្នុងការគណនាតំលៃឈើដែលកាប់ខុសច្បាប់ និងតំលៃពិតនៃអនុផលព្រៃឈើ ។ ឧទាហរណ៍ ក្រៅពីការរកអុសដុតប្រជាជនជាច្រើនដែលមានជីវភាពក្រីក្រពឹងផ្អែកយ៉ាងខ្លាំងលើអនុផលព្រៃឈើ ដើម្បីរកចំណូលនិងបង្កើនការហូបចុក ។ សំពាធសហគមន៍ ដូចជា ការកាប់យកអុស កសិកម្មផ្លាស់ទី និងការកែប្រែដីជាអចិន្ត្រៃយ៍ ក៏ជាមូលហេតុសំខាន់នៃការបាត់បង់ និងខូចគុណភាពព្រៃឈើដែរ ។ការសិក្សារបស់វិទ្យាស្ថាន CDRI បង្ហាញថា អភិបាលកិច្ចធនធានធម្មជាតិជាបញ្ហាសំខាន់បំផុត និងត្រូវគ្រប់គ្រងឱ្យមានចីរភាពដើម្បីកាត់បន្ថយភាពក្រីក្រ ។[១]

## ២. វិស័យឧស្សាហកម្ម

វិស័យឧស្សាហកម្មរួមចំណែក ២៩% ក្នុង ផសស និងប្រើប្រាស់ប្រហែល ១៤% នៃកំលាំងពលកម្មសរុប ។វិស័យនេះបន្តមានកំនើនយ៉ាងខ្លាំងក្នុងឆ្នាំ២០០៦ ដល់ ១៨,៣% ។ការរួមចំណែករបស់វិស័យនេះដល់កំណើន ផសស សរុប ដែលកើនឡើងពី ៣,៤% ក្នុងឆ្នាំ២០០៥ ដល់ ៤,៩% ឆ្នាំ២០០៦ ឆ្លុះបញ្ចាំងពីការរីកលូតលាស់ ក្នុងផលិតកម្មដែលនាំមុខគេដោយឧស្សាហកម្មកាត់ដេរ និងសំណង់នៅតំបន់ទីក្រុង ។

ផលិតកម្មសំលៀកបំពាក់ និងវាយនភ័ណ្ឌបន្តកើនឡើងជាលំដាប់ ដល់ប្រមាណ ១៣% ក្នុងឆ្នាំ២០០៦ ។ វាជាកត្តាជំរុញដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចចាប់តាំងពីចុងទសវត្សរ៍១៩៩០ ដោយសារមានលក្ខខណ្ឌពាណិជ្ជកម្មអំណោយផលល្អនៃកិច្ចព្រមព្រៀងវាយនភ័ណ្ឌចំរុះ (Multi-Fibre Agreement: MFA) ។ បន្ទាប់ពីកិច្ចព្រមព្រៀង បានបញ្ចប់នៅថ្ងៃទី១មករា២០០៥អ្នកខ្លះបានទាយទុកថាសេដ្ឋកិច្ចកម្ពុជាអាចត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរប៉ុន្តែតួលេខចុងក្រោយបានបដិសេធការប៉ាន់ស្មានទាំងអស់នោះ ។ ការនាំចេញសំលៀកបំពាក់ពីកម្ពុជា ក្រោយពេលចប់ MFA មិនទាន់មាន

[១] អេង នេត្រា និងភីម រុនស៊ីណារិទ្ធិ (២០០៧) "កម្ពុជា: ការពិនិត្យស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ពីឆ្នាំ២០០៧ ដល់ រយៈពេលមធ្យម- សូចនាករសំខាន់ៗនៃកំណើន ការអភិវឌ្ឍ និង វិបុលភាពរួម" ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា ឆ្នាំទី១១ លេខ២

ការប៉ះពាល់អ្វីពីប្រទេសចិនដែលជាមហាយក្សខាងវាយនភ័ណ្ឌដូចការទស្សន៍ទាយនោះទេ ពីព្រោះសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប បានដាក់កំហិតបន្ថែមលើសំលៀកបំពាក់មកពីចិននៅខែឧសភា ២០០៥ ។ ទោះយ៉ាងណាក៏ដោយ កំហិតនេះនឹងផុតកំណត់នៅឆ្នាំ២០០៨ ហើយប្រទេសកម្ពុជាចាំបាច់ត្រូវខិតខំពង្រឹងថែមទៀតនូវកំលាំងប្រកួតប្រជែង និងបង្កើនផលិតភាពក្នុងវិស័យនេះ ។ ម្យ៉ាងទៀត ឧស្សាហកម្មកាត់ដេរនៅកម្ពុជា មានកេរ្តិ៍ឈ្មោះល្អក្នុងការអនុវត្តតាមស្តង់ដារពលកម្ម ដូច្នេះទទួលបានទីផ្សារដោយឡែកមួយ (niche market) ដែលនេះជាខែលជួយការពារកម្ពុជាអំពីការប្រកួតប្រជែងពេញទំហឹងពីចិន ។ ការបង្កើនផលិតភាពពលកម្ម តាមរយៈការផ្តល់ការបណ្តុះបណ្តាល និងប្រាក់បៀវត្សរ៍គ្រប់គ្រាន់សំរាប់ជីវភាពសមរម្យមួយ មានសារៈសំខាន់បំផុត ប្រសិនបើឧស្សាហកម្មកាត់ដេរកម្ពុជាចង់រក្សាបាននូវកំលាំងប្រកួតប្រជែងនេះ ។

អនុវិស័យសាងសង់បានលូតលាស់កាន់តែខ្លាំង នៅច្រើនឆ្នាំកន្លងមកនេះ ។ ការរីកដុះដាលសំណង់ គឺផុសចេញពីស្ថិរភាពសង្គម កំណើនសេដ្ឋកិច្ច សន្ទុះនៃទីផ្សារអចលនទ្រព្យដែលរួមចំណែកដោយវិនិយោគផ្ទាល់ពីបរទេស (FDI) និងការទិញកេងចំណេញ ព្រមទាំងជំនួយជាបន្តពីសហគមន៍អន្តរជាតិសំរាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ។ ការសាងសង់នេះមាន ១/៣ ជាសំណង់សាធារណៈ ដូចជាការកសាងហេដ្ឋារចនាសម្ព័ន្ធជាដើម និង ២/៣ ជាសំណង់ឯកជនដូចជាការសាងសង់និងពង្រីករោងចក្រ សណ្ឋាគារ និងផ្ទះ ។ ប៉ុន្តែមានការបារម្ភពីការវិនិយោគច្រើនលើសលប់លើសំណង់ផ្ទះនៅរាជធានីភ្នំពេញ ដែលមានការសាងសង់ដល់ ៨.០០០ ទៅ ១០.០០០ ផ្ទះល្វែងក្នុងមួយឆ្នាំៗ ។ តំលៃដីខ្ពស់នៃផ្ទះល្វែង និងកំរិតប្រាក់ចំណូលទាបនាបច្ចុប្បន្នរបស់ប្រជាជនកម្ពុជាថ្នាក់មធ្យម បណ្តាលអោយមានភាពស្រពិចស្រពិលថា តើអ្នកណាជាប្រភពតំរូវការផ្ទះល្វែងទាំងនោះ ។ សំនួរមួយផ្សេងទៀតក៏បានចោទឡើងផងដែរថា តើតំលៃផ្ទះដ៏ថ្លៃនេះ ឆ្លុះបញ្ចាំងពីកត្តាមូលដ្ឋាន រឺក៏ជាលទ្ធផលនៃការទិញលក់កេងចំណេញ ។ ប្រសិនបើការឡើងថ្លៃខ្ពស់នេះ បណ្តាលមកពីការឆ្លៀតឱកាសកេងចំណេញ ថ្លៃកើនឡើងខុសពីធម្មតានេះអាចធ្វើអោយរាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព ។ បញ្ហាពាក់ព័ន្ធមួយទៀត គឺអនុវិស័យនេះមិនអាចផ្តល់ប្រាក់ចំណូលគ្រប់គ្រាន់ដល់កម្មករទេ ទោះបីជាវាបានបង្កើតការងារជាច្រើនក៏ដោយ ។

អនុវិស័យផ្សេងៗទៀត ដូចជា រ៉ែ អគ្គិសនី ឧស្ម័ន និងទឹក ក៏មានកំនើនវិជ្ជមានដែរធៀបនឹងឆ្នាំមុន ប៉ុន្តែការរួមចំណែកដល់ការរីកលូតលាស់វិស័យឧស្សាហកម្ម និងកំនើនជារួមនៃ ផសស នៅតិចតួចនៅឡើយ ។ ដោយឡែកខាងរ៉ែ មានសក្តានុពលច្រើនណាស់ ។ ការស្រាវជ្រាវពីដី និងរ៉ែ បង្ហាញថា ប្រទេសកម្ពុជាមានរ៉ែជាច្រើន ដូចជា បុកស៊ីត ត្បូងថ្ម ប្រេងកាត រ៉ែលោហៈនិងមិនមែនលោហៈ និងសំភារៈបានពីកន្លែងជីកយកថ្ម ។ វិនិយោគមួយចំនួនបានធ្វើឡើងសំរាប់រុករករ៉ែទាំងនោះនៅពាសពេញប្រទេសកម្ពុជា ជាពិសេសនៅកំឡុងពេល ២ឆ្នាំចុងក្រោយនេះ ។ ខាងផ្នែកអគ្គិសនីវិញ មានការកែលំអការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ទីក្រុង ប៉ុន្តែ ប្រជាពលរដ្ឋនៅតែជួបការដាច់ចរន្តអគ្គិសនីផ្លាស់វេនគ្នាពិសេសក្នុងរដូវក្តៅ ។ តំលៃអគ្គិសនីខ្ពស់ បើធៀបទៅនឹងប្រទេសថៃ វៀតណាម និងប្រទេសដទៃទៀតក្នុងតំបន់ ហើយវាបានប៉ះពាល់ដល់គ្រប់វិស័យផលិតកម្ម និងបង្កឧបសគ្គដល់វិនិយោគខាងឧស្សាហកម្ម និងកំរិតប្រកួតប្រជែង ។ នៅតំបន់ជនបទកម្ពុជា កន្លែងភាគច្រើនគ្មានអគ្គិសនី កន្លែងខ្លះទៀតមានអគ្គិសនីដែរតែតំលៃខ្ពស់ ។ ដំណោះស្រាយតាមរយៈការនាំចូលអគ្គិសនីពីប្រទេសជិតខាង បានអនុវត្តទៅមុខយ៉ាងយឺត ។

## ៣. វិស័យសេវាកម្ម

វិស័យសេវាកម្មបានរួមចំណែក ៣៨,២% នៃ ផសស និងផ្ដល់ការងារបាន ២៦,០% ដល់កំលាំងពលកម្មសរុប ។ វិស័យនេះ កើនបាន ១០,៣% នៅឆ្នាំ២០០៦ ធៀបនឹងកំនើន ១២,៧% នៅឆ្នាំ២០០៥ ។ គ្រប់អនុវិស័យបានចូលរួមដល់កំណើននេះ ប៉ុន្តែសំខាន់ជាងគេ គឺការរីកដុះដាលខាងជំនួញ សណ្ឋាគារនិងភោជនីយដ្ឋាន សេវាកម្មអចលនទ្រព្យនិងជំនួញ និងសេវាកម្មផ្សេងៗទៀត ។

គួរកត់សំគាល់ថា ទេសចរណ៍នៅកម្ពុជាមិនមានចំណងទាក់ទងខ្លាំងជាមួយវិស័យដទៃទៀតទេ ។ ឧទាហរណ៍ ថ្វីបើមានកំណើនយ៉ាងខ្លាំងក្នុងវិស័យទេសចរណ៍ក៏ដោយ ក៏ផលិតផលកសិកម្មក្នុងស្រុក មិនបានយកទៅប្រើប្រាស់ឱ្យបានទូលំទូលាយនៅតាមភោជនីយដ្ឋាននានាទេ ពីព្រោះការផ្គត់ផ្គង់មិនសូវទៀងទាត់ ហើយគុណភាពក៏ប្រែប្រួលដែរ ។ ការណើសិក្សារបស់ CDRI ក្នុងឆ្នាំ២០០៦ រកឃើញថាសន្ទុះដ៏ខ្លាំងនៃទេសចរណ៍នៅខេត្តសៀមរាប មានឥទ្ធិពលតិចតួចលើការកាត់បន្ថយភាពក្រីក្រតាមភូមិនានាក្នុងខេត្ត ហើយចំណុចគួរអោយភ្ញាក់ផ្អើល គឺសៀមរាបជាខេត្តក្រីក្រជាងគេលំដាប់ទី៣ នៅកម្ពុជា ។ ការបែងចែកដល់អ្នកភូមិ ជាសំខាន់បានមកពីការសាងសង់សណ្ឋាគារ និងផ្ទះជាច្រើនជាជាងការផ្ដល់សេវាអោយដល់ភ្ញៀវទេសចរ ។ មានឱកាសល្អ និងការប្រឹងប្រែងជាច្រើនរបស់អ្នកផ្ដល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីពង្រឹងចំណងទាក់ទងរវាងវិស័យទេសចរណ៍ និងវិស័យឧស្សាហកម្ម និងកសិកម្ម ដូចជាការជំរុញអោយមានការផ្គត់ផ្គង់ក្នុងស្រុកយ៉ាងទៀងទាត់នូវម្ហូបអាហារមានគុណភាពខ្ពស់ជាដើម ។ កំណើនទេសចរណ៍មិនត្រឹមតែផ្ដល់ផលប្រយោជន៍ដល់ អនុវិស័យគមនាគមន៍និងទូរគមនាគមន៍ ហើយនិងសណ្ឋាគារនិងភោជនីយដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្ដល់ប្រយោជន៍ដល់ការធ្វើជំនួញលក់រាយ និងហិរញ្ញប្បទាន ព្រមទាំងសេដ្ឋកិច្ចជារួមផងដែរ ។

វិស័យសេវាកម្ម នៅមានចំណុចអាចកែលំអបានថែមទៀត ។ ការជួយសម្រួលពាណិជ្ជកម្មតាមរយៈការកែលំអហេដ្ឋារចនាសម្ព័ន្ធ ដូចជាការដឹកជញ្ជូន និងទូរគមនាគមន៍ អាចបង្កើតការងារ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋនៅតាមជនបទនានាដែលភាពក្រីក្រនៅតែមានច្រើននៅឡើយ ។ ក្នុងអនុវិស័យហិរញ្ញវត្ថុ គេកត់សំគាល់ថា ចំណាយលើកំចីនៅមានកំរិតខ្ពស់ បើធៀបទៅនឹងប្រទេសជិតខាង ។ ម្យ៉ាងទៀត ការខ្ចីឥណទានជាផ្លូវការ មានការលំបាកជាច្រើន ពីព្រោះប្រជាជនមិនសូវបានដឹងពីរបៀបធ្វើការរបស់ធនាគារ និងចេះប្រើប្រាស់ឥណទានឱ្យមានផលិតភាព ហើយចំនួនធនាគារនៅតាមជនបទក៏មានតិច ។ សេវាកម្ម ពាណិជ្ជកម្ម និងអចលនទ្រព្យ មានដំណើរការល្អ ហើយការរីកដុះដាលសេវាកម្មអចលនទ្រព្យ ជាកត្តាចំបងដែលជំរុញឱ្យមានកំណើនក្នុងអនុវិស័យនេះ ។ ទីផ្សារអចលនទ្រព្យស្ទុះឡើងយ៉ាងខ្ពស់ដល់កំរិតមួយគួរអោយបារម្ភ ក្នុងអំឡុងពីរបីឆ្នាំចុងក្រោយនេះ ។ សេវាកម្មដទៃៗទៀតបានរីកលូតលាស់គួរអោយចាប់អារម្មណ៍ ជាអាទិ៍ សេវាកម្មឯកជនផ្ដល់ការអប់រំនិងថែទាំសុខភាព សេវាកម្មលំហែកំសាន្ត សេវាកម្មសហគមន៍ និងសេវាកម្មបំរើបុគ្គល និងផ្សេងៗ ។

គួរកត់ចំណាំថា ការប៉ាន់ស្មានតំលៃបន្ថែមនៃវិស័យសេវាកម្ម ជួបការលំបាកជាច្រើន ដោយសារវិស័យនេះមួយភាគធំ មានលក្ខណៈមិនផ្លូវការ និងមានទិន្នន័យដែលបានកត់ត្រាទុកតិចតួចណាស់ ។ ការយឺតយ៉ាវក្នុងការផ្សព្វផ្សាយទិន្នន័យរដ្ឋបាល ព្រមទាំងការលំបាកនឹងទទួលបានទិន្នន័យទាំងនោះ ក៏ជះឥទ្ធិពលដល់ការប៉ាន់ស្មានក្នុងគណនីជាតិដែរ ។

## ៤. ការអនុម័តលើការវិនិយោគ

ការអនុម័តលើគំរោងវិនិយោគអាជីវកម្មថ្មីៗ បន្តកើនឡើងខ្លាំងនៅឆ្នាំ២០០៦ ។ យោងទៅតាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) តំលៃនៃគំរោងវិនិយោគសរុបគិតជាទ្រព្យសកម្មជាប់លាប់ មានចំនួន ២.៦៣៣លានដុល្លារនៅឆ្នាំ២០០៦ ដែលកើនឡើងយ៉ាងខ្លាំងធៀបនឹងកំរិត ១.១៦២លានដុល្លារនៅឆ្នាំ២០០៥ ។ ក្នុងឆ្នាំ២០០៦ ទាំងវិនិយោគក្នុងស្រុក និងវិនិយោគផ្ទាល់ពីបរទេស កើនឡើងយ៉ាងខ្លាំងដល់ ១.១៤៥លានដុល្លារ និង ១.៤៨៨លានដុល្លារ ។ ចិននៅតែជាអ្នកវិនិយោគទុននាំមុខគេ (៧៦៣លានដុល្លារ) បន្ទាប់មករុស្ស៊ី (២៧៨លានដុល្លារ) ថៃ (១០២លានដុល្លារ) កូរ៉េខាងត្បូង (៧៩លានដុល្លារ) និងសហរដ្ឋអាមេរិក (៦២លានដុល្លារ) ។ ស្ថិតិ CDC ក៏បង្ហាញដែរថា វិនិយោគធ្វើឡើងភាគច្រើនជាការសាងសង់ ការរុករករ៉ែ កាត់ដេរ ថាមពល និងស៊ីមង់ត៍ ។ ប៉ុន្តែគួរកត់សំគាល់ថា កន្លងមកគំរោងវិនិយោគដែលបានអនុម័ត មិនបានអនុវត្តជាក់ស្តែងទាំងអស់នោះទេ ។

## ៥. ការនាំចេញ និងនាំចូល

ដំណើរការនាំចេញរបស់កម្ពុជា ក្នុងឆ្នាំ២០០៦ មានកំរិតខ្លាំង ដោយកើនឡើង ២២% ធៀបនឹងឆ្នាំមុន ដល់ ៣.៦៩៣លានដុល្លារ ។ ទំនិញនាំចេញច្រើនជាងគេ គឺវាយនភ័ណ្ឌ និងសំលៀកបំពាក់ ដែលមានចំនួន ៨៤% នៃការនាំចេញសរុប ហើយបន្ទាប់មក គឺស្បែកជើង ។ ផលិតផលនាំចេញដទៃទៀត ដែលតំណាងអោយ ១០% នៃការនាំចេញសរុប រួមមាន ត្បូង យានយន្ត គ្រឿងម្ហូបអាហារ ប្លាស្ទិក សត្វ ផលិតផលឈើ និងបន្លែ ។ ក្នុងឆ្នាំ២០០៦ ការនាំចូលរបស់កម្ពុជាកើនឡើងតាមអត្រាមធ្យមប្រចាំឆ្នាំ ២០,៩% ហើយមានតំលៃ ៤.៧៤៩លានដុល្លារ រឺស្មើនឹង ៨០% នៃ ផសស ។ ផលិតផលនាំចូលច្រើនជាងគេ គឺវាយនភ័ណ្ឌ និងសំលៀកបំពាក់ ដែលមានចំនួន ៣១,៥% នៃការនាំចូលសរុប ។ អវត្តមាននៃការផ្គត់ផ្គង់ក្នុងស្រុកដោយសារកង្វះខាតនៃចំណងទាក់ទងខាងដើមខ្សែ ធ្វើអោយមានការនាំចូលប្រភេទទំនិញទាំងនេះ ដែលភាគច្រើនមកពីចិន និងហុងកុង និងត្រូវប្រើជាធាតុចូលសំរាប់ផលិតកម្មកាត់ដេរ ។ ប្រភេទទំនិញនាំចូលសំខាន់ៗផ្សេងទៀត មានដូចជា ឧបករណ៍អគ្គិសនីនិងម៉ាស៊ីន ផលិតផលរ៉ែ គ្រឿងម្ហូបអាហារ យានយន្ត ជីគីមី ប្លាស្ទិក គ្រឿងដែក ម្សៅក្រដាស និងក្រដាស ។

## ៦. ចំណូល និងចំណាយថវិកា

ក្នុងឆ្នាំ២០០៦ ចំណូលថវិកាសរុបមានចំនួន ៣.២៥៩,២ពាន់លានរៀល រឺកើនឡើង ២៤% ធៀបនឹងឆ្នាំ២០០៥ ។ ចំណូលពន្ធជាប្រភពចំបងនៃការប្រមូលចំណូលក្នុងស្រុក ។ ដូចនេះ បញ្ហារចនាសម្ព័ន្ធក្នុងប្រព័ន្ធពន្ធដារ ដូចជាការរួមតូចនៃមូលដ្ឋានពន្ធ និងការចុះខ្សោយនៃរដ្ឋបាលពន្ធ ត្រូវការដំណោះស្រាយកែលំអ ។ រដ្ឋាភិបាល បានបង្ហាញពីការប្តេជ្ញាចិត្តពង្រឹង និងពង្រីកដំណើរការប្រមូលចំណូល តាមរយៈកម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈគ្រប់ជ្រុងជ្រោយមួយ ។ បន្ថែមលើនេះទៀត រាជរដ្ឋាភិបាលបានលើកថា អាចយកពន្ធលើដីមិនប្រើប្រាស់ដែលរួមបញ្ចូលដីគ្រប់ប្រភេទទាំងអស់ លើកលែងតែដីសំរាប់កសិកម្ម និងដីប្រើសំរាប់គោលបំណងសាធារណៈ ដើម្បីធានាឱ្យមានប្រព័ន្ធពន្ធមួយសមស្រប ។

ក្នុងឆ្នាំ២០០៦ ចំណាយថវិកាកើនឡើង ១៩% ដល់ ៤.០៨៣,២ពាន់លានរៀល ក្នុងនេះចំណាយចរន្តកើនឡើង ២០% ដល់ ២.៣៦៦,៦ពាន់លានរៀល និងចំណាយមូលធនកើនឡើង ១៨% ដល់ ១.៧១៦,៧ពាន់លានរៀល ។ចំណាយចរន្ត រួមមានចំណាយលើវិស័យរដ្ឋបាលទូទៅដែលកើន ២០% ដល់ ៤២៥,៩ពាន់លានរៀល ធៀបនឹងឆ្នាំមុន ចំណាយលើវិស័យការពារជាតិនិងសន្តិសុខ កើន ១៥% ដល់ ៥២០,២ពាន់លានរៀល, វិស័យរដ្ឋបាលសេដ្ឋកិច្ចកើន ៣៥% ដល់ ២៤០,៣ពាន់លានរៀល, និងវិស័យរដ្ឋបាលសង្គមកិច្ចកើន ២៤% ដល់ ៩៨៥,៥ពាន់លានរៀល ។ អនុវិស័យអប់រំ និងសុខាភិបាល ដែលស្ថិតក្រោមវិស័យរដ្ឋបាលសង្គមកិច្ច គឺជាខ្ទង់ចំណាយជាអាទិភាពនៅក្នុងកញ្ចប់ថវិការដ្ឋ ។

គួរកត់សំគាល់ថា ក្នុងរយៈពេល ១៥ឆ្នាំ ចុងក្រោយនេះ ចំណាយចរន្តទៅលើវិស័យកសិកម្មមិនទាន់លើសពី ១,៥% នៃចំណាយចរន្តសរុបបើមិនទាន់ច្រើនជាង២,៥% នៃចំណាយសរុបនៅឡើយទេ ។តួលេខនេះជាកំរិតមួយទាបពេកពីព្រោះប្រជាជន ៥៧-៧០% ពឹងផ្អែកជាសំខាន់លើកសិកម្ម ហើយភាគច្រើនមានជីវភាពក្រីក្រ ។ ចំណុចនេះជាមូលហេតុធ្វើអោយកំណើនកសិកម្មអន់ថយជាងវិស័យផ្សេងៗទៀត ហើយទិន្នផលកសិកម្មនៅតែទាបជាងគេក្នុងតំបន់ ។ វិនិយោគលើកសិកម្មអាចបង្កើនប្រាក់ចំណូលដល់កសិករភ្លាមៗ ហើយជាមួយកំណើនប្រាក់ចំណូលនេះ ពួកគាត់អាចមានលទ្ធភាពបញ្ជូនកូនទៅសាលារៀន ។ ផ្ទុយទៅវិញ កសិករក្រីក្រប្រហែលជាគ្មានលទ្ធភាពបញ្ជូនកូនទៅសាលារៀនទេ ទោះបីជាថវិកាខាងអប់រំអាចសាងសង់សាលារៀនបានច្រើនថែមទៀតក៏ដោយ ។

## ៧. អតិផរណា

យោងតាមតួលេខពីវិទ្យាស្ថានជាតិស្ថិតិ (NIS) ក្នុងឆ្នាំ២០០៦ កំរិតថ្លៃជារួមនៅក្រុងភ្នំពេញកើនឡើង ៤,៧% ធៀបនឹងឆ្នាំមុនដល់ ៥,៧% (២០០៥) ។ ថ្លៃទូរគមនាគមន៍ និងដឹកជញ្ជូនកើនឡើង ៩,១% ប៉ុន្តែអត្រាកំណើននេះ នៅទាបជាងឆ្នាំមុន (១១,៤%) ។ ការឡើងថ្លៃទូរគមនាគមន៍ និងដឹកជញ្ជូន បណ្តាលជាសំខាន់មកពីកំណើនថ្លៃប្រេងសាំង និងម៉ាស៊ូត ។ ការឡើងថ្លៃម្ហូបអាហារ និងភេសជ្ជៈ ក៏ជាកត្តាសំខាន់ជំរុញកំណើនថ្លៃទំនិញគ្រប់ប្រភេទ ។ កំណើនថ្លៃម្ហូបអាហារនេះ នាំមុខគេដោយថ្លៃសាច់ ។ ធៀបនឹងឆ្នាំ២០០៥ ថ្លៃម្ហូបអាហារ និងភេសជ្ជៈ កើន ៦,៤% រឺ ២,១% ទាបជាងអត្រាកំណើនពីឆ្នាំមុន ។ ក្រៅពីទំនិញពីរប្រភេទនេះ នៅមានថ្លៃតំហែទាំផ្ទាល់ខ្លួនដែលកើន ៤,៩% ថ្លៃសំលៀកបំពាក់និងស្បែកជើង កើន ៣,៩% ថ្លៃផ្ទះនិងទឹកភ្លើង កើន ២,៥% ។

## ៨. ការងារ

ប្រទេសកម្ពុជា ជាប្រទេសដែលមានកំណើនប្រជាជនខ្ពស់នៅក្នុងពិភពលោក ។ យោងតាមវិទ្យាស្ថានជាតិស្ថិតិ (NIS) ចំនួនប្រជាជនកើនតាមអត្រាប្រចាំឆ្នាំ ៣,៨% ក្នុងទសវត្សរ៍១៩៩០ និង ២,០% ក្នុងអំឡុងឆ្នាំ២០០០-២០០៦ ។ SIDA បានប៉ាន់ស្មានថាកំលាំងពលកម្មសរុបកើនឡើងប្រចាំឆ្នាំគឺ២២១.០០០នាក់រឺ៣,៦% ក្នុងកំឡុងឆ្នាំ១៩៩៨-២០០៤ ហើយគេព្យាករណ៍ថា សន្ទុះនេះនឹងបន្តរហូតដល់ឆ្នាំ២០១០ ដែលជាការដាក់សំពាធលើសេដ្ឋកិច្ចឱ្យបង្កើតឱកាសការងារសំរាប់កំលាំងពលកម្មយុវជនដ៏ច្រើននេះ ។ អត្រាកំលាំងពលកម្មចូលរួមគឺ ៥៧,២% ក្នុងឆ្នាំ២០០៦ ។ ការងារសរុបជាមធ្យមមានចំនួន ៨លាន រឺកើនប្រហែល ២% ធៀបនឹងឆ្នាំ២០០៥ ដែលគ្រាន់តែស្មើនឹងកំណើនប្រជាជនប៉ុណ្ណោះ ។ ចំនួន និងភាគរយប្រជាជនបានការងារធ្វើក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មកើនឡើង រីឯចំនួនប្រជាជនធ្វើការក្នុង

វិស័យកសិកម្មបានថយចុះ ដែលឆ្លុះបញ្ចាំងពីការអភិវឌ្ឍនៃសេដ្ឋកិច្ច ។ក្នុងឆ្នាំ២០០៦វិស័យកសិកម្មរួមចំណែក៥៧,៤% ដល់ការងារសរុប រីឯឧស្សាហកម្ម និងសេវាកម្មរួមចំណែក ១៤,៥% និង ២៨,១% ។

## ៩. សេចក្តីបញ្ចប់ និងទស្សនវិស័យសំរាប់ឆ្នាំ២០០៧

សេដ្ឋកិច្ចកម្ពុជា ទោះបីមានមូលដ្ឋានតូចក្តី បានបន្តកើនឡើងយ៉ាងខ្លាំងក្នុងឆ្នាំ២០០៦ ។ សេដ្ឋកិច្ចរីកលូតលាស់ដោយសារសន្ទុះដ៏ខ្លាំងនៃទេសចរណ៍ និងផលិតកម្មកាត់ដេរ ។ចំណងទាក់ទងរវាងវិស័យទាំងពីរ និងវិស័យផ្សេងៗទៀតនៅមានតិចតួចនៅឡើយ ។ យោងតាមការផ្លាស់ប្តូរគោលនយោបាយគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិក្នុងការនាំចេញវាយនភ័ណ្ឌនិងសំលៀកបំពាក់ ការប្រឹងប្រែងជាបន្តបន្ទាប់ដើម្បីបង្កើនផលិតភាព និងកំរិតប្រកួតប្រជែងលើវិស័យកាត់ដេរ និងធ្វើចំរុះកម្មមុខទំនិញនាំចេញ គឺសំខាន់បំផុតដើម្បីជំរុញកំណើនសេដ្ឋកិច្ចថែមទៀត ។ ប្រទេសកម្ពុជា គួរតែពង្រឹងចំណងទាក់ទងរវាងឧស្សាហកម្មកាត់ដេរនិងទេសចរណ៍ ជាមួយនឹងវិស័យកសិកម្ម តាមរយៈវិនិយោគក្នុងអាជីវកម្មសំរាប់ជួយទ្រទ្រង់ ដូចជា ចំការកប្បាស និងការផ្គត់ផ្គង់បន្លែ និងសាច់ជាដើម ដែលនឹងជួយបង្កើនកំរិតប្រកួតប្រជែង ព្រមទាំងបង្កើតការងារ និងប្រាក់ចំណូលថែមទៀត ។ សក្តានុពលកសិ-ពាណិជ្ជកម្មមួយផ្សេងទៀតគឺ ការដាំដំឡូងឈើដែលមានកំណើនតំរូវការពីប្រទេសចិន ។ ការយករ៉ែក៏ជាសក្តានុពលសំខាន់មួយទៀត ដោយការស្រាវជ្រាវពីដី និងរ៉ែ បានបង្ហាញថា នៅកម្ពុជាមានរ៉ែជាច្រើន ដូចជា បុកស៊ីត ត្បូងថ្ម រ៉ែតន្ទនរឹង រ៉ែលោហៈនិងមិនមែនលោហៈ និងសំភារៈបានពីកន្លែងជីកយកថ្ម ជាបន្ថែមលើការរកឃើញប្រេងកាត និងឧស្ម័នក្នុងឈូងសមុទ្រថៃនាពេលថ្មីៗនេះ ។ ធនធានទាំងនេះមិនទាន់បានស្រាវជ្រាវ និងអភិវឌ្ឍអោយបានទូលំទូលាយនៅឡើយទេ ដោយសារសង្គ្រាម និងជំលោះផ្ទៃក្នុងកាលពីមុន ។

គួរកត់សំគាល់ថា ប្រភពនៃកំណើននៅតែតូចចង្អៀត ទោះបីជាសេដ្ឋកិច្ចមានកំណើនលឿនក៏ដោយ ។ ដូចនេះ សេដ្ឋកិច្ចកម្ពុជា មានហានិភ័យច្រើនដែលពាក់ព័ន្ធនឹងបំរែបំរួលនៃទីផ្សារសកលលោក ។ ដើម្បីកាត់បន្ថយភាពងាយទទួលរងគ្រោះនេះ ត្រូវមានវិនិយោគក្នុងស្រុកកាន់តែច្រើនឡើង ជាពិសេសលើសហគ្រាសធុនតូចនិងមធ្យម(SMEs) ។ ទោះបីសេដ្ឋកិច្ចមានកំណើនខ្លាំងក្នុងទសវត្សរ៍មុនក្តី ប៉ុន្តែចំណងទាក់ទងរវាងកំណើននេះនឹងភាពក្រីក្រនៅមានកំរិតខ្សោយ ហើយបញ្ហាប្រឈម គឺត្រូវធ្វើយ៉ាងណាដើម្បីពង្រឹងចំណងទាក់ទងនេះ ។ ដើម្បីធ្វើអោយកំណើននេះអំណោយផលកាន់តែច្រើនដល់អ្នកក្រីក្រ ត្រូវមានគោលនយោបាយជំរុញការអភិវឌ្ឍកសិកម្មជនបទបានឆាប់រហ័ស និងបង្កើតការងារ ។ គោលនយោបាយទាំងនេះគួររួមបញ្ចូល ការធ្វើចំរុះកម្មកសិកម្មទៅដាំដំណាំណា ដែលមានតំលៃខ្ពស់និងប្រើពលកម្មច្រើន ហើយធ្វើការកែលំអប្រព័ន្ធបញ្ចេញលក់លើទីផ្សារ (Marketing) ព្រមទាំងធ្វើអោយប្រសើរឡើងនូវឧបករណ៍/កន្លែងស្តុកទំនិញ និងបង្កើនលទ្ធភាពរបស់កសិករក្នុងការទទួលបានឥណទាន ។ គោលនយោបាយបង្កើតការងារអាចរួមបញ្ចូលឱកាសការងារបន្ថែមទៀតក្រៅពីការធ្វើស្រែចំការ តាមរយៈការជំរុញសហគ្រាសធុនតូចនិងមធ្យម និងការកែលំអលទ្ធភាពទទួលបានឥណទានសំរាប់សហគ្រាសតូចៗ ។

ផសស រំពឹងថានឹងកើនឡើង ៩,៥% នៅឆ្នាំ២០០៧ ។កំណើននេះ បានមកពីគ្រប់វិស័យ ប៉ុន្តែវាពឹងផ្អែកខ្លាំងលើឧស្សាហកម្មដែលឈានមុខគេដោយការនាំចេញផលិតផលកាត់ដេរ និងលើសេវាកម្មដែលនាំមុខគេដោយទេសចរណ៍ ។ កសិកម្ម រំពឹងថានឹងកើនឡើងបានប្រហែល ៤,៥% ដែលនាំមុខដោយផលដំណាំ និងសត្វចិញ្ចឹម ។ ឧស្សាហកម្ម

រំពឹងថានឹងមានកំណើនត្រឹម១២% ក្នុងនេះផលិតផលវាយនភ័ណ្ឌនិងសំណង់កើនឡើង១៥% រីឯអនុវិស័យដទៃទៀតនឹងកើនឡើងតាមអត្រាកំណើនមធ្យមដែលសំរេចបានក្នុងបួនឆ្នាំចុងក្រោយ ។កំណើនសេវាកម្មរំពឹងថានឹងនៅថេរ ប្រហែល ១0% ក្នុងនេះកត្តាជំរុញចំបងគឺមាន ពាណិជ្ជកម្ម សណ្ឋាគារនិងភោជនីយដ្ឋាន ព្រមទាំងការដឹកជញ្ជូននិងទូរគមនាគមន៏ដែលពាក់ព័ន្ធខ្លាំងទៅនឹងទេសចរណ៏ ។ ពាណិជ្ជកម្មក្រៅប្រទេសកម្ពុជារំពឹងថា កើនឡើងបន្តិចម្តងៗក្នុងឆ្នាំបន្តបន្ទាប់ខាងមុខនេះ និងមានតួនាទីកាន់តែសំខាន់នៅក្នុងសេដ្ឋកិច្ច ។ ការនាំចូលរំពឹងថា នឹងកើនឡើងថែមទៀត ស្របតាមកំណើនតំរូវការដែលជាលទ្ធផលនៃកំណើនប្រជាជន និងសេដ្ឋកិច្ចកំរិតខ្ពស់ ។ ការនាំចេញនឹងកើនឡើង ជាពិសេសផលិតផលសំលៀកបំពាក់ និងវាយនភ័ណ្ឌ ។ ការប្រែប្រួលគោលនយោបាយគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិលើសំលៀកបំពាក់និងវាយនភ័ណ្ឌ ព្រមទាំងការប្រឹងប្រែងជាបន្តបន្ទាប់ដើម្បីបង្កើនផលិតភាព និងកំរិតប្រកួតប្រជែងនៃវិស័យកាត់ដេរ និងការធ្វើចំរុះកម្មទំនិញនាំចេញ ប្រហែលអាចជួយជំរុញថែមទៀតដល់កំណើនសេដ្ឋកិច្ច ។

*សូមមើលឯកសារយោងក្នុងអត្ថបទជាភាសាអង់គ្លេស*

## ជំពូក ៣
## ការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រក្នុងខេត្តតាកែវ: បញ្ហាចោទ ទំនាស់ និងដំណោះស្រាយ

### ១.សេចក្តីផ្តើម

រាជរដ្ឋាភិបាលបានផ្តល់អាទិភាពទៅលើវិស័យធារាសាស្ត្រដោយចាត់ទុកជាកំលាំងមួយសំរាប់រុញច្រានវិស័យកសិកម្ម ។ ទោះបីជាដូច្នេះក៏ដោយ មានដីកសិកម្មត្រឹមតែ ៧% ប៉ុណ្ណោះ ដែលបានទទួលការស្រោចស្រពពេញលេញ ហើយវិស័យធារាសាស្ត្រ បានទទួលការវិនិយោគតិចតួចទៅឡើយពីរដ្ឋ និងឯកជន ។

ដើម្បីលើកកំពស់ការយល់ដឹងពីវិស័យធារាសាស្ត្រ ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើង ដោយមានគោលបំណងដូចតទៅ: ១) បង្ហាញអំពីស្ថានភាពទូទៅនៅក្នុងវិស័យធារាសាស្ត្រ ដោយផ្តោតការសិក្សាទៅលើខេត្តតាកែវ ២) សិក្សាពីការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្របញ្ហានិងទំនាស់ផ្សេងៗដែលកើតមាននិង៣) ស្វែងរកដំណោះស្រាយសំរាប់បញ្ហា និងទំនាស់ទាំងនោះ ។

### ២. វិធីសាស្ត្រ

ការចុះអង្កេតដល់កន្លែង បានធ្វើឡើងនៅប្រព័ន្ធធារាសាស្ត្រចំនួន ៥ (សំពោចក្នុងឃុំចំប៉ី ដងខ្ទមក្នុងឃុំរកាក្រៅ ដើមក្រឡាញ់និងស្វាយខមក្នុងឃុំដូង និងជ្រោយសំពោចក្នុងឃុំបារាយណ៍) ក្នុងខេត្តតាកែវ នៅដើមឆ្នាំ២០០៧ ។ ដើម្បី ប្រមូលទិន្នន័យអំពីប្រវត្តិកសាង និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ក្រុមស្រាវជ្រាវបានធ្វើការពិភាក្សាជាក្រុម និង កិច្ចសំភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលរួមមាន តំណាងក្រុមប្រឹក្សាឃុំ សហគមន៍កសិករប្រើប្រាស់ទឹក (FWUC) គណ:កម្មាធិការ (FWUCC) និងអាជ្ញាធរខេត្ត ។

លើសពីនេះ មានការសំភាសជាមួយគ្រួសារកសិករចំនួន ១១០គ្រួសារ (៥៥គ្រួសារជាអ្នកប្រើប្រាស់ទឹកមកពីប្រព័ន្ធ ធារាសាស្ត្រដងខ្ទម និង ៥៥គ្រួសារទៀតមកពីប្រព័ន្ធធារាសាស្ត្រសំពោច) ។ ការសិក្សាជាមួយគ្រួសារកសិករគឺដើម្បីធ្វើការស្វែងយល់ជាសំខាន់អំពីការលំបាកដែលកសិករជួបប្រទះ និងស្វែងយល់អំពីការវិនិយោគ និងទិន្នផលដែលកសិករទទួលបាន ។

### ៣. លទ្ធផល និងការពិភាក្សា

នៅកម្ពុជា មានប្រព័ន្ធធារាសាស្ត្រជាង ២០០០ ប៉ុន្តែប្រព័ន្ធធារាសាស្ត្រក៏ដូចជាអាងស្តុកទឹកភាគច្រើន ដំណើរការមិនបានល្អទេ ព្រោះតែបច្ចេកទេសកសាងមិនល្អ ព្រមទាំងរងនូវការខូចខាតធ្ងន់ធ្ងរដោយសារសង្គ្រាម និងកង្វះការថែរក្សាអោយបានជិតដល់ ។ដូចគ្នានឹងប្រព័ន្ធធារាសាស្ត្រ ក្នុងខេត្តឯទៀតៗដែរ អាងស្តុកទឹកក្នុងខេត្តតាកែវ បានសាងសង់ឡើងក្នុងសម័យសម្តេចនរោត្តមសីហនុ និងមិនសូវបានទទួលនូវការថែទាំជួសជុលអោយបានល្អនោះទេ ។ ទោះបីប្រព័ន្ធធារាសាស្ត្រមួយចំនួន បានស្តារ និងជួសជុលឡើងវិញក៏ដោយ ក៏នៅតែមានបញ្ហាចោទនៅឡើយ ។ បញ្ហាឃើញមាន

ជាទូទៅគឺ បញ្ហាខាងហិរញ្ញវត្ថុ បន្ទាប់មកការចូលរួមរបស់ប្រជាជន និងបញ្ហាបច្ចេកទេសរបស់សំណង់ប្រព័ន្ធធារាសាស្ត្រ ។

ក្នុងឆ្នាំ១៩៩៤ រដ្ឋាភិបាលបានចាប់ផ្តើមផ្ទេរការទទួលខុសត្រូវផ្នែកប្រតិបត្តិការ និងការថែទាំជួសជុល (O&M) ប្រព័ន្ធធារាសាស្ត្រទៅឱ្យ FWUC ដើម្បីកាត់បន្ថយបន្ទុកការងាររដ្ឋ និងផ្តល់សិទ្ធិឱ្យកសិករធ្វើជាម្ចាស់ ។FWUC ត្រូវបានអនុញ្ញាតឱ្យរកចំណូលពីប្រភពដូចតទៅៈ ១) ការប្រមូលថ្លៃសេវាប្រើប្រាស់ទឹក ២) រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ៣) ប្រាក់ចំណូលពីការធ្វើអាជីវកម្មនេសាទ និង ៤) ប្រាក់ពិន័យ ។ ប៉ុន្តែ ការសិក្សាបានរកឃើញថា FWUC បានជួបការលំបាកក្នុងការរកមូលនិធិឱ្យបានគ្រប់គ្រាន់ ដោយសារគេមិនអាចទទួលការឧបត្ថម្ភពីប្រភពទាំងនោះឡើយ លើកលែងតែចំណូលពីថ្លៃសេវាប្រើប្រាស់ទឹកដែលមានកំរិតនៅឡើយ ។

ប្រព័ន្ធធារាសាស្ត្រទាំងអស់ ពឹងផ្អែកជាសំខាន់ទៅលើវិភាគទានពីសមាជិក FWUC តាមរយៈការបង់ថ្លៃសេវាប្រើប្រាស់ទឹក ប៉ុន្តែគ្មានប្រព័ន្ធណាមួយបានទទួលការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីរដ្ឋដូចដែលមាននៅក្នុងប្រកាសលេខ ៣០៦ ឡើយ ។ ប៉ុន្តែថ្លៃសេវាប្រើប្រាស់ទឹក គឺអាចទូទាត់ចំណាយបានត្រឹមតែមួយភាគបីនៃចំណាយ O&M ប៉ុណ្ណោះ ។ ទំលាប់ប្រើប្រាស់ទឹកដោយឥតបង់ថ្លៃ ជាមូលហេតុមួយនៃការប្រមូលថ្លៃសេវាប្រើប្រាស់ទឹកបានតិចតួច ។ ការប្រមូលថ្លៃសេវាបានតិចបែបនេះ ក៏បណ្តាលមកពីអ្នកទទួលបន្ទុកប្រមូលមានការជាប់រវល់មមាញឹកនៅក្នុងសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេ ។ សំរាប់គ្រួសារក្រីក្រ ច្រើនតែស្ទាក់ស្ទើរមិនចង់បង់ប្រាក់ រឺមិនមានលទ្ធភាពបង់ថ្លៃសេវា ។ រីឯអ្នកប្រើប្រាស់ទឹកដែលមានចំណេះដឹង និងអំណាចមួយចំនួន ពួកគេព្យាយាមគេចវេសមិនបង់ថ្លៃសេវាតាមមធ្យោបាយផ្សេងៗ ។ ថវិការកបានតិចតួចបែបនេះ បានជះឥទ្ធិពលដល់សមត្ថភាពនៃ FWUC ក្នុងការបំពេញមុខងារ O&M ។

ក្នុងការអនុវត្តជាក់ស្តែង ថ្លៃសេវាប្រើប្រាស់ទឹក គឺគណនាឡើងដោយផ្អែកលើទិន្នផល ។ ការមិនយកថ្លៃទឹកទៅតាមបរិមាណទឹកប្រើប្រាស់ ជាហេតុផលមួយដែលកសិករប្រើប្រាស់ទឹកច្រើនហួសប្រមាណ ។ក្រៅពីបញ្ហាវិភាគទានហិរញ្ញវត្ថុ ប្រជាជនកសិករមិនបានចូលរួមជាដុំកំភួនទេនៅក្នុង O&M លើកលែងតែប្រឡាយទឹកស្ថិតនៅជិតដីរបស់ពួកគេ ។ ដោយគ្មានការថែទាំជួសជុលជិតដល់ ប្រព័ន្ធធារាសាស្ត្រទាំងនោះ ស្ថិតក្នុងភាពងាយខូចខាតជានិច្ច ។

ដោយគ្មានការស្តារជួសជុល និងថែទាំ អាងស្តុកទឹកកាន់តែរាក់ទៅៗ ហើយទំនប់ទឹកក៏កាន់តែចុះខ្សោយ ទំនប់អាចទប់ទឹកបានតិចជាងការរំពឹងទុក ។ ចំណែកឯប្រឡាយក៏រាក់ទៅៗ ដែលជាញឹកញាប់បណ្តាលមកពី ការរចនាសាងសង់មិនល្អ និងការវាតយកដីប្រឡាយពីសំណាក់កសិករ ដែលការណ៍នេះបានបង្កនូវការលំបាកដល់ការគ្រប់គ្រង និងបែងចែកទឹកអោយមានប្រសិទ្ធភាព ។ លើសពីនេះទៀត ទ្វារទឹកក៏ចាស់ និងមិនអាចបិទបើកបានស្រួលឡើយ ដូច្នេះជួនកាលកសិករក៏គាស់បំបែកទ្វារទឹក ដើម្បីយកទឹកប្រើ ។

កង្វះខាតការចូលរួមថែរក្សាពីសំណាក់ប្រជាកសិករ បណ្តាលមកពីការណ៍ដែល FWUC មិនត្រូវបានបង្កើតចេញពីគំនិតផ្តួចផ្តើមនៅមូលដ្ឋាន ប៉ុន្តែកើតឡើងដោយការជំរុញពីខាងក្រៅ ។ ប្រព័ន្ធធារាសាស្ត្រមួយចំនួន មិនបានជ្រើសរើសអ្នកដឹកនាំ ដែលមានសមត្ថភាពសមស្របទេ ហើយរឿងនេះនាំឱ្យមានការចូលរួមតិចតួច ពីសមាជិកដែលមិនសូវពេញចិត្តចំពោះអ្នកដឹកនាំរបស់គេ ។ គ្រួសារកសិករធូរធារមិនសូវបានចូលរួម ដោយសារពួកគេ មានប្រភពចំណូលច្រើនមុខ ។ អាស្រ័យហេតុនេះ តំរូវអោយមានអ្នកដឹកនាំខ្លាំង ដើម្បីចលនាធនធាននៅមូលដ្ឋាន ។

ជាទូទៅ ប្រជាជនតែងយល់ថា ប្រធានគួរតែជាបុរស ដោយហេតុផលមួយផ្អែកថា វាជាការងារធ្ងន់ ត្រូវចេញពីផ្ទះយូរម៉ោង និងបញ្ហាសុវត្ថិភាព ។ ការបោះឆ្នោតជ្រើសរើស និងលក្ខណៈវិនិច្ឆ័យដទៃទៀត គួរតែមានភាពបត់បែន

ដើម្បីទទួលបានការមូលមតិពីប្រជាជនមូលដ្ឋាន ។ ប្រជាជនតែងមានទំនុកចិត្តលើអ្នកមានការអប់រំខ្ពស់ ហើយក៏ចង់បានមនុស្សមានការប្តេជ្ញាចិត្តខ្ពស់ អាកប្បកិរិយាល្អ និងមានទំនាក់ទំនងល្អជាមួយសហគមន៍ ហើយធ្លាប់ធ្វើការបានសំរេចលទ្ធផលល្អកន្លងមក ។

បញ្ហាខាងស្ថាប័នរបស់ FWUC រួមមាន បញ្ហាហិរញ្ញវត្ថុ កង្វះខាតការដាក់អនុវត្តច្បាប់ សមត្ថភាពខ្សោយរបស់ស្ថាប័ន និងកង្វះខាតគ្រឿងលើកទឹកចិត្ត ។ ទំនប់ទឹកទាំងប្រាំនៅតាកែវនេះ បានស្នើសុំដូចគ្នានូវការគាំទ្រដល់ការកសាងសមត្ថភាព និងការពង្រឹងស្ថាប័ន ។ ទោះបីជា FWUCC បានទទួលការបណ្តុះបណ្តាលមួយចំនួនពីមន្ទីរធនធានទឹក ប៉ុន្តែវាមិនគ្រប់គ្រាន់ទេ ពីព្រោះគ្មានការពិនិត្យតាមដានបន្តទៀត ។

ការរំលោភបំពានធ្ងន់ធ្ងរ គឺការពង្រីកដីកសិកម្មដោយពង្រីកវាចូលផ្ទៃដីប្រឡាយទឹក ។ កសិករមិនអាចដោះស្រាយបញ្ហានេះដោយខ្លួនឯងបានទេ ហើយគេក៏រង់ចាំអន្តរាគមន៍ពីថ្នាក់លើ ។ កន្លងមកគេកំរឃើញមានវិធានការដោះស្រាយបណ្តឹងទាំងនោះណាស់ ហើយបើមានក៏យឺតយ៉ាវដែរ ។ យោងតាមលក្ខន្តិកៈ ការរំលោភត្រូវទទួលការពិន័យ ប៉ុន្តែជាក់ស្តែង FWUCC បែរជានៅស្ងៀមចំពោះការរំលោភបំពានទាំងឡាយ ពីព្រោះជាញឹកញាប់ ពួកគេមិនអាចដោះស្រាយបញ្ហាទាំងនោះ ដោយគ្មានការគាំទ្រពីក្រុមប្រឹក្សាឃុំនោះទេ និងពីព្រោះពួកគេខ្លាចការសងសឹក ។

កង្វះខាតទឹក គឺជាដើមហេតុថ្មីនៃទំនាស់ ដោយទឹកនៅក្នុងអាងស្តុកមានកំណត់ ការពង្រីកផ្ទៃដីដាំដុះបានបង្កើនការប្រកួតប្រជែងដើម្បីបានទឹកស្រោចស្រព ។ បញ្ហាប្រឈមមួយទៀត គឺជាការប្រើប្រាស់ទឹកដោយអប្រសិទ្ធភាព និង អសមធម៌ ។ ជាញឹកញាប់ ទំនាស់កើតឡើងទាក់ទិននឹងបញ្ហាបែងចែកទឹក រវាងកសិករនៅខ្សែទឹកខាងលើ និងកសិករនៅខ្សែទឹកខាងក្រោម ។ ទំនាស់ក៏កើតឡើងដោយសារការដាំដុះនៅក្នុងអាងស្តុកទឹក ពីព្រោះកសិករធ្វើស្រែនៅក្នុងអាងស្តុកចង់ឱ្យមានទឹកតិចមុនពេលធ្វើស្រែប្រាំង ចំណែកឯកសិករនៅខាងក្រៅ ចង់ស្តុកទឹកទុករហូតដល់ចុងរដូវប្រាំង ។ ជួនកាលក៏មានទំនាស់រវាងសហគមន៍នេសាទ ជាមួយកសិករផងដែរ ដែលជាទូទៅច្រើនទាក់ទិននឹងការបង្ហូរទឹកចេញក្រៅអាង ។

នៅកន្លែងដែលមានប្រព័ន្ធធារាសាស្ត្រធំអាចស្រោចស្រពបានច្រើនភូមិ បញ្ហាដែលកើតមាន ច្រើនទាក់ទងនឹងទីតាំងនៃទ្វារទឹក និងទីតាំងនៃអ្នកចាត់ចែងទ្វារទឹកនោះ ។ អ្នកចាត់ចែងទឹកជួនកាលព្យាយាមការពារប្រយោជន៍កសិករក្នុងភូមិរបស់ខ្លួន ដោយមិនសូវគិតពីកសិករក្នុងភូមិដទៃទៀត ។ ជារឿយៗ ភូមិផ្សេងៗគ្នាពិបាកមានការឯកភាពគ្នាលើការបង្ហូរ និងការបែងចែកទឹកណាស់ ជាពិសេសពេលដែលមានទឹកមិនគ្រាប់គ្រាន់ ។ ការយោគយល់គ្នា ទៅវិញទៅមកក៏នៅមានតិចតួច ហើយអ្នកប្រើប្រាស់មួយចំនួនអាត្មានិយម ហើយមិនសូវ យកទុកដាក់ចំពោះសកម្មភាពរួមទេ ។

វិភាគទានហិរញ្ញវត្ថុប្រហែលប្រមូលបានច្រើនជាងនេះ បើសិនមានការពន្យល់ក្បោះក្បាយពីសារៈសំខាន់នៃថ្លៃសេវាប្រើប្រាស់ទឹកដល់កសិករ ប្រាក់កំរៃមានភាពយុត្តិធម៌សំរាប់ក្រុមផ្សេងៗ ហើយអ្នកប្រមូលថ្លៃប្រើប្រាស់ទឹក ចុះប្រមូលប្រាក់ភ្លាមៗក្រោយពេលច្រូតកាត់ ។ FWUC និងអាជ្ញាធរឃុំមានការងារជាប់ទាក់ទងគ្នាច្រើន និងបំពេញអោយគ្នាទៅវិញទៅមក ។ តាំងពីបានបង្កើត FWUC មក ពួកអ្នកភូមិកំពុងឈានទៅធ្វើការដោះស្រាយបញ្ហាជាសមូហភាព និងតាមរយៈតំណាងក្នុង FWUCC របស់ខ្លួន មុនពេលនាំគ្នាទៅរកថ្នាក់លើអោយដោះស្រាយដែលការណ៍នេះបង្ហាញអំពីរបៀបនៃការដោយស្រាយទំនាស់ដែលគេមានពីមុន ។

ជារឿយៗ ក្រុមប្រឹក្សាឃុំ ដើរតួនាទីសំខាន់ ក្នុងការគាំទ្រ FWUC ដូចជា ការគាំទ្រខាងផ្លូវស្មារតី ការជួយពិនិត្យដោះស្រាយទំនាស់ទឹក ហើយនិងការស្វែងរកជំនួយពីអ្នកខាងក្រៅ ។ចំណងទាក់ទងជាមួយអ្នកដឹកនាំដែលមានការគាំទ្រ

ពីរដ្ឋបាលថ្នាក់ខ្ពស់ គឺជាជំនួយមួយធំសំរាប់កិច្ចដំណើរការ FWUC ។ ប៉ុន្តែ ក្រុមប្រឹក្សាឃុំមិនដើរតួនាទី ជាអ្នកជួយទ្រទ្រង់ខ្លាំងក្លាក្នុងបញ្ហាទំនាស់ទេ ពីព្រោះពួកគេចង់រក្សាប្រជាប្រិយ៍ភាពជាមួយប្រជាពលរដ្ឋ ។ ការសិក្សាបានបង្ហាញថា ជួនកាលមានការអន្តរាគមន៍ពីខាងក្រៅ ហើយការអន្តរាគមន៍ទៅលើបញ្ហាទំនាស់ភាគច្រើន មានលក្ខណៈបណ្តោះអាសន្ន និងនយោបាយ ។

ការសិក្សាបង្ហាញអោយឃើញថា គ្រួសារ ៩៦% នៅដងខ្វម និង ៨៦% នៅសំពោច បានពេញចិត្តនឹងទង្វើរបស់ FWUCC ។ ពិន្ទុជាមធ្យមគឺ ៧,១៦ នៅដងខ្វម ដែលមាន ០,៥៣ ខ្ពស់ជាងពិន្ទុនៅសំពោច ។ ពិន្ទុនៅដងខ្វមខ្ពស់ជាខ្លាំងជាងសំពោច ក្នុងចំណុចតម្លាភាពខាងហិរញ្ញវត្ថុ ការធ្វើផែនការនិងគំរោងថវិកា និងទំនាក់ទំនងខាងក្រៅ ។ ទោះជាយ៉ាងនេះក្តី កសិករនៅក្នុងតំបន់ទាំងពីរ បានអោយពិន្ទុទាបសំរាប់តម្លាភាពខាងហិរញ្ញវត្ថុ ។

## ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ប្រព័ន្ធធារាសាស្រ្តជាច្រើនមានការរចនារៀបចំមិនសូវល្អ ហើយការថែទាំក៏មិនបានគ្រាប់គ្រាន់ ។ តំបន់ខាងក្រោមមានទឹកច្រើនពេកនៅដើមរដូវប្រាំង និងមិនសូវបានទទួលនូវការថែរក្សាទេ ដែលការណ៍នេះផ្ទុយគ្នាពីតំបន់ខាងលើ ។ នៅខេត្តតាកែវ បញ្ហាទាំងឡាយទាក់ទងជាសំខាន់ទៅនឹងកង្វះខាតហិរញ្ញវត្ថុ ការចូលរួមតិចពីប្រជាជន និងការរចនារៀបចំខាងបច្ចេកទេស ។ កត្តាមិនល្អពីរយ៉ាងទៀតគឺ ការជ្រើសរើសអ្នកដឹកនាំមិនសមស្រប ព្រមទាំងសមត្ថភាពខាងស្ថាប័ន និងការពង្រឹងអនុវត្តន៍ច្បាប់នៅទន់ខ្សោយ ។

ទំនាស់ជាញឹកញាប់កើតឡើងរវាងអ្នកទទួលផលប្រភេទដូចគ្នា ដូចជា កសិករធ្វើស្រែជាដើម ដែលទំនាស់ជាទូទៅច្រើនផុសចេញពីការផ្គត់ផ្គង់ និងបែងចែកទឹកមិនគ្រប់គ្រាន់ ។ ទំនាស់ក៏កើតមានឡើងផងដែរ រវាងអ្នកធ្វើស្រែនឹងអ្នកនេសាទ ។ ការដោះស្រាយទំនាស់ មានយន្តការកាន់ប្រសើរហើយ ប៉ុន្តែនៅមានលក្ខណៈបណ្តោះអាសន្ន និងនយោបាយនៅឡើយ ។

FWUC ត្រូវការការកសាងសមត្ថភាព និងការគាំទ្រខាងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីអាចធានាឱ្យមាន O&M ជាទៀងទាត់ឡើង ។ យន្តការសំរាប់ពិនិត្យតាមដាន វាយតំលៃ និងដាក់ពិន័យ ទាក់ទិននឹងការទូទាត់ថ្លៃសេវាប្រើប្រាស់ទឹក ត្រូវតែបង្កើតឡើង ។ នៅពេលដែល FWUC អាចប្រមូលធនធាននៅមូលដ្ឋាន ការជួយទ្រទ្រង់ខាងហិរញ្ញវត្ថុ គួរតែថយចុះជាបណ្តើរៗ ។ ការទូទាត់ប្រាក់កំរៃនៃការចូលរួមជាទៀងទាត់នៅក្នុង O&M គួរតែកំណត់ឡើងដោយប្រជាជនក្នុងមូលដ្ឋានដោយផ្អែកទៅលើគុណភាព និងទំហំការងារ ។ សមត្ថភាពរបស់ FWUC ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងដោះស្រាយទំនាស់ ត្រូវតែពង្រឹងថែមទៀត ។

*សូមមើលឯកសារយោងក្នុងអត្ថបទជាភាសាអង់គ្លេស*

# ជំពូក ៤
# កត្តាកំណត់ការចូលរួមក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ

## ១. សេចក្តីផ្តើម

នៅក្នុងផ្នត់គំនិតរបស់ប្រជាកសិករខ្មែរភាគច្រើន ទឹកគឺជាប្រភពបញ្ហាប្រឈមជារៀងរាល់ឆ្នាំ ។ តើនឹងមានភ្លៀងធ្លាក់នៅពេលណា ដើម្បីយើងអាចចាប់ផ្តើមដាំដុះបាន? តើនឹងមានទឹកភ្លៀងធ្លាក់គ្រប់គ្រាន់ឬទេ? ឬក៏វានឹងមានទឹកភ្លៀងច្រើនពេក? ចុះនៅខែបន្តបន្ទាប់ទៀតយ៉ាងម៉េចដែរ? ទាំងអស់នេះគឺជាក្តីបារម្ភរបស់ប្រជាជន រហូតដល់ពេលបានប្រមូលផលរួចរាល់ ព្រោះថាពួកគេគ្មានដំណោះស្រាយជាមួយនឹងបញ្ហាធម្មជាតិទាំងនោះទេ ។ កសិកម្មដែលពឹងផ្អែកលើធម្មជាតិនេះ តែងតែផ្តល់ផលតិចជាងការរំពឹងទុក ។ គេដឹងជាទូទៅថា ជីវភាពកសិករខ្មែរនៅក្រខ្សត់ ដោយសារគ្មានប្រព័ន្ធផ្គត់ផ្គង់ទឹកដែលអាចគ្រប់គ្រងបាន (ស៊ូម៉ាត្រា និងដារ៉ាវី ២០០៧) ។

ប្រព័ន្ធធារាសាស្ត្រ គឺជាដំណោះស្រាយដែលអាចផ្តល់ទំនុកចិត្ត ដល់ការដាំដុះស្រូវវស្សា ។ កសិករអាចប្រាកដថាមានទឹកនៅក្នុងវាលស្រែ ដើម្បីធ្វើការដាំដុះបាន ដោយមិនចាំបាច់ពឹងលើរបបទឹកភ្លៀងទេ ។ កសិករថែមទាំងអាចគ្រប់គ្រងការផ្គត់ផ្គង់ទឹកទាំងស្រុងបានទៀតផង ។ លើសពីនេះ ប្រព័ន្ធធារាសាស្ត្រ អាចធ្វើឱ្យកសិករបង្កើនការដាំដុះផលដំណាំរបស់ខ្លួន ពីមួយដង ទៅពីរដងក្នុងមួយឆ្នាំ ទាំងនៅរដូវប្រាំង និងរដូវវស្សា ។

ប៉ុន្តែសំនួរចោទសួរថា តើប្រព័ន្ធធារាសាស្ត្រ អាចផ្តល់ទំនុកចិត្តដល់កសិករឬទេ? បើយោងតាមទ្រឹស្តី ប្រព័ន្ធធារាសាស្ត្រត្រូវតែសាងសង់ឡើង ដើម្បីបំរើតម្រូវការរបស់កសិករ ដូច្នេះប្រជាកសិករមានសេចក្តីរំភើបរីករាយជាមួយនឹងការសាងសង់នេះជាខ្លាំង ព្រោះពួកគេសង្ឃឹមថា នឹងមានទឹកគ្រប់គ្រាន់ដើម្បីប្រើប្រាស់ ដែលកាន់តែសង្កត់ធ្ងន់ថា "ធារាសាស្ត្រទឹក គឺជាប្រភពនៃទ្រព្យសម្បត្តិរបស់ប្រជាជន"។ ប៉ុន្តែកសិករខ្លះ ដូចជាគ្មានការយកចិត្តទុកដាក់ទាល់តែសោះ ។ បើតាមអង្កេតជាក់ស្តែងបង្ហាញថា ប្រព័ន្ធធារាសាស្ត្រដែលមានហើយនោះ គឺពុំសូវមានការចូលរួមប្រើប្រាស់ច្រើនប៉ុន្មានទេ ។

## ២. ការសិក្សាទ្រឹស្តី

គំរោងអភិវឌ្ឍន៍ជាច្រើនមកហើយបានទទួលបរាជ័យក្នុងការលើកស្ទួយជីវភាពប្រជាជនឱ្យចាកផុតពីភាពក្រីក្រ ។ មានមតិអះអាងថា គំរោងទាំងនោះបរាជ័យ គឺដោយសារគ្មានការចូលរួមពីប្រជាជន និងដោយយល់ឃើញថាពួកគេ គ្មានចំណែកជាម្ចាស់ (Ackerman 2004) ។ ម្ចាស់គម្រោងសង្ឃឹមថា ការសាងសង់ប្រព័ន្ធធារាសាស្ត្រក្នុងតំបន់មួយ ធ្វើឱ្យប្រជាជននៅទីនោះ អាចទាញយកផលប្រយោជន៍ពីវា ប៉ុន្តែទន្ទឹមនោះក៏ជួយថែទាំវាផងដែរ ។ ការសន្និដ្ឋាននេះ ផ្អែកលើការយល់ឃើញថា ប្រជាជនតែងតែរីករាយនឹងអ្វីគ្រប់យ៉ាងដែលគេផ្តល់ឱ្យ ។ គំនិតមួយបានលើកឡើងថា ប្រជាជននឹង

មានចំណាប់អារម្មណ៍នឹងគំរោងអភិវឌ្ឍន៍ទាំងនោះ ប្រសិនបើពួកគេមានអារម្មណ៍ថា ពួកគេគឺជាចំណែកដ៏សំខាន់មួយនៃគម្រោងអភិវឌ្ឍន៍ ឬក៏គម្រោងនោះជារបស់ពួកគេ (Moote et al. 1997) ។ ភាពខុសគ្នានៃគម្រោងដែលមានចីរភាព និងមិនមាននោះ គឺផ្អែកទៅលើកម្រិតនៃការចូលរួមរបស់ប្រជាពលរដ្ឋ ដែលប្រើពាក្យថា "ការចូលរួម" ។ ការសិក្សាមួយបានបង្ហាញថា កង្វះខាតការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាកត្តាដែលនាំឱ្យគម្រោងប្រព័ន្ធធារាសាស្ត្រគ្រប់គ្រងទឹកនៅអាស៊ីទទួលបរាជ័យ (Easter 2000) ។

ការឱ្យនិយមន័យនៃពាក្យ "ការចូលរួម" ប្រែប្រួលទៅតាមសេដ្ឋកិច្ច សង្គម នយោបាយ និងវប្បធម៌របស់អ្នកឱ្យនិយមន័យ ។ កាលពីឆ្នាំ១៩៧៥ អង្គការសហប្រជាជាតិឱ្យនិយមន័យពាក្យនេះថា "គឺការចូលរួមក្នុងកិច្ចការអភិវឌ្ឍន៍ចែករំលែកផលប្រយោជន៍ដោយសមធម៌ និងចូលរួមក្នុងការសំរេចចិត្ត" (Chandrapatya et al. 2007) ។ អ្នកផ្សេងទៀតយល់ថា វាជាការចូលរួមក្នុងការវិនិច្ឆ័យបញ្ហា ការធ្វើគម្រោង និងការអនុវត្តគម្រោង (German 2007) ។ ប៉ុន្តែប្រជាពលរដ្ឋ បែរជាយល់ច្រលំថា ពាក្យនេះមានន័យថា "ការចូលរួមប្រជុំទៅវិញ" (Rusten et al. 2004) ។

## អត្ថប្រយោជន៍នៃការចូលរួមរបស់ប្រជាពលរដ្ឋ

លោក Arnstein (1969) បានបែងចែកការចូលរួមនេះ ជា ៤ កម្រិតក្នុងគម្រោងអភិឌ្ឍន៍:

- ភាពជាម្ចាស់
- ភាពជាដៃគូ
- ភាពជាទីប្រឹក្សា
- ភាពជាអ្នកផ្តល់ព័ត៌មាន

ចំពោះភាពជាម្ចាស់ និងភាពជាដៃគូ គឺជាការចូលរួមដែលមានប្រាកដប្រជា ដែលជាចំណែកស្នូលនៃគម្រោងអភិវឌ្ឍន៍ ។ គេយល់ឃើញថា ការចូលរួមបែបនេះ អាចធ្វើឱ្យអភិបាលកិច្ចធនធានទឹកមានប្រសិទ្ធភាព (Solanes and Villaeral 1999) ។ ក្នុងន័យនេះ ការចូលរួមផ្តល់ឱកាសឱ្យប្រជាជន នាំយកនូវចំណេះដឹងមូលដ្ឋាន របៀបរបបការងារ និងប្រពៃណីរបស់ពួកគេ បញ្ចូលទៅក្នុងការធ្វើផែនការដែលជាគន្លឹះសំខាន់ ក្នុងការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋផ្ទាល់ ព្រមទាំងផ្តល់នូវចំណេះដឹង និងបច្ចេកទេសប្រចាំថ្ងៃ ដើម្បីបង្កើនប្រសិទ្ធភាពគម្រោង (Sinath 2001; Johnson et al. 2003; Narain 2006) ។ ការចូលរួម គឺជាកត្តាដែលនាំឱ្យប្រជាជនរួបរួមគ្នា ដើម្បីពិភាក្សាវែកញែក និងដោះស្រាយបញ្ហាដែលពួកគេជួបប្រទះផ្ទាល់ ។ ការចូលរួមរបស់ប្រជាពលរដ្ឋ ជំរុញការឈានទៅរកដំណោះស្រាយដែលមានប្រសិទ្ធភាព ព្រោះថាគ្រប់ៗគ្នាបានចូលរួម និងបានបង្ហាញគំនិត (Rahnema 1992) ។ សំរាប់គោលនយោបាយ ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាការចូលរួមបង្កើតគោលនយោបាយ ដែលធ្វើឱ្យពួកគេយល់កាន់តែច្បាស់ និងទទួលយកគោលនយោបាយនោះ ។ ការចូលរួមធ្វើឱ្យមានការបញ្ចេញមតិ និងជំរុញឱ្យគម្រោងអភិវឌ្ឍន៍ អាចឆ្លើយតបនឹងតម្រូវការគ្រប់ៗគ្នាបាន ព្រោះថាអ្នកទន់ខ្សោយ និងអ្នកតូចតាចអាចបញ្ចេញមតិ និងគំនិតរបស់ខ្លួនបាន (Arnstein1969) ។

## ឧបសគ្គនៃការចូលរួមជាក់ស្តែង

តើការចូលរួមពិតជាអាចដោះស្រាយបញ្ហាអភិវឌ្ឍន៍មែនទេ? គំនិតសំខាន់គួរពិចារណាពីរគឺ ទីមួយ ការសង្កត់ធ្ងន់ទៅលើឥទ្ធិពលនៃការសំរេចចិត្តនៃអ្នកមានអំណាច ដែលគ្រាន់តែបង្កើតពាក្យ ការចូលរួមនេះ ដើម្បីប្រមូលជំនួយឱ្យស្របច្បាប់ (German 2007; Rahnema 1992) ។ វាគ្រាន់តែជាការឆ្លើយតបនឹងការចំនាយរបស់គម្រោង (Rahnema 1992) ។ នៅមានមតិអះអាងថា វាជាប្រភពក្នុងការពង្រីកនយោបាយដែលស្របច្បាប់ និងមានឥទ្ធិពល ដែលជាដំណើរឆ្ពោះទៅកាន់អភិបាលកិច្ចល្អនិងជំរុញការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិឌ្ឍន៍(Rahnema 1992; Crooke & Kothari 2001) ។ ពួកលោកខាងលិច បាននាំយកពាក្យនេះទៅប្រើប្រាស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដោយមិនបានគិតពីរបៀបរបបការងារ និងប្រពៃណីរបស់ប្រទេសទាំងនោះទេ (Longley et al. 2007) ។ ទាំងអស់នេះ ធ្វើឱ្យមានចម្ងល់នៃការបង្កើតពាក្យនេះ និងជំរុញការចូលរួម ថាតើនរណាបង្កើតវាដើម្បីបង្កើនសមិទ្ធផលនៃការអភិវឌ្ឍន៍?

គំនិតទីពីរដែលគួរតែពិចារណាដែរនោះគឺចរិតលក្ខណៈនៃការចូលរួម ។ការចូលរួមគឺសំដៅទៅលើវត្តមានរបស់ប្រជាជនម្នាក់ៗ ដែលមានសំលេងគ្រប់គ្នាយ៉ាងសកម្ម និងស្មើភាពគ្នាក្នុងការបញ្ចេញមតិទៅលើបញ្ហាមួយ (Lebel et al. 2005) ។ ប៉ុន្តែភាពជាក់ស្តែងដែលកើតមាននោះ គឺប្រជាជនចូលរួមតែគម្រោងណាដែលគេឃើញមានផលប្រយោជន៍ចំពោះខ្លួនឯងប៉ុណ្ណោះ (Ribot 2004) ។

លោក Mohan (2001) បានបង្ហាញគំនិតប្រឆាំងថា មានពេលខ្លះការចូលរួម អាចធ្វើឱ្យគំរោងអភិវឌ្ឍន៍ជួបបញ្ហាស្មុគស្មាញជាងមុន ហើយមានពេលខ្លះ អាចនាំទៅរកបរាជ័យដល់គម្រោងទៀតផង ព្រោះថាប្រសិនបើគ្មានការគ្រប់គ្រងឱ្យបានហ្មត់ចត់ទេនោះការចូលរួមរបស់ប្រជាជននឹងធ្វើឱ្យមានការខ្វែងគំនិតនិងជម្លោះនៅពេលដែលប្រជាជនម្នាក់ៗ គិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ជាងប្រយោជន៍រួម ដោយទាញគម្រោងបំរើតម្រូវការរៀងៗខ្លួន ។

## ភាពពិតនៃការចូលរួមរបស់ប្រជាជនខ្មែរ

ដំណើរការនៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងគំរោងអភិវឌ្ឍន៍ប្រទេសកម្ពុជា គឺបាននាំទៅដល់ភាពជោគជ័យ និងពេលខ្លះបរាជ័យក្នុងពេលជាមួយគ្នាផងដែរ ដោយហេតុថា មានប្រជាជនចាប់ផ្តើមចូលរួម ប៉ុន្តែក្នុងចំនួនតិចតួច ហើយគ្រាន់តែ "ទៅអង្គុយស្តាប់" (DFID 2006; Hughes 2003; Rusten et al. 2004) ។ ប្រជាជនខ្មែរមិនទៅជួបតំណាងរបស់ពួកគេ ដើម្បីធ្វើការសហការអភិវឌ្ឍន៍នោះទេ (Hughes 2003) តែបែរជាទៅរកមន្ត្រីផ្សេងទៀតដែលភាគច្រើនជាបងប្អូនសាច់ញាតិ ហើយអ្នកនោះអាចជួយដោះស្រាយបញ្ហាផ្ទាល់ខ្លួនរបស់គេបាន (Rusten et al.2004) ។

បច្ចុប្បន្ននេះ អ្នកចូលរួមរៀបចំសហគមន៍ ច្រើនតែមានវ័យចំណាស់ដែលពិបាកទទួលយកការអប់រំថ្មីៗ ដូច្នេះតំរូវការអភិវឌ្ឍសង្គមពិបាកនឹងឈានទៅមុខ ។ លើសពីនេះ កសិករមមាញឹកនឹងការងារចិញ្ចឹមជីវិតប្រចាំថ្ងៃដែលធ្វើឱ្យពួកគេមិនអាចគិតទុកសម្រាប់ថ្ងៃស្អែកនោះទេ (Shrestha 1994) ។ ការចូលរួមតិចតួចពីសហគមន៍បែបនេះ គឺជាឧបសគ្គដល់ការទ្រទ្រង់ប្រព័ន្ធធារាសាស្ត្រ ។

## ៣. វិធីសាស្ត្រ

អត្ថបទនេះ សិក្សាអំពីបញ្ហាចូលរួមរបស់ប្រជាពលរដ្ឋ ដែលការចូលរួមនេះ សំដៅទៅលើ ១) ប្រជាជនប្រើទឹកពីប្រព័ន្ធធារាសាស្ត្រ ក្នុងវិស័យកសិកម្ម និង ២) ប្រជាពលរដ្ឋចូលរួមធ្វើការសំរេចចិត្តលើដំណើរការប្រព័ន្ធធារាសាស្ត្រ ជាពិសេសការកំណត់ថ្លៃសេវាប្រើប្រាស់ទឹក ។ ក្រុមស្រាវជ្រាវធ្វើការសិក្សាដោយពិភាក្សាជាមួយនឹងក្រុមជំនាញ ដូចជា ក្រុមអ្នកគ្រប់គ្រងទឹកនៅមូលដ្ឋាន ក្រុមកសិករប្រើប្រាស់ទឹក និងក្រុមគ្រប់គ្រងធនធានទឹកខេត្ត ដើម្បីស្វែងយល់ពីគោលគំនិតរបស់ក្រុមនីមួយៗ ជុំវិញបញ្ហានៃការចូលរួម ។ បន្ទាប់មក ក្រុមអ្នកស្រាវជ្រាវបានជួបពិភាក្សាបញ្ហាដែលប្រជាកសិករផ្ទាល់ជួបប្រទះក្នុងការដាំដុះរបស់ពួកគេ ជាពិសេសការប្រើប្រាស់ទឹកពីប្រព័ន្ធធារាសាស្ត្រ ។

## ៤. គំហើញ

### *អ្នកចូលរួមដែលយកមកសិក្សា*

ត្រពាំងត្របែក ជាតំបន់លិចទឹកក្នុងខេត្តកំពង់ឆ្នាំង ដែលមានទឹកជន់លិចនៅរដូវវស្សា ។ តំបន់នេះមានប្រព័ន្ធធារាសាស្ត្រមួយ ស្ថិតនៅលើទន្លេ ជ្រៃបាក់ ដែលកសាងឡើងដោយក្រុមខ្មែរក្រហមក្នុងអំឡុងទសវត្សរ៍១៩៧០ រហូតមកដល់ពេលនេះ ត្រូវគេបោះបង់ចោល និងអន្តរាយដោយសារទឹកជំនន់ និងសំនឹក ។ នៅតំបន់នេះ ប្រជាជនដាំស្រូវឡើងទឹក ប៉ុន្តែទឹកលិចពីទន្លេសាបមិនទៀងទាត់ ពេលខ្លះជន់លិចរហូតដល់ទៅ ៣ម៉ែត្រ ធ្វើឱ្យផលដំណាំនានាខូចខាតអស់ ។ ដោយសារតែមិនអាចទាញយកផលបែបនេះ ទើបប្រជាជនបោះបង់ការដាំដុះនៅតំបន់នេះនៅចុងឆ្នាំ១៩៨០ ។ នៅឆ្នាំ១៩៩១ អង្គការ AFSC បានកែលំអទំនប់ប្រព័ន្ធធារាសាស្ត្រនេះឡើងវិញ ។

ប៉ុន្តែប្រព័ន្ធនេះ ពុំមានប្រលាយទឹកនោះទេ ប្រជាជនត្រូវបូមយកទឹកដោយម៉ាស៊ីនបញ្ចូលស្រែដោយខ្លួនឯង ។ នៅពេលដំណើរការនាដំណាក់កាលដំបូង មានកសិករតិចតួចទេ មានចំណាប់អារម្មណ៍ប្រើប្រាស់វា ហើយទទួលផលដំណាំស្រូវប្រាំងបានតែប្រហែល ២០ហិកតាប៉ុណ្ណោះ ។

ចំពោះតំបន់ដាំដំណាំមានទំហំតូចបែបនេះ ប្រព័ន្ធធារាសាស្ត្រអាចផ្តល់ទឹកបានគ្រប់គ្រាន់ និងបង្កើនផលដំណាំស្រូវពីចំនួន ៤,៥តោន ក្នុងមួយហិកតា ដែលពីមុនទទួលបានតែ ០,៧តោន ឬ ០,៨តោន ឬគ្មានសោះសម្រាប់រដូវវស្សា ។ ប៉ុន្តែការរីករាយជាមួយនឹងការកើនឡើងនៃផលដំណាំទាំងនេះ មិនគង់វង្សយូរទេ ព្រោះថាទំហំដីដែលទទួលទឹកពីប្រព័ន្ធនេះ កើនឡើងរហូតដល់ទៅ ៥០០ហិកតា នៅឆ្នាំ២០០៦ និងនៅឆ្នាំ ២០០៧ ក្រុមសហគមន៍កសិកររាយការណ៍ថា ទំហំបានកើនឡើងចំនួន ៣០ហិកតាបន្ថែមទៀត ជាទំហំដែលធំពេក ធ្វើឱ្យប្រព័ន្ធមិនអាចផ្គត់ផ្គង់ទឹកបានគ្រប់គ្រាន់ ។

ការគ្រប់គ្រងប្រព័ន្ធដែលមានការប្រកួតប្រជែងខ្លាំងពីសំណាក់កសិករ ដើម្បីដណ្តើមយកធនធានទឹកមកធ្វើកសិកម្ម គឺមានការលំបាក ។ ព្រមជាមួយគ្នានេះ ក៏មានប្រព័ន្ធខ្លះ មានធនធានទឹកគ្រប់គ្រាន់ តែប្រជាកសិករបែរមិនយកចិត្តទុកដាក់ទាញយកធនធានទឹកមកធ្វើកសិកម្ម ។ ករណីនេះ យើងសង្កេតឃើញមាននៅដំណាក់អំពិល ។

ប្រព័ន្ធធារាសាស្ត្រនៅដំណាក់អំពិល បានកសាងឡើងក្នុងរបបប៉ុលពតដូចគ្នា ។ ប្រជាជននៅក្នុងតំបន់បានឱ្យដឹងថា ថ្មធំៗតម្រៀបកាត់ទន្លេ បង្វែរទឹកទៅប្រលាយលាតសន្ធឹង ២៥គីឡូម៉ែត្រទៅទិសខាងលិច ធ្វើឱ្យទំនប់ និងប្រលាយត្រូវបានទុកចោល និងអន្តរាយអស់ ។ ក្នុងកិច្ចប្រឹងប្រែងពង្រីកវិស័យកសិកម្មនៅតំបន់នេះ នៅឆ្នាំ២០០៤ គេបានជំរុញឱ្យមានការជួសជុលប្រព័ន្ធធារាសាស្ត្រនេះឡើងវិញ ហើយបានរួចរាល់នៅពាក់កណ្តាលឆ្នាំ២០០៦ ជាមួយនឹងសំណង់

ទំនប់បំបែកមួយប្រវែង ៧គីឡូម៉ែត្រ ។ ព័ត៌មានពីការចុះស្រាវជ្រាវបង្ហាញថា កសិករប្រើប្រាស់ទឹកនៅស្រូវប្រាំង មានចំនួនតិចតួចនៅឡើយ ព្រោះថាប្រព័ន្ធមិនទាន់សាងសង់រួច ដែលត្រូវការទំនប់ ប្រលាយធំ ប្រលាយតូច និងប្រលាយជើងក្អែបបន្ថែមទៀតដើម្បីដំណើរការ ។ ហេតុនេះបានជាធ្វើឱ្យប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល មិនអាចបែងចែកទឹកទៅគ្រប់ដីស្រែកសិករបាន ទោះបីមានទឹកច្រើនពេញប្រលាយមេក៏ដោយ ព្រោះកសិករដែលនៅឆ្ងាយពីប្រលាយគ្មានលទ្ធភាពទាញយកទឹកទាំងនោះមកប្រើប្រាស់ ។

បើសិនជាកសិករចង់ទាញយកទឹក ពួកគេត្រូវជួលម៉ាស៊ីនបូមទឹក ដែលកសិករក្រីក្រ មិនអាចរ៉ាប់រងបាន ។ សព្វថ្ងៃនេះ កសិករជួលម៉ាស៊ីនបូមទឹកពីឯកជន ដែលបូករួមទាំងម៉ាស៊ីនបូមទឹក និងប្រេង ក្នុងតម្លៃ ១៥.000រៀល ឬប្រហែល ៤ ដុល្លារក្នុងមួយម៉ោង ។ ដើម្បីបញ្ចូលទឹកក្នុងស្រែទំហំ ១ហិកតា ម៉ាស៊ីនបូមទឹកត្រូវដំណើរការ ៦ ទៅ ៨ ម៉ោងក្នុងមួយថ្ងៃ និងក្នុងរយៈពេល៤ថ្ងៃដូច្នេះកសិករត្រូវចំណាយ១០0ដុល្លារសម្រាប់ដីស្រែ១ហិកតា ។ការងារស្រោចស្រពដំណាំស្រូវ មិនមែនត្រូវការបូមទឹកដាក់បញ្ចូលតែម្តងនោះទេ កសិករត្រូវបូមទឹកបញ្ចូលស្រែជារៀងរាល់ខែ ឬក៏លើសពីនេះទៅតាមប្រភេទដីស្រែ ដែលអាចរក្សាទឹកទុកបានយូរប៉ុណ្ណា ។ កសិករខេត្តពោធិសាត់ម្នាក់ មានប្រសាសន៍ថា "ពួកយើងត្រូវជួលម៉ាស៊ីនបូមទឹក ៨ម៉ោង/មួយថ្ងៃ ក្នុងរយៈពេល ៣ថ្ងៃ ហើយត្រូវការលុយកាក់ជាច្រើន ចុះបើយើងត្រូវការទឹកសម្រាប់ខែក្រោយៗទៀតនោះ?" ហើយកសិករចំណាស់ម្នាក់ទៀត មានប្រសាសន៍បន្ថែមថា "បន្ទាប់ពីចំណាយលើការភ្ជួររាស់ ដកស្ទូង ដាក់ជី និងថ្លៃទឹក ពួកយើងទទួលប្រាក់ចំណេញកាន់តែតិច ឬក៏មិនចំណេញសោះតែម្តង ដូច្នេះតើពួកយើងខំប្រឹងដើម្បីអ្វី?"

ចំណែកឯនៅតំបន់ផ្សេងទៀត កសិករមិនចូលរួមទេ ព្រោះគេមានជំរើសផ្សេងទៀតដែលល្អជាងការធ្វើកសិកម្ម ដូចជានៅខេត្តសៀមរាប ដែលមានទឹកលើសលប់នៅក្នុងប្រព័ន្ធ តែគេមិនបានប្រើប្រាស់ទឹកទាំងនោះ ឱ្យមានផលប្រយោជន៍ដល់កសិកម្មទេ ។ នៅតំបន់ខ្លះក្នុងខេត្ត មានទឹកហូរចេញក្រៅប្រព័ន្ធ ដោយសារគ្មានការប្រើប្រាស់ ។ មូលហេតុគឺ ប្រជាជនអាចធ្វើចំណាកស្រុក ទៅធ្វើការនៅទីក្រុងសៀមរាប ដែលផ្តល់ចំណូលខ្ពស់ជាង អ្នកខ្លះអះអាងថា អាចរកបាន ៥ដុល្លារក្នុងថ្ងៃ ។ ឯអ្នកផ្សេងទៀតដែលមិនខ្វល់ពីទឹកនោះគឺ ពួកគេជាអ្នកជំនួញ ។ ដូច្នេះ តើមានកសិករឯណាទៅចូលរួមធ្វើការសម្រេចចិត្ត? តាមការកត់សំគាល់ កសិករខ្មែរតែងទៅចូលរួមប្រជុំ ដែលជាទូទៅការប្រជុំ ធ្វើនៅការិយាល័យឃុំ ឬភូមិ ហើយពួកគេចង់ដឹងបញ្ហា និងដំណោះស្រាយនានា ដែលកំពុងតែកើតមានឡើង ។ ស្ត្រីម្នាក់នៅខេត្តពោធិសាត់មានប្រសាសន៍ថា "បើសិនជាគេអញ្ជើញពួកយើងទៅប្រជុំនោះពួកយើងនឹងទៅព្រោះចង់ដឹងព័ត៌មាននានាដែរ ។" ចំពោះការចូលរួម ការណ៍ដែលមានវត្តមានរបស់ប្រជាជននាពេលប្រជុំ គឺជាសញ្ញាវិជ្ជមានមួយ ប៉ុន្តែប្រជាជនគ្រប់រូបមិនអាចទៅចូលរួមប្រជុំបានទេ ព្រោះការធ្វើដំណើរទៅប្រជុំ ត្រូវការចំណាយប្រាក់ ។ សមាជិកគ្រួសារកសិករ ត្រូវចែកវេនគ្នាទៅប្រជុំ ។ ម្យ៉ាងទៀត ម៉ោងប្រជុំតែងតែស្របពេលគ្នានឹងពេលដែលកសិករធ្វើការនៅក្នុងស្រែ ។ ការចូលរួមប្រជុំមានន័យថា ត្រូវនៅឆ្ងាយពីដីស្រែ ដែលជាប្រភពចិញ្ចឹមជីវិត ។ អ្នកចូលរួមប្រជុំភាគច្រើន គឺអ្នកដែលមិនសូវមមាញឹកនឹងការងារច្បារដំណាំ ដូចជាកសិករស្ត្រី និងវ័យចំណាស់ និងក្មេងៗដែលមិនអាចជួយការងារបង្កបង្កើនផល ។ អ្នកខ្លះទៀតមិនមកប្រជុំ ព្រោះគេគិតថា គ្មានផលប្រយោជន៍ដល់គេ ។ កសិករម្នាក់មានប្រសាសន៍ថា "ពួកយើងបានទៅចូលរួមប្រជុំច្រើនណាស់ ប៉ុន្តែគ្មានអ្វីប្រែប្រួលទាល់តែសោះ ។"

ប៉ុន្តែ ការចូលរួមប្រជុំមិនអាចចាត់ទុកជាការចូលរួមដែលមានន័យពេញលេញ សម្រាប់ដំណើរការអនុវត្តគ្រប់គ្រងធនធានទឹកនោះទេ ។ ការចូលរួមប្រជុំគ្រាន់តែជាធាតុមួយនៃការចូលរួម ហើយកន្លងមកការចូលរួមនៅមានកម្រិតនៅឡើយ ។ កសិករដែលទៅប្រជុំ គឺគ្រាន់តែចង់ដឹងរឿងរ៉ាវ ប៉ុន្តែពួកគេមិនដែលបញ្ចេញមតិ បង្ហាញគំនិតអ្វីទេ ឧទាហរណ៍ ការប្រជុំពិភាក្សាស្តីអំពីតម្លៃនៃដំណើរការប្រព័ន្ធធារាសាស្ត្រ រវាងក្រុមសហគមន៍កសិករ និងកសិករ ។ ទន្ទឹមនឹងនោះ ក៏នៅមានកសិករខ្លះ ហ៊ានប្រឆាំងនឹងគំនិតដែលពួកគេមិនយល់ស្របដែរ ។ កសិករម្នាក់នៅខេត្តកំពង់ធំមានប្រសាសន៍ថា "បើសិនជាពួកគេធ្វើអ្វី ដែលមានផលប៉ះពាល់ដល់យើងនោះ យើងនឹងតវ៉ា ។" នេះបញ្ជាក់ឱ្យឃើញថា អ្នកចូលរួម គឺចូលរួមក្នុងដំណើរការ មិនត្រឹមតែស្តាប់អង្គប្រជុំនោះទេ ។

ទោះយ៉ាងណា ការបញ្ចេញយោបល់របស់ប្រជាជននៅមានកម្រិតតិចតួចណាស់ ហើយភាគច្រើនគំនិតទាំងនោះទោរទៅរកគំនិតភាគច្រើនទៅវិញ ។ បើតាមការសង្កេត កសិករចង់បញ្ចេញយោបល់គាំទ្រ ឬប្រឆាំងគោលការណ៍ដែលលើកឡើងជាខ្លាំងតែពួកគេចាំមើលតែមតិភាគច្រើនទៅវិញ ។កសិករម្នាក់មានប្រសាសន៍ថា "ប្រសិនបើក្រុមសហគមន៍កសិករ លើកយកអ្វីដែលប៉ះពាល់នឹងផលប្រយោជន៍ យើងនឹងតវ៉ា ប៉ុន្តែត្រូវចាំមើលអ្នកផ្សេងទៀតសិន ប្រសិនបើភាគច្រើនគេយល់ស្រប តើយើងមានគ្នាតិចតួចប្រឆាំងតវ៉ាយ៉ាងដូចម្តេចទៅ?"

## ៥. សេចក្តីសន្និដ្ឋាន

នៅពេលដែលប្រព័ន្ធធារាសាស្ត្រ បានសាងសង់ និងជួលជុល ហើយកសិករមិនយកទឹកមកប្រើប្រាស់នោះ មនុស្សជាច្រើនគិតថា ប្រជាជនមិនចង់ "ចូលរួម" និង "ខ្ជិលច្រអូស" ។ ស្ថិតិស្រង់បានបង្ហាញថា កសិករដែលមិនចូលរួមនោះ មិនមែនខ្ជិលច្រអូសទេ ។ មុននឹងប្រជាកសិករចូលរួមក្នុងសហគមន៍ប្រព័ន្ធធារាសាស្ត្រ ពួកគេត្រូវគិតគូរយ៉ាងហ្មត់ចត់អំពីការចំណាយរបស់ខ្លួន ។ ប្រជាជនដែលប្រើប្រាស់ទឹកក្នុងប្រព័ន្ធ រួញរាដោយសារតែការចំនាយដ៏លើសលប់ពេក ។ ទោះបីជាមានអ្នកចូលរួមកាន់តែសកម្មក្នុងប្រព័ន្ធក៏ដោយ ក៏ប្រសិទ្ធភាពដែលទទួលបានមានកម្រិតទាបខ្លាំងដែរ ជាពិសេស គឺការបែងចែកទឹក និងការដាក់តំលៃ ព្រោះប្រជាកសិករភាគច្រើន មិនហ៊ានតបតនឹងមតិរបស់ក្រុមមានឥទ្ធិពលភាគច្រើន ព្រោះខ្លាចថានឹងក្លាយទៅជាជនក្រៅក្រុម ។

*សូមមើលឯកសារយោងក្នុងអត្ថបទជាភាសាអង់គ្លេស*

# ជំពូក ៥
# ការលូតលាស់ពីទីផ្សារដីធ្លីមិនផ្លូវការទៅជាផ្លូវការៈ ដំណើរការកាន់កាប់ដីធ្លីនៅប្រទេសកម្ពុជា

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងដំណើរការគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍អន្តរជាតិដើម្បីពង្រឹងផ្នែករដ្ឋបាល និងសុវត្ថិភាពកាន់កាប់ដីធ្លីនៅកម្ពុជា ។ ស្របគ្នានឹងសកម្មភាពជាច្រើនទៀត គំរោង LMAP កំពុងដំណើរការកម្មវិធីចុះបញ្ជីដីធ្លីជាប្រព័ន្ធ ដោយបានចេញប័ណ្ណកម្មសិទ្ធិចំនួនមួយលានប័ណ្ណ នៅតាមតំបន់ទីប្រជុំជន និងតំបន់ជនបទ ក្នុងដំណាក់កាលទី១ (២០០៣-២០០៧) ។

ប័ណ្ណកម្មសិទ្ធិដី រំពឹងថានឹងជំរុញអោយទីផ្សារដីធ្លីផ្លូវការ ដំណើរការកាន់តែមានប្រសិទ្ធភាព តាមរយៈការបែងចែកដីធ្លីសំរាប់ការប្រើប្រាស់មានផលិតភាពខាងសេដ្ឋកិច្ច ។ទន្ទឹមគ្នានេះការខិតខំពង្រឹងប្រព័ន្ធរដ្ឋបាលដីធ្លី មានរួមបញ្ចូលទាំងការជំរុញអោយប្រើប្រាស់សៀវភៅគោលបញ្ជីដីធ្លី ដែលជាបញ្ជីផ្លូវការ ដើម្បីជួយសំរួលដល់ប្រតិបត្តិការទិញលក់ដី ។ ការរំពឹងទុកទាំងនេះ ផ្អែកលើការសង្កេតឃើញថា ប្រទេសមានទីផ្សារដីធ្លីទំនើបប្រកបដោយប្រសិទ្ធភាព តែងបានទទួលផលប្រយោជន៍ពីប្រព័ន្ធរដ្ឋបាលមានដំណើរការល្អ ហើយប្រព័ន្ធនេះជាគន្លឹះសំខាន់សំរាប់ការរៀបចំទីផ្សារដីធ្លីដ៏មានប្រសិទ្ធភាព ។ អន្តរកាលពីទីផ្សារដីធ្លីមិនផ្លូវការ ទៅទីផ្សារផ្លូវការ និងការអភិវឌ្ឍប្រព័ន្ធរដ្ឋបាលដីធ្លីមានប្រសិទ្ធភាព ហាក់ដូចជាដើរទន្ទឹមគ្នា (Williamson and Wallace, 2007) ។

ទីផ្សារដីធ្លីមានលក្ខណៈផ្លូវការតិច រឺច្រើន គឺអាស្រ័យលើកំរិតដែលសកម្មភាពរបស់វាមានការបំរើសេវាកម្មអំពីប្រព័ន្ធសាធារណៈ រឺប្រព័ន្ធមានច្បាប់អនុញ្ញាតរបស់រដ្ឋាភិបាល រឺក៏យ៉ាងហោចណាស់ ប្រព័ន្ធរៀបចំឡើងដោយឆ្លងតាមរដ្ឋាភិបាល (Williamson and Wallace, 2007:2) ។ ប្រព័ន្ធផ្លូវការរួមមាន ការកសាងហេដ្ឋារចនាសម្ព័ន្ធខាងស្ថាប័នដើម្បីដោះស្រាយបញ្ហាការចុះបញ្ជីដីធ្លី ការវាយតំលៃ និងការយកពន្ធ ព្រមទាំងការរៀបចំផែនការ និងការអភិវឌ្ឍ (ឧទាហរណ៍ ផែនការមេសំរាប់អភិវឌ្ឍន៍ទីក្រុង បទប្បញ្ញត្តិបែងចែកតំបន់ប្រើប្រាស់ដីជាដើម) ។ រីឯទីផ្សារដីធ្លីមិនផ្លូវការវិញ គឺត្រូវបានគ្រប់គ្រងស្របតាមប្រព័ន្ធមូលដ្ឋាន ដែលមិនសុទ្ធតែមានតំលាភាពនោះទេ និងដែលធ្វើឱ្យផលប្រយោជន៍ខាងដីធ្លីមានលក្ខណៈ "មិនជឿនលឿន មិនប្រក្រតី ផ្សងសំណាង រឺគ្មានសុវត្ថិភាពតែម្តង" ។ ទីផ្សារមិនផ្លូវការជារឿយៗ ដំណើរការស្របគ្នានឹងប្រព័ន្ធទីផ្សារផ្លូវការស្របច្បាប់ ពីព្រោះប្រជាជនច្រើនតែចូលចិត្តអនុវត្តតាមបែបបទមិនផ្លូវការនៅមូលដ្ឋាន ជាជាងតាមបែបបទផ្លូវការដែលត្រូវការចំណាយខ្ពស់ ។Williamson និង Wallace 2007:2 បានសង្កេតឃើញថា នៅតាមប្រទេសមានទីផ្សារដីធ្លីស្របគ្នា ដែលប្រើប្រាស់នូវបែបបទផ្លូវការតាមកំរិតខុសៗគ្នា ភាគច្រើននៃការទិញលក់តាមបែបបទផ្លូវការ គឺច្រើនតែពាក់ព័ន្ធនឹងគំរោងអភិវឌ្ឍន៍ធំៗ និងដីធ្លីមានតំលៃខ្ពស់ ។

ការពិពណ៌នាខាងលើអំពីទីផ្សារផ្លូវការ និងមិនផ្លូវការ ព្រមទាំងចរិតលក្ខណៈនៃទីផ្សារដីធ្លីស្របគ្នា បានបង្ហាញច្បាស់ពី ស្ថានភាពនៅកម្ពុជា ដែលមានទីផ្សារមិនផ្លូវការគ្របដណ្តប់ភាគច្រើននៅតំបន់ជនបទ ប៉ុន្តែនៅតាមទីប្រជុំជន

ជាច្រើន មានប្រើទីផ្សារផ្លូវការកាន់តែញឹកញាប់ឡើង ទន្ទឹមគ្នានឹងទីផ្សារមិនផ្លូវការដែលមានតាំងពីយូរមកហើយ ។ នៅតំបន់ជាយក្រុង អន្តរកាលទីផ្សារដីធ្លីពីមិនផ្លូវការទៅជាផ្លូវការ គេអាចសង្កេតឃើញយ៉ាងងាយ ទោះជាល្បឿននៃអន្តរកាលវាមានកំរិតខុសៗគ្នាទៅតាមលក្ខណៈពិសេស និងប្រវត្តិសាស្ត្រនៃតំបន់នីមួយៗក៏ដោយ ។

ការស្រាវជ្រាវនាពេលថ្មីៗ (CDRI 2007a; CDRI 2007b) ដើម្បីវាយតំលៃពីផលប៉ះពាល់ជាសក្តានុពលនៃប័ណ្ណកម្មសិទ្ធិដីទៅលើសេដ្ឋកិច្ច និងសង្គមកម្ពុជា បានបង្ហាញថា ទីផ្សារដីធ្លីនៅទីប្រជុំជន និងជនបទ វាខុសគ្នាជាច្រើនយ៉ាង ប៉ុន្តែក៏មានលក្ខណៈដូចគ្នាច្រើនចំណុចដែរ ។ ការស្រាវជ្រាវនេះ បានរកឃើញនូវសូចនាករមួយចំនួន សំរាប់កំណត់ទិសដៅ និងល្បឿនធ្វើអន្តរកាលពីទីផ្សារដីធ្លីមិនផ្លូវការទៅជាផ្លូវការ នៅតាមតំបន់ទីប្រជុំជន តំបន់ជនបទ ព្រមទាំងតំបន់ជាយក្រុងផងដែរ ។ សូចនាករគន្លឹះៗ ចំនួន៥ មានដូចតទៅ ១) ទំរង់នៃការធ្វើលទ្ធកម្មដីធ្លី ២) ទំរង់នៃឯកសារបញ្ជាក់កម្មសិទ្ធិ ៣) បរិមាណនៃការទិញលក់ដីធ្លី ៤) តំលៃដីធ្លីដែលទិញលក់ និង ៥) ទំរង់នៃសំណុំឯកសារទិញលក់ ។

សូចនាករទាំងនេះអាចប្រើដើម្បីវាយតំលៃលើការអភិវឌ្ឍយ៉ាងលឿននៃទីផ្សារដីធ្លីនៅតំបន់ទីប្រជុំជន និងតំបន់ជាយក្រុងនៅកម្ពុជា ហើយនិងការប្រើប្រាស់ការចុះបញ្ជីផ្លូវការ ដើម្បីជួយសំរួល និងផ្តល់សុពលភាពដល់ការទិញលក់ដីធ្លី ។ អត្ថបទនេះវែកញែកថា នៅតំបន់ជាច្រើនដែលមានការចេញប័ណ្ណកម្មសិទ្ធិដីរួចហើយ សិទ្ធិជាប្រពៃណីនៅក្នុងទីផ្សារដីមិនផ្លូវការបានដំណើរការល្អគ្រប់គ្រាន់ ដើម្បីគ្រប់គ្រងការទិញលក់ និងទំនាស់នៅមូលដ្ឋាន ពីព្រោះប្រជាជននៅមានទំលាប់សុំឱ្យអាជ្ញាធរមូលដ្ឋានទទួលស្គាល់ និងផ្តល់សុពលភាពដល់ការទិញលក់ដី និងការផ្ទេរកម្មសិទ្ធិ ។ ផ្ទុយទៅវិញ ជាមួយនឹងការផ្តល់ប័ណ្ណកម្មសិទ្ធិតាមគំរោង LMAP មន្ត្រីរាជការរំពឹងទុកថា ប្រតិបត្តិការទិញ-លក់ និងការផ្ទេរផ្សេងៗ (បន្តមរតក) នឹងមានសុពលភាពតាមរយៈការចុះបញ្ជីផ្លូវការ ។ ចំណុចនេះបង្ហាញថា ការផ្ទេរកម្មសិទ្ធិដែលទទួលស្គាល់ត្រឹមតែអាជ្ញាធរមូលដ្ឋានទៅតាមទំលាប់ចាស់ ខាងរដ្ឋាភិបាល រឺតុលាការអាចមិនព្រមទទួលស្គាល់ថាស្របច្បាប់នោះទេ ។

អំណះអំណាងខាងលើ ក៏ជះឥទ្ធិពលទៅលើការកំណត់តំបន់គោលដៅ និងលំដាប់លំដោយនៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីជាប្រព័ន្ធដែរ ។ ប័ណ្ណកម្មសិទ្ធិដី ជាធនធានកំរមួយ ដូច្នេះហើយត្រូវមានសេចក្តីសំរេចខាងគោលនយោបាយពីតំបន់ ដែលគួរចេញប័ណ្ណកម្មសិទ្ធិឱ្យមុន និងបន្តបន្ទាប់មកទៀត ដើម្បីអោយវាផ្តល់អត្ថប្រយោជន៍បានច្រើនបំផុតដល់សង្គម និងសេដ្ឋកិច្ច រួមទាំងជួយជំរុញអោយមានទីផ្សារដីធ្លីផ្លូវការមានប្រសិទ្ធភាពខ្ពស់ផង ។ ទោះយ៉ាងនេះគោលដៅចំបងរបស់ LMAP និងផលប្រយោជន៍ដ៏ច្រើនដែលសង្ឃឹមថានឹងទទួលបានពីគំរោង អាចមិនស៊ីសង្វាក់គ្នា ហើយអាចធ្វើឱ្យច្របូកច្របល់ដល់ការកំណត់តំបន់គោលដៅ និងលំដាប់លំដោយនៃការផ្តល់ប័ណ្ណ ។ ឧទាហរណ៍ការប្រើប័ណ្ណកម្មសិទ្ធិដី ដើម្បីកាត់បន្ថយភាពក្រីក្រ មានន័យថា ប័ណ្ណកម្មសិទ្ធិដីគួរតែផ្តល់នៅតំបន់មានអត្រាក្រីក្រខ្ពស់ ដែលច្រើនតែជាតំបន់ដាច់ស្រយាល មានទីផ្សារដីធ្លីមិនផ្លូវការ និងស្ពឹកស្រពន់ ។ អវត្តមានសឹងតែទាំងស្រុងនៃការទិញលក់ដីបង្ហាញថា ប័ណ្ណកម្មសិទ្ធិដីមានឥទ្ធិពលតិចតួចណាស់ក្នុងការជំរុញអោយមានទីផ្សារដីធ្លីផ្លូវការនៅតាមតំបន់ទាំងនោះ ។ ផ្ទុយទៅវិញ ការប្រឹងប្រែងធ្វើប័ណ្ណកម្មសិទ្ធិដោយផ្តើមចេញពីតំបន់ផ្សារនៅជនបទ និងតំបន់ជុំវិញផ្សារដែលមានទីផ្សារដីមិនផ្លូវការសកម្មខ្លាំង វាអាចមានឥទ្ធិពលល្អប្រសើរជាងក្នុងការជំរុញអោយមានទីផ្សារផ្លូវការ ។

ការវិភាគវែកញែកនេះសន្មតថា ការទិញលក់ដី និងការផ្ទេរកម្មសិទ្ធិ នៅក្រោយពេលមានការចេញប័ណ្ណកម្មសិទ្ធិនឹងមានការជួយសំរួល និងផ្តល់សុពលភាព តាមរយៈការចុះបញ្ជីជាផ្លូវការ ។ ប៉ុន្តែបើសិនការសន្មតនេះមិនត្រឹមត្រូវទេ

តើនឹងមានអ្វីកើតឡើង? ផលប៉ះពាល់វិជ្ជមានជាសក្តានុពលនៃទីផ្សារដីធ្លី អាចថយចុះដោយសារប្រជាជនបន្តចូលចិត្តប្រើប្រាស់មធ្យោបាយមិនផ្លូវការតាមទំលាប់ចាស់ ដើម្បីធ្វើការផ្ទេរដី និងសិទ្ធិកាន់កាប់ដី ។

ពីមួយឆ្នាំទៅមួយឆ្នាំ បែបបទធ្វើលទ្ធកម្មប្រហែលប្រែប្រួលភាគច្រើនទៅជាការទិញ និងការផ្ទេរបន្តមរតកវិញ ។ ដូច្នេះ ភាគរយនៃក្បាលដីដែលទទួលបានពីរដ្ឋចែកឱ្យនឹងធ្លាក់ចុះ ជាពិសេសនៅទីប្រជុំជននឹងមានការធ្លាក់ចុះយ៉ាងខ្លាំង ហើយបន្ទាប់មកគឺនៅតំបន់ជាយក្រុង ។ ដោយទីផ្សារដីធ្លីផ្លូវការនឹងកើតឡើងកាន់តែច្រើននៅតាមតំបន់ជនបទ ពិសេសនៅក្នុងនិងជុំវិញតំបន់ផ្សារ និងកន្លែងរដ្ឋបាល លទ្ធកម្មតាមរយៈការទិញនឹងកើនចំនួនភាគរយ ទោះបីវានៅទាបជាងតំបន់ទីប្រជុំជន និងជាយក្រុងក៏ដោយ ។ នៅទីប្រជុំជន អត្រាទទួលបានដីដោយការទិញរបស់គ្រួសារមានស្ត្រីជាមេគ្រួ ក៏កើនឡើងលឿនជាងគ្រួសារស្ត្រីមេគ្រួនៅតាមជនបទដែរ ។ ការប្រែប្រួលបែបនេះ ជាពិសេសនៅទីប្រជុំជន និងតំបន់ជាយក្រុង គឺជាលទ្ធផលនៃការរីកលូតលាស់នៃទីផ្សារដីធ្លីផ្លូវការ សំរាប់ការវិនិយោគមានផលិតភាព និងការទិញទុកលក់យកចំណេញ ។ ការចុះបញ្ជីដីធ្លី ប្រាកដជាជួយសំរួលដល់ដំណើរការទិញលក់ ដោយជួយកាត់បន្ថយតំលៃប្រតិបត្តិការផ្ទេរកម្មសិទ្ធិតាមកិច្ចសន្យា ។ ប៉ុន្តែការទិញលក់ដីទាំងនេះមានចុះបញ្ជីផ្លូវការ បានច្រើនក៏រិតណា វាជាបញ្ហាមួយផ្សេងទៀត ។

ទីផ្សារដីធ្លីនៅជនបទ ជាទូទៅពុំមានឯកសារបញ្ជាក់កម្មសិទ្ធិទេ ប៉ុន្តែទីផ្សារដីធ្លីដែលមានលក្ខណៈផ្លូវការជាងនៅទីប្រជុំជន ជាទូទៅតែងមានទំរង់ឯកសារខ្លះសំរាប់បញ្ជាក់ ។ ទាំងនៅទីប្រជុំជន និងតំបន់ជនបទ ទំរង់ឯកសារដីដែលគេនិយមប្រើប្រាស់ ច្រើនមានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ប៉ុន្តែវាមិនស្របតាមច្បាប់ ដូចដីធ្លីដែលបានចុះបញ្ជីជាផ្លូវការដោយអាជ្ញាធរសុរិយោដីឡើយ ។ ឯកសារដីភាគច្រើន មិនបានចុះបញ្ជីជាផ្លូវការទេ ដូច្នេះវាមិនស្របច្បាប់ឡើយ ។

ប្រសិនបើការទិញលក់ដី បន្តកើនឡើងដូចការរំពឹងទុក បន្ទាប់ពីការចេញប័ណ្ណកម្មសិទ្ធិឱ្យ ប្រជាជនអាចនៅតែបន្តធ្វើឯកសារកាត់ឈ្មោះនៅត្រឹមថ្នាក់មូលដ្ឋានដែលជាមធ្យោបាយមិនស្របច្បាប់ ។ រឿងនេះបានកើតឡើងជាក់ស្តែងហើយ នៅតាមតំបន់មួយចំនួនដែលបានចេញប័ណ្ណកម្មសិទ្ធិដីឱ្យរួចរាល់ (ដូចជាបានចុះក្នុងឯកសាររបស់ Markussen 2007) ដូចជានៅខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ជាឧទាហរណ៍ស្រាប់ (ADI 2007) ។ ចំណុចនេះសំខាន់ណាស់ពីព្រោះហេតុផលគន្លឹះមួយនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺដើម្បីជួយសំរួលដល់ការផ្ទេរកម្មសិទ្ធិដីតាមរយៈការចុះបញ្ជីជាផ្លូវការ ។ ពីមួយឆ្នាំទៅមួយឆ្នាំ ដីធ្លីមានប័ណ្ណកម្មសិទ្ធិពីគំរោង LMAP ដែលគេធ្វើការទិញលក់ដោយមិនចុះបញ្ជីជាផ្លូវការ អាចធ្វើអោយចុះខ្សោយដល់សុវត្ថិភាពកាន់កាប់ដីថែមទៀត មិនមែនពង្រឹងវាដូចបំណងដើមនោះទេ ។ ការទិញលក់បែបនេះ ក៏នឹងជួយធ្វើឱ្យមានទំនាស់ដីធ្លីជាបន្តបន្ទាប់ ហើយបង្កការខាតបង់មួយយ៉ាងធំដល់ចំណូលរដ្ឋ ។

*សូមមើលឯកសារយោងក្នុងអត្ថបទជាភាសាអង់គ្លេស*

# ឧបពូក ៦
# របាយការណ៍សង្ខេបអំពីស្ថាប័ន គោលនយោបាយ និង ក្របខ័ណ្ឌច្បាប់ ស្តីពីការគ្រប់គ្រងទេសន្តប្រវេសពលករកម្ពុជា[១]

ពាក់ព័ន្ធនឹងស្ថាប័នគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ ស្តីពីការគ្រប់គ្រងទេសន្តប្រវេសពលករកម្ពុជា ប្រទេសកម្ពុជាមានបទពិសោធន៍តិចជាងប្រទេសដទៃទៀតទេ ។ ពលករភាគច្រើន ធ្វើដំណើរតាមមធ្យោបាយមិនផ្លូវការ រឺខុសច្បាប់ រឺឯមធ្យោបាយស្របច្បាប់វិញ ទើបនឹងមានក្នុងមួយទសវត្សរ៍កន្លងមក ។ ភ្នាក់ងាររដ្ឋ នឹងប្រឈមចំពោះបញ្ហាកាន់តែច្រើនឡើងនៃការគ្រប់គ្រងចំណាកស្រុកពលករដែលរំពឹងថានឹងមានការកើនឡើង ដោយសារកត្តាខាងក្នុង និងខាងក្រៅ ។ ការធ្វើចំណាកស្រុក ទំនងជានឹងកើនឡើង ដោយសារការបង្កើតការងារក្នុងស្រុក មានល្បឿនយឺតជាងកំណើនពលករប្រចាំឆ្នាំ ដែលមានប្រហែល ៣០០.០០០នាក់ ។ ប្រាក់បៀវត្សរ៍ខ្ពស់ជាង និងតំរូវការពលករនៅប្រទេសថៃ ម៉ាឡេស៊ី កូរ៉េខាងត្បូង សឹង្ហបុរី និងជប៉ុន គឺជាកត្តាទាក់ទាញពីខាងក្រៅ ។

ទោះជាយើងពេញចិត្តនឹងការបង្កើតឱកាសការងារ និងអភិវឌ្ឍន៍នៅក្នុងប្រទេសជាងក្តី ក៏យើងគួរមានការបង្កើតប្រព័ន្ធគ្រប់គ្រងគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ សំរាប់គ្រប់គ្រងចំណាកស្រុកពលករឱ្យបានល្អដែរ ពីព្រោះចំណាកស្រុក អាចផ្តល់ឱកាសការងារ និងចំណូលចាំបាច់សំរាប់រយៈពេលខ្លី និងមធ្យម ។ មិនតែប៉ុណ្ណោះ វាអាចជួយកាត់បន្ថយភាពក្រីក្រផងដែរ ។ ប្រាក់ដែលផ្ញើមកកម្ពុជា មានតួលេខប៉ាន់ស្មានប្រហែល ២០០លានដុល្លារ រឺ ៣,២៣% នៃផលិតផលក្នុងស្រុកសរុប (ផសស) ឆ្នាំ២០០៥ ។ ចំពោះប្រទេសផ្សេងទៀតក្នុងតំបន់ ចំណាកស្រុកពលករ គឺសំខាន់ណាស់ ហើយប្រាក់ផ្ញើមកផ្ទះ មានចំនួនយ៉ាងច្រើន ។ យោងតាម Dang (2007) ជនជាតិវៀតណាមប្រហែល ៤០០.០០០នាក់ កំពុងធ្វើការនៅ ៤០ប្រទេសផ្សេងៗគ្នា ហើយបានផ្ញើប្រាក់ មកផ្ទះប្រមាណ ២ពាន់លានដុល្លារក្នុងមួយឆ្នាំ ។ យោងតាមសូចនាករអភិវឌ្ឍន៍ពិភពលោក (World Development Indicators) ឆ្នាំ២០០៧ ផ្សាយដោយធនាគារពិភពលោក ប្រទេសថៃ ទទួលបានប្រាក់ផ្ញើមកផ្ទះ ១,២ពាន់លានដុល្លារ វៀតណាមបាន ៤ពាន់លានដុល្លារ ហ្វីលីពីន ១៣,៥ពាន់លានដុល្លារ និងបង់ក្លាដេស ៤,២ពាន់លានដុល្លារនៅឆ្នាំ២០០៥ ។ ការសិក្សារបស់មូលនិធិអន្តរជាតិសំរាប់ការអភិវឌ្ឍកសិកម្ម និងធនាគារអភិវឌ្ឍន៍ទ្វីបអាមេរិក (IFAD 2007) រកឃើញថា ពលករចំណាកស្រុកនៅលើពិភពលោកមាន ១៥០លាននាក់ ហើយពួកគេបានផ្ញើប្រាក់មកផ្ទះ ៣០០ពាន់លានដុល្លារនៅឆ្នាំ២០០៦ គឺលើស ជំនួយអភិវឌ្ឍន៍និងវិនិយោគផ្ទាល់ពីបរទេសទៅទៀត ។

---

[១] នេះជាសេចក្តីសង្ខេប នៃរបាយការណ៍ព្រាងដែលវិទ្យាស្ថាន CDRI កំពុងសរសេរ ដោយមានការឧបត្ថម្ភថវិកា ដោយអង្គការពលកម្មអន្តរជាតិ (ILO) និងសហការជិតស្និទ្ធជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ យោបល់ ឬកំហុសដោយអចេតនា គឺជារបស់អ្នកនិពន្ធ ពោលគឺមិនមែនជារបស់ CDRI ឬអង្គការ ILO ទេ ។

ជាទូទៅ ការងារជាមូលដ្ឋានសំរាប់ចំណាកស្រុកចេញពីកម្ពុជា មានពីរប្រភេទ គឺការងារស្របច្បាប់ និងការងារមិនស្របច្បាប់ ។ គិតត្រឹមចុងឆ្នាំ២០០៧ ពលករសរុប ២០.៦៣០នាក់ ត្រូវបានបញ្ជូនជាផ្លូវការទៅកាន់ម៉ាឡេស៊ី ថៃ និងកូរ៉េ ។ ក្នុងនោះពលករ ១០.៥៣២នាក់ ត្រូវបានបញ្ជូនជាផ្លូវការទៅម៉ាឡេស៊ី ៣៩៨៤នាក់ ទៅកូរ៉េ និង ៦១១៤នាក់ ទៅថៃ ។ ពលករប្រហែល ១៨០.០០០នាក់ កំពុងធ្វើការនៅថៃ យោងតាម (UNIFEM 2006) ដែលក្នុងនោះ ១១០.០០០នាក់ បានទទួលលិខិតអនុញ្ញាតឱ្យធ្វើការចេញដោយរដ្ឋាភិបាលថៃ នៅឆ្នាំ២០០៤ និងប្រហែល ៥០.០០០នាក់ បានទទួលលិខិតបញ្ជាក់ពីអត្តសញ្ញាណ (CI) ចេញដោយរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមការងារអន្តរក្រសួងដឹកនាំដោយក្រសួងការងារ ។ ពលករទៅម៉ាឡេស៊ីភាគច្រើនជាស្ត្រី ទៅធ្វើជាអ្នកបំរើ រឺអ្នកធ្វើការងារផ្ទះ រីឯពលករទៅកូរ៉េភាគច្រើនជាបុរស ។ បើទោះជាថៃធ្លាប់បានទទួលពលករ ចំណាកស្រុកពីកម្ពុជាតាំងពីឆ្នាំ១៩៩៤ ក៏ពលករភាគច្រើន គ្មានឯកសារបញ្ជាក់អ្វីទេ រឺជាពលករមិនស្របច្បាប់ ។ ការបញ្ជូនពលករទៅជាផ្លូវការ ទើបតែចាប់ផ្តើមក្នុងឆ្នាំ២០០៦ បន្ទាប់ពីមានអនុស្សរណៈព្រមព្រៀង (MOU) រវាងថៃ និងកម្ពុជា នៅខែឧសភា ឆ្នាំ២០០៣ ។

## បទប្បញ្ញត្តិច្បាប់ និងស្ថាប័នសំរាប់គ្រប់គ្រងចំណាកស្រុកពលករ

*កង្វះក្របខ័ណ្ឌច្បាប់*

ដោយចំណាកស្រុកពលករនៅកម្ពុជា ជារឿងមួយថ្មី ហេតុនេះកម្ពុជា ត្រូវប្រឈមនឹងបញ្ហាក្នុងការបង្កើតគោលនយោបាយ នីតិបញ្ញត្តិ និងបទប្បញ្ញត្តិផ្សេងៗ ដើម្បីដោះស្រាយបញ្ហាចំណាកស្រុកពលករ ។ នៅឆ្នាំ១៩៩៥ អនុក្រឹត្យលេខ៥៧ ស្តីពីការបញ្ជូនពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេសត្រូវបានអនុម័ត ។ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា កាលពេលនោះ ជាអ្នកពង្រាងអនុក្រឹត្យនោះ ដោយសហការជាមួយ ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស ។ អនុក្រឹត្យលេខ ៥៧ បានទទួលស្គាល់ពីកង្វះខាតឱកាសការងារក្នុងស្រុក និងមានគោលបំណងកែលំអកំរិតជីវភាពរបស់ប្រជាជនតាមរយៈការរកចំណូល និងទទួលបានជំនាញពីការងារក្រៅស្រុក ។ អនុក្រឹត្យចែងឱ្យក្រសួងទទួលបន្ទុក ( ពេលនេះ គឺក្រសួងការងារ) ធ្វើជាអ្នកផ្តល់ធនធានមនុស្ស ហើយក្រុមហ៊ុនរឺទីភ្នាក់ងារជ្រើសរើសពលករ ជាភាគីទទួលយកពលករ ។ ក្រៅពីអនុក្រិតលេខ ៥៧ នៅមានប្រកាសលេខ១០៨ ចុះនៅខែឧសភា ឆ្នាំ២០០៦ ស្តីពី ការអប់រំអំពីជំងឺអេដស៍ ចំណាកស្រុក ដោយសុវត្ថិភាព និងសិទ្ធិការងារសំរាប់ពលករខ្មែរធ្វើការនៅក្រៅស្រុក ព្រមទាំងអនុក្រឹត្យលេខ ៧០ ចុះនៅខែកក្កដា ឆ្នាំ២០០៦ ស្តីពីការបង្កើតក្រុមប្រឹក្សាបណ្តុះបណ្តាលហត្ថពលកម្ម និងបញ្ជូនពលករទៅបរទេស ។

អ្នកឆ្លើយសំភាសន៍ជាច្រើនលើកឡើងថា កម្ពុជាខ្វះគោលនយោបាយទេសន្តប្រវេសន៍ រឺច្បាប់ជាក់លាក់សំរាប់ចំណាកស្រុក ។ នៅក្នុងគំនិតពួកគេ អនុក្រិតលេខ ៥៧ ( ជាឯកសារច្បាប់ច្រេងក្រងតែមួយគត់ក្រៅពីប្រកាស) មានអាយុកាលយូរពេកហើយ និងគួរមានការពិនិត្យកែសំរួលឡើងវិញ ។ ច្បាប់ការងាររបស់កម្ពុជា មិនអាចយកទៅអនុវត្តនៅប្រទេសទទួលយកពលករបានទេ ជាពិសេសទាក់ទិននឹងចំណាកស្រុកពលករ ។

*កង្វះខាតក្នុងស្ថាប័នរដ្ឋ*

មានទស្សនៈថាគួរមានស្ថាប័នជំនាញដោយឡែកមួយទទួលខុសត្រូវគ្រប់គ្រងចំណាកស្រុកពលករដូចដែលប្រទេសមួយចំនួនអនុវត្ត ដោយហេតុថាចំណាកស្រុក ជាបញ្ហាស្មុគស្មាញពាក់ព័ន្ធនឹងវិស័យជាច្រើន មានជំរើសល្អមួយ គឺបង្កើត

ការិយាល័យ រឺនាយកដ្ឋានឯករាជ្យ នៅក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។ ប៉ុន្តែ ទស្សនៈមួយទៀតយល់ថា ស្ថាប័នមានគ្រប់គ្រាន់ហើយ អ្វីដែលនៅខ្វះខាត គឺសមត្ថភាពរបស់ស្ថាប័ន ។ អ្នកឆ្លើយសំភាសន៍ទាំងអស់ មានមតិរួមមួយថា ចាំបាច់ត្រូវបន្ថែមចំនួនបុគ្គលិកមានសមត្ថភាព ទៅក្នុងអគ្គនាយកដ្ឋានពលកម្ម និងនាយកដ្ឋានការងារនិងហត្ថពលកម្ម ដើម្បីគ្រប់គ្រងបញ្ហាចំណាកស្រុកពលករ ឱ្យបានប្រសើរជាងនេះ ជាពិសេស ប្រសិនបើពលករខុសច្បាប់មួយភាគធំ ត្រូវបង្វែរឱ្យទៅតាមផ្លូវស្របច្បាប់វិញនោះ ។ រឿងនេះ ត្រូវការនូវថវិកាមួយចំនួនពីរដ្ឋាភិបាលដើម្បីទាក់ទាញមន្ត្រីដែលមានសមត្ថភាពសមស្រប និងដើម្បីមានមធ្យោបាយគ្រប់គ្រាន់ក្នុងការអនុវត្តការងារ ។ ក្រសួងការងារយល់ថា គួរមានទស្សនកិច្ចសិក្សា និងសិក្ខាសាលាពិភាក្សាច្បាស់លាស់លើការកែទំរង់ស្ថាប័នគ្រប់គ្រងចំណាកស្រុកពលករនេះ ដែលនេះជាសំណូមពរមួយសមហេតុផល ។

អង្គការមិនមែនរដ្ឋាភិបាល មានសកម្មភាពច្រើនពាក់ព័ន្ធនឹងបញ្ហាចំណាកស្រុកនិងការជួញដូរមនុស្ស ។បណ្តាញ NGO ពាក់ព័ន្ធនឹងចំណាកស្រុក ត្រូវបានបង្កើតឡើងក្រោមការគាំទ្រពីមូលនិធិអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិដើម្បីស្ត្រី (UNIFEM) និងមានការចូលរួមពីអង្គការចំនួន ៣០ ។ អង្គការទាំងនោះ ជួបប្រជុំរៀងរាល់ ២ខែម្តង ដើម្បីបន្តកម្មវិធីចំនួន ៥ ស្តីពី ១) ការផ្សព្វផ្សាយចំណេះដឹង និងការតស៊ូមតិ ២) ការស៊ើបអង្កេត ៣) ទិដ្ឋភាពច្បាប់ ៤) ការស្រាវជ្រាវ និងប្រមូលទិន្នន័យ និង ៥) ការកសាងសមត្ថភាព និងទំនាក់ទំនងសាធារណៈ ។ បណ្តាញនេះ ដឹកនាំដោយគណៈកម្មាធិការដឹកនាំការងារ ដែលមកពីអង្គការសកម្មៗ ធ្វើការខាងចំណាកស្រុកពលករ និងការជួញដូរមនុស្ស ។

*កង្វះខាតស្ថាប័នឯកជន*

អនុក្រឹត្យលេខ ៥៧ លើកឡើងចំបញ្ហានៃភាពគ្មានការងារធ្វើ និងភាពមានការងារមិនគ្រប់គ្រាន់ ព្រមទាំងបង្ហាញពីផលចំណេញបានមកពីចំណាកស្រុកពលករ ក្នុងការលើកកំពស់ករិតជីវភាពរបស់ប្រជាជនកម្ពុជា ។ ក៏ប៉ុន្តែទិដ្ឋភាពមួយចំនួនបង្ហាញថា គោលបំណងអនុក្រឹត្យ និងគោលនយោបាយ មានភាពមិនស៊ីចង្វាក់គ្នា ។ ទាំងនេះមានដូចជា ការតម្រូវឱ្យទីភ្នាក់ងារជ្រើសរើសពលករដាក់ប្រាក់តំកល់ច្រើន និងចេញសោហ៊ុយចំណាយជាមុន ។ គួរតែមានទីភ្នាក់ងារជ្រើសរើសពលករច្រើនគ្រប់គ្រាន់ ដើម្បីទទួលចាត់ចែងលើពលករចំណាកស្រុក ចំនួនប្រមាណ ២០០.០០០នាក់ បើសិនជាពួកគេត្រូវធ្វើដំណើរទៅតាមមធ្យោបាយស្របច្បាប់ ។ ទាំងស្ថាប័នរដ្ឋ និងឯកជន តម្រូវអោយមានចំនួនច្រើនគ្រប់គ្រាន់ និងរឹងមាំ ។ បច្ចុប្បន្ននេះ មានកង្វះខាតទាំងមន្ត្រីរដ្ឋមានសមត្ថភាពដោះស្រាយបញ្ហាចំណាកស្រុកពលករ និងទីភ្នាក់ងារឯកជនសំរាប់ជ្រើសរើសបណ្តុះបណ្តល និងបញ្ជូនពលករទៅបរទេស ។

កង្វះខាតចំនួនទីភ្នាក់ងារបញ្ជូនពលករទៅក្រៅស្រុក គឺបណ្តាលមកពីតម្រូវការដ៏ខ្ពស់ដែលចែងក្នុងអនុក្រឹត្យ ។ ក្រុមហ៊ុនត្រូវបានតំរូវអោយដាក់នូវប្រាក់តំកល់ចំនួន ១០០.០០០ដុល្លារ ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងត្រូវបង់ចំណាយផ្សេងៗសំរាប់បញ្ជូនពលករ ។ ការណ៍នេះដាក់នូវបន្ទុកផ្នែកហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរមួយទៅលើពួកគេ ។ វាក៏ជាមូលហេតុដែលធ្វើឱ្យ ២៦ក្រុមហ៊ុន ត្រូវបិទទ្វារក្នុងខែកក្កដា ឆ្នាំ២០០៦ នៅពេលដែលមានការរឹតបណ្តឹងឱ្យដាក់ប្រាក់ដិកល់ ហើយនៅសល់តែ ១២ក្រុមហ៊ុនប៉ុណ្ណោះដែលបន្តដំណើរការ ។ ថ្មីៗនេះ ក្រុមហ៊ុនចំនួន ៣ បន្ថែមទៀត ត្រូវបានបង្កើតឡើង ដែលធ្វើអោយចំនួនសរុបកើនទៅដល់ ១៦ក្រុមហ៊ុន ដោយមិនរាប់បញ្ចូលនូវទីភ្នាក់ងារចំនួន ២ ទៀត ដែលព្យាយាមប្រែក្លាយខ្លួនទៅជាអង្គការមិនមែនរដ្ឋាភិបាល (NGO) ។ តាមការវិនិច្ឆ័យដោយ

ប្រទេសដែលមានបទពិសោធន៍យូរអង្វែងក្នុងការនាំពលករទៅបរទេស តួលេខនេះគឺជាចំនួនដ៏តិចតួចណាស់ ។ ប្រទេសបង់ក្លាដែស មានប្រមាណ ៨០០ក្រុមហ៊ុនធ្វើការជ្រើសរើស និងបញ្ជូនពលករទៅបរទេស រីឯប្រទេសហ្វីលីពីន មានច្រើនជាង ១០០០ក្រុមហ៊ុន ។ កម្ពុជាគួរមានក្រុមហ៊ុនយ៉ាងហោចណាស់ ១០០ក្រុមហ៊ុន បើគិតថាក្រុមហ៊ុនមួយអាចជ្រើសរើស និងបញ្ជូនពលករបាន ២០០០នាក់ ។ ក្រុមហ៊ុនគួរមានការិយាល័យនៅតាមខេត្ត និងស្រុក ដើម្បីបង្កភាពងាយស្រួលដល់ពលករដែលភាគច្រើនជាអ្នកក្រីក្រនៅតាមតំបន់ជនបទ ។

*ការតំរូវឱ្យទីភ្នាក់ងារជ្រើសរើសពលករ ចំណាយជាមុនក្នុងការបញ្ជូនពលករចំណាកស្រុក*

បញ្ហាមួយទៀតនៃបទប្បញ្ញត្តិ គឺថាចំណាយហិរញ្ញវត្ថុនៃការបញ្ជូនពលករទៅក្រៅស្រុក ត្រូវទទួលរ៉ាប់រងដោយក្រុមហ៊ុនទាំងនោះ ។ ក្រសួងការងារយល់ឃើញថា លក្ខខណ្ឌតំរូវឱ្យចេញចំណាយជាមុននេះ គឺតំរូវតាមគោលការណ៍រដ្ឋាភិបាលដែលត្រូវបានដាក់អោយអនុវត្ត ប៉ុន្តែការពិតវាគ្រាន់តែជាអនុសាសន៍មួយរបស់សម្តេចនាយករដ្ឋមន្ត្រី ដែលបង្ហាញពីភាពអាណិតអាសូរចំពោះជនក្រីក្រប៉ុណ្ណោះ ។ នេះមានន័យថា ក្រុមហ៊ុនត្រូវចំណាយជាមុនយ៉ាងហោចណាស់ ១.២០០.០០០ដុល្លារ ក្នុងការបញ្ជូនពលករចំនួន ២០០០នាក់ ទៅក្រៅស្រុកក្នុងពេលតែមួយបាន ដោយហេតុថា ចំណាយនៃការបញ្ជូនពលករម្នាក់ គឺ៦០០ដុល្លារ ។ នេះគឺជាចំនួនលុយដ៏ច្រើន និងប្រថុយប្រថាន ជាពិសេសសំរាប់ក្រុមហ៊ុនមានម្ចាស់ជាជនជាតិកម្ពុជា ដែលមិនសូវមានទុន ប៉ុន្តែមានសមត្ថភាព ។ ក្រុមហ៊ុនទាំងនេះ រាយការណ៍នូវការខាតបង់ដ៏ច្រើនគួរសម ដែលបណ្តាលមកពីការរត់ចោលការងាររបស់ពលករក្នុងខណៈពេលនៅបរទេស ។ បញ្ហានេះបានធ្វើឱ្យជីវិតក្រុមហ៊ុនទាំងនោះ ស្ថិតក្នុងភាពគ្រោះថ្នាក់ ។

បន្ទាប់ពីបានកត់សំគាល់ឃើញនូវបន្ទុកទាំងនេះ ក្រសួងមិនជំទាស់ចំពោះការតំរូវឱ្យពលករដែលដាក់ពាក្យទៅធ្វើការនៅបរទេសទាំងអស់ធ្វើការចំណាយលើលិខិតឆ្លងដែន ព្រមទាំងចំនាយមូលដ្ឋានផ្សេងៗដូចជា ការពិនិត្យសុខភាពជាដើម ។ បច្ចុប្បន្ន ពលករម្នាក់ត្រូវចំណាយ ៥០ដុល្លារ រឺ១៥០ដុល្លារ ទៅលើលិខិតឆ្លងដែន អាស្រ័យទៅតាមរយៈពេលដែលអាចចាំបាន ។ នេះជាជំហ៊ានដ៏ល្អមួយសំរាប់ការចែករំលែកបន្ទុកចំណាយ ។ ប៉ុន្តែ ទីភ្នាក់ងារជ្រើសរើសពលករនៅតែត្រូវរ៉ាប់រងចំពោះចំណាយដែលនៅសល់ពីនោះ ។ រួមទាំងប្រាក់ចំណេញ ក្រុមហ៊ុនត្រូវគិតសេវា ៧០០ដុល្លារក្នុងម្នាក់ ចំពោះពលករទៅធ្វើការនៅប្រទេសថៃ ដែលក្នុងនោះ ១០០ដុល្លារ ត្រូវចេញដោយពលករដើម្បីបង្គ្រប់ចំណាយធ្វើលិខិតឆ្លងដែន ។ ចំពោះពលករទៅប្រទេសម៉ាឡេស៊ី ក្នុងម្នាក់ត្រូវសងចំណាយវិញពី ៨០០-៩០០ដុល្លារ ។ ក្រុមហ៊ុនត្រូវកាត់យកកំរៃសេវានេះពីប្រាក់ខែរបស់ពលករ ។ នៅប្រទេសថៃ និយោជកមួយចំនួនបានបង់ប្រាក់ ២០.០០០បាត អោយមុនមកក្រុមហ៊ុនបញ្ជូនពលករខ្មែរ ដើម្បីចំណាយគ្រប់ប្រភេទ សំរាប់ពលករម្នាក់ដែលត្រូវបញ្ជូនទៅឱ្យពួកគេ ។ និយោជកមួយចំនួនចំណាយ ១០.០០០បាតមុន និង១០.០០០ក្រោយពេលពលករទៅដល់ ។ នៅពេលដែលទីភ្នាក់ងារឯកជន ត្រូវបានអនុញ្ញាតអោយបញ្ជូនពលករទៅប្រទេសកូរ៉េ កំរៃសេវាគិតចំពោះពលករម្នាក់ គឺ ១៥០០-៣០០០ដុល្លារ ។ ចាប់តាំងពីដើមឆ្នាំ ២០០៧ មក ក្រុមហ៊ុនឯកជនទាំងនោះ មិនត្រូវបានអនុញ្ញាតអោយបញ្ជូនពលករទៅប្រទេសកូរ៉េខាងត្បូងទៀតទេ ។ មានតែរដ្ឋាភិបាលប៉ុណ្ណោះដែលកំពុងធ្វើការនេះ ហើយគិតកំរៃសេវាត្រឹមតែ៩០០ដុល្លារប៉ុណ្ណោះក្នុងពលករម្នាក់ ដែលនេះគឺជាការកាត់បន្ថយចំណាយដ៏ធំមួយសំរាប់ពលករ និងជាជោគជ័យនៃសេវារបស់រដ្ឋក្នុងប្រព័ន្ធថ្មីរវាងរដ្ឋនិងរដ្ឋ។ គេគួររកវិធីយ៉ាងណាដើម្បីកាត់បន្ថយចំណាយក្នុងការបញ្ជូនពលករទៅប្រទេសថៃ ។

## បញ្ហាសំខាន់ៗ ជាគន្លឹះនៅក្នុងការផ្តល់សេវារដ្ឋបាលដល់ចំណាកស្រុកពលករ

*តំលៃដំណើរការបញ្ជូនពលករទៅបរទេស*

ក្រោយពីប្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអ្នកចាត់ចែងបណ្តុះបណ្តាល និងបញ្ជូនពលករដោយផ្ទាល់ទៅប្រទេសកូរ៉េ តំលៃចំណាយធ្លាក់មកនៅត្រឹម ប្រហែល ៩០០ដុល្លារប៉ុណ្ណោះក្នុងមួយនាក់ ដោយគិតទាំងចំណាយលើសំបុត្រយន្តហោះ ៤២០ដុល្លារ និងលើលិខិតឆ្លងដែនតែ ៥០ដុល្លារប៉ុណ្ណោះ ។ នេះជាការជឿនលឿនមួយបើធៀបនឹងការណ៍ដែលក្រុមហ៊ុនកំណត់យកពី ១៥០០ ទៅ ៣០០០ដុល្លារក្នុងមួយនាក់កាលពីមុនឆ្នាំ២០០៧ ។

ដោយឡែកនៅតែមានចំណាយខ្ពស់ដល់ទៅ ៧០០ដុល្លារ សំរាប់ពលករមួយនាក់ ទៅធ្វើការនៅប្រទេសថៃដោយស្របច្បាប់ ។ចំណាយនេះមានកំរិតខ្ពស់ណាស់បើធៀបនឹងចំណាយត្រឹម ១០០ដុល្លារ ដែលពលករភាគច្រើនបង់ឱ្យមេខ្យល់ ដើម្បីទៅដល់កន្លែងធ្វើការក្នុងប្រទេសថៃ ។ ដើម្បីឱ្យពលករភាគច្រើនបង្វែរមករកផ្លូវចេញចូលប្រទេសថៃដោយស្របច្បាប់តំលៃ ៧០០ដុល្លារនេះ គួរបញ្ចុះឱ្យបានច្រើន ។ តាមការសិក្សានេះ រដ្ឋាភិបាលថៃ និងរដ្ឋាភិបាលកម្ពុជាអាចរួមចំណែកធ្វើឱ្យថ្លៃនេះចុះមកនៅត្រឹមតែ ៣០០ដុល្លារប៉ុណ្ណោះ ។នៅក្នុង ៧០០ដុល្លារ បច្ចុប្បន្នភាគីខាងថៃបច្ចុប្បន្នទទួលបានប្រហែល ២២០ដុល្លារ ដោយរួមមាន ៥៩ដុល្លារសំរាប់ទិដ្ឋាការ នៅស្ថានទូតថៃ និង ១០៦ដុល្លារសំរាប់លិខិតអនុញ្ញាតឱ្យធ្វើការ (Work Permit) ចេញដោយក្រសួងការងារថៃ និងសោហ៊ុយធ្វើដំណើរ និងពិនិត្យសុខភាព ។ រដ្ឋាភិបាលថៃអាចចូលរួមបន្ថយកំរៃ ពី២២០ដុល្លារ មកត្រឹម ១០០ដុល្លារបាន ដោយយកថ្លៃទិដ្ឋការត្រឹមតែ ៥០០បាត រឺត្រូវជាប្រហែល ១៥ដុល្លារ និងថ្លៃលិខិតអនុញ្ញាត ឱ្យធ្វើការត្រឹមតែ ១០០០បាត រឺ ៣០ដុល្លារ ដោយរក្សាទុកថ្លៃពិនិត្យសុខភាព និងសោហ៊ុយធ្វើដំណើរនៅដដែល ។

នៅក្នុងកំរៃសរុប ៧០០ដុល្លារនេះ ៤៨០ដុល្លារចំណាយនៅលើទឹកដីកម្ពុជា ដោយរួមទាំងថ្លៃ ១៥០ដុល្លារសំរាប់លិខិតឆ្លងដែន និងប្រាក់ចំណូលរបស់ក្រុមហ៊ុនរើសពលករប្រហែល ៧០ដុល្លារក្នុងមួយនាក់ ។ រាជរដ្ឋាភិបាលកម្ពុជាអាចចូលរួមកាត់បន្ថយតំលៃពី៤៨០ដុល្លារនេះឱ្យមកនៅត្រឹម២០០ដុល្លារបាន ដោយរក្សាប្រាក់ចំណូល ៧០ដុល្លារសំរាប់ក្រុមហ៊ុនដដែល ។ ដើម្បីធ្វើដូចនេះបាន ថ្លៃលិខិតឆ្លងដែនគួរនៅត្រឹម ៥០ដុល្លារ ក្នុងរយៈពេល១ឬ២សប្តាហ៍ និងការចំណាយផ្សេងៗអាចបន្ថយពី២២០ដុល្លារ មកនៅត្រឹម៤០ដុល្លារ ។ប្រសិនបើធ្វើតំលៃសរុបធ្លាក់មកនៅ ត្រឹម៣០០ដុល្លារក្នុងម្នាក់បាន បញ្ហាមួយចំនួនធំ នឹងត្រូវបានដោះស្រាយ ។ ក៏ប៉ុន្តែ ចំណុចចំបងមួយគឺ ទាក់ទងនឹងលិខិតឆ្លងដែន ។

*លិខិតឆ្លងដែន*

នៅពេលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុម័តឱ្យពលករទៅធ្វើការនៅក្រៅប្រទេស ទីភ្នាក់ងារជ្រើសរើសពលករ រឺពលករផ្ទាល់ត្រូវរៀបចំសំណុំបែបបទធ្វើលិខិតឆ្លងដែនជាមុនសិន បន្ទាប់មកទើបអាចស្នើសុំសិទ្ធិធ្វើការពីក្រសួងការងារថៃ និងសុំទិដ្ឋាការពីស្ថានទូតថៃ ។ លិខិតឆ្លងដែន មាន "តំលៃផ្លូវការ" ត្រឹមតែ ២០ដុល្លារ សំរាប់ពលករចំណាកស្រុក ដោយសារត្រូវបានសម្បទានពីរដ្ឋាភិបាល ប៉ុន្តែក្រោយមកនៅឆ្នាំ២០០៧ ត្រូវតំលើង ២០ដុល្លារទៀតសំរាប់បន្ថែមទិន្នន័យអេឡិសត្រូនិក ។ ប៉ុន្តែ តំលៃជាក់ស្តែងគឺ ៥០ដុល្លារ ក្នុងករណីមិនបន្ទាន់ និងត្រូវចំណាយពេលប្រហែលលើស២ខែ រឺចំនួន ១៥០-១៨០ដុល្លារ សំរាប់រយៈពេលមួយសប្តាហ៍ ។នៅប្រទេសថៃ គេយកថ្លៃតែ ៣០ដុល្លារប៉ុណ្ណោះសំរាប់រយៈពេល ៣ ទៅ ៥ថ្ងៃ ហើយមានការិយាល័យច្រើនដែលទទួលធ្វើលិខិតឆ្លងដែន ។

ភ្នាក់ងារជ្រើសរើសពលករ បានត្អូញត្អែរអំពីតំលៃ និងការចំណាយពេលយូរក្នុងការធ្វើលិខិតឆ្លងដែន ។ ពួកគេនិយាយថា ប្រសិនបើចង់កែលំអសេវារដ្ឋបាល គេគួរតែធ្វើលិខិតឆ្លងដែនឱ្យបានឆាប់ជាងនេះ ពីព្រោះពលករភាគច្រើនមិនអាចរង់ចាំយូរបានទេ ដោយសារពួកគេរកកំរៃបានតែមួយគ្រប់៧ប៉ុណ្ណោះពីមួយថ្ងៃទៅមួយថ្ងៃ ហើយមិនអាចចំណាយពេលច្រើនខែដើម្បីរង់ចាំការងារនៅបរទេសបានទេ ។ ពលករត្រូវចំណាយពេល ១ខែទៀត ដើម្បីទទួលបានទិដ្ឋាការពីថៃ ដែលស្ថានទូតទទួលពាក្យសុំតែ ២ថ្ងៃប៉ុណ្ណោះក្នុងមួយសប្តាហ៍ ។ រួមផ្សំនឹងការចំណាយពេលផ្សេងៗទៀត ដំណើរការទាំងមូល ត្រូវចំណាយពេលប្រហែល ៦ខែ ដែលវាជារយៈពេលយូរពេកសំរាប់ពលករ ជាពិសេសអ្នកដែលត្រូវការចំណូលភ្លាមៗជាចាំបាច់នោះ ។

កន្លែងផ្តល់លិខិតឆ្លងដែន មានតែមួយគត់ក្នុងប្រទេសកម្ពុជា ។ ការិយាល័យនោះមានទីតាំងតូចចង្អៀតតាំងពីយូរមកហើយ ។ បើគិតពីតំលៃដ៏ខ្ពស់របស់លិខិតឆ្លងដែន មិនគួរមានកង្វះខាតនូវកន្លែងសំរួលការ និងសំភារៈ ដើម្បីដំណើរការធ្វើវាឡើយ ។ ប្រាក់ចំណូលបានមកពីការធ្វើលិខិតឆ្លងដែនច្បាស់ជាគ្រប់គ្រាន់ សំរាប់ទិញសំភារៈចាំបាច់ និងសំរាប់ជួលបុគ្គលិកឱ្យបានច្រើន សមល្មមនឹងតំរូវការដ៏ច្រើននាពេលបច្ចុប្បន្ន ។ នៅពេលមានប្រជាពលរដ្ឋកាន់តែច្រើនមកស្នើសុំធ្វើលិខិតឆ្លងដែន ការិយាល័យនឹងទទួលបានចំណូលបន្ថែមទៀតសំរាប់ផ្គត់ផ្គង់ ដល់ប្រព័ន្ធការងារ ។

ប្រសិនបើពលករទាំង ២០០.០០០នាក់ ត្រូវមានលិខិតឆ្លងដែនទាំងអស់គ្នា ហើយគិតយកថ្លៃលិខិតឆ្លងដែនមួយត្រឹមតែ ៥០ដុល្លារ នោះតំលៃសរុបត្រូវជា ១០លានដុល្លារ ។ ប៉ុន្តែ ការិយាល័យដ៏តូចមួយនៅភ្នំពេញ មិនអាចមានកំលាំងគ្រប់គ្រាន់បំពេញការងារច្រើនបែបនេះឡើយ ។ដូច្នេះ ក្រសួងមហាផ្ទៃ គួរបង្កើតការិយាល័យ បន្ថែមមួយឬពីរទៀត នៅភ្នំពេញ ដើម្បីឱ្យការងារមានប្រសិទ្ធភាពជាងនេះ និងរកចំណូលបានច្រើនជាងនេះ ។ សំខាន់ជាងនេះទៀត ក្រសួងមហាផ្ទៃគួរតែបង្កើតការិយាល័យធ្វើលិខិតឆ្លងដែននៅតាមបណ្តាខេត្តសំខាន់ៗ និងបណ្តុះបណ្តាលឱ្យមន្ត្រីមានសមត្ថភាពអនុវត្តការងារ ។ បើពិតជាអាចធ្វើដូច្នោះមែន វាមិនត្រឹមតែអាចបំពេញ តំរូវការដ៏ច្រើនលើសលប់របស់ប្រជាពលរដ្ឋបានទេ ប៉ុន្តែ វាថែមទាំងអាចជួយកាត់បន្ថយចំណាយធ្វើដំណើរសំរាប់ប្រជាពលរដ្ឋនៅតាមបណ្តាខេត្តបានទៀតផង ។ ឧទាហរណ៍ ខេត្តបន្ទាយមានជ័យ គួរមានការិយាល័យសំរាប់ទទួលពាក្យស្នើសុំ និងធ្វើលិខិតឆ្លងដែន ដោយមានពលករច្រើនដែលត្រូវការលិខិតឆ្លងដែន ។ ការងារនេះអាចដំណើរការកាន់តែរហ័សជាងនេះ ប្រសិនបើអភិបាលខេត្ត ត្រូវបានផ្តល់សិទ្ធិឱ្យចុះហត្ថលេខាលើលិខិតឆ្លងដែន ។ ប៉ុន្តែទោះបីជាមានតែអគ្គនាយកប៉ូលីសជាតិទើបអាចចុះហត្ថលេខាបានក៏ដោយ ក៏គួរមានការិយាល័យនៅតាមខេត្តសំរាប់ទទួលពាក្យស្នើសុំ និងបញ្ជូនឯកសារទាំងនោះមកធ្វើលិខិតឆ្លងដែននៅភ្នំពេញ ។

*បញ្ហារត់ចោលការងារនៅពេលធ្វើការនៅប្រទេសថៃ*

ការទាមទារឱ្យទីភ្នាក់ងារជ្រើសរើសពលករទទួលខុសត្រូវលើចំណាយបញ្ជូនពលករ គឺជាបញ្ហាមួយ ។ ទីភ្នាក់ងារនឹងខាតបង់ប្រសិនបើពលករគេចចេញពីការងារ ។ យោងតាមទីភ្នាក់ងារជ្រើសរើសពលករ ការរត់ចោលការងារ មានអត្រាខ្ពស់គួរសម ជាពិសេសនៅថៃ ។ រឿងនេះអាចយល់បាន ដោយសារមានពលករតែ ៦១១៤នាក់ប៉ុណ្ណោះ ត្រូវបានបញ្ជូន ទៅដោយស្របច្បាប់ ហើយមានពលករជាង ១០០.០០០នាក់ កំពុងធ្វើការនៅថៃដោយខុសច្បាប់ ។ ពលករស្របច្បាប់ ទំនងជាចង់រត់គេចពីបំណុល និងចូលរួមជាមួយពលករគ្មានឯកសារបញ្ជាក់ ។ រឿងនេះ មិនមែន

មានតែនៅថៃទេ ។ Dang (2007) រាយការណ៍ថា អត្រារត់ចោលការងាររបស់ពលករវៀតណាមនៅជប៉ុន គឺ ២៧-៣០% នៅកូរ៉េខាងត្បូង ២០-២៥% ហើយនៅតៃវ៉ាន់ ០៩-១២% ។

បញ្ហាមួយទៀត គឺថាពលករមួយចំនួនយល់ថាការងារនៅថៃលំបាកពេក ដូច្នេះពួកគេត្រូវតែត្រឡប់មកផ្ទះវិញ ទោះជាតាមមធ្យោបាយណាក៏ដោយ ។ បញ្ហានេះ ធ្វើអោយទីភ្នាក់ងារខាតបង់ប្រាក់ ។ វាអាចមកពីទីភ្នាក់ងារមិនបានពន្យល់ពលករទាំងនោះអោយបានគ្រប់គ្រាន់មុនពេលឱ្យពួកគេទទួលការងារ ឬអាចមកពីការងារដែលទីភ្នាក់ងារបានសន្យា និងការងារពិតប្រាកដមិនដូចគ្នា ។ ទីភ្នាក់ងារ ឬក្រុមហ៊ុនជ្រើសរើសពលករ គួរត្រូវបន្ទោសខ្លះដែរ ចំពោះពលកររត់ចោលការងារ ព្រោះពួកគេមិនបានជ្រើសរើសពលករឱ្យបានត្រឹមត្រូវ ។ ទីភ្នាក់ងារមិនបានប្រឹងប្រែងជ្រើសរើសឱ្យល្អទេ ប៉ុន្តែជ្រើសឱ្យតែបានគ្រប់ចំនួនប៉ុណ្ណោះ ។ ពួកគេគួរជ្រើសរើសពលករដែលមានបទពិសោធន៍ស្រាប់ហើយ ដូចជាកម្មករសំណង់នៅកម្ពុជា ដើម្បីទៅធ្វើកម្មករសំណង់នៅប្រទេសផ្សេង ។ មានពលករក្នុងស្រុកច្រើនទៀត ដែលអាចជំនួសពួកគេធ្វើការងារសំណង់នៅប្រទេសកម្ពុជា ។ ក្រុមហ៊ុន រឺភ្នាក់ងារ គួរជៀសវាងបញ្ជូនយុវវ័យដែលចង់ធ្វើចំណាកស្រុកដោយមិនបានរើសសំរាំងអ្វីទាំងអស់ ដើម្បីទទួលបានកំរៃសេវាជ្រើសរើសពលករបានយ៉ាងឆាប់រហ័ស ។

វាមិនមែនជារឿងងាយស្រួលទេសំរាប់ទីភ្នាក់ងារ ក្នុងការដោះស្រាយបញ្ហានៃការរត់ចោលការងាររបស់ពលករ ។ ក្នុងករណីខ្លះ ពួកគេស្នើសុំស្ថានទូតថៃឱ្យរារាំងពលកររត់ចោលការងារ មិនឱ្យទទួលបានទិដ្ឋាការម្តងទៀត ។ ប៉ុន្តែស្ថានភាពនៅតែច្របូកច្របល់ដដែលដោយគ្មានដំណោះស្រាយណាមួយល្អសោះ ។ នៅថៃ មិនដូចជាកូរ៉េខាងត្បូង រឺម៉ាឡេស៊ីទេ ដែលមានពលករចំណាកស្រុកភាគច្រើនស្របច្បាប់ ហើយមិនងាយនឹងត្រឡប់មកផ្ទះវិញស្រួល ដោយគ្មានលិខិតឆ្លងដែន ។ នៅថៃ គឺជាករណីពិសេស ពីព្រោះទីតាំងភូមិសាស្ត្រ និងការត្រួតពិនិត្យព្រំដែន ធូររលុង បានធ្វើឱ្យងាយស្រួលដល់ពលករក្នុងការរត់ចោលការងារ ហើយស្នាក់នៅធ្វើការនៅថៃដោយមិនស្របច្បាប់ រឺរត់ត្រឡប់មកកម្ពុជាវិញដោយងាយ ។

*ជំរើសឱ្យក្រុមហ៊ុនជ្រើសរើសពលករបង់ប្រាក់ជាមុន*

បើសិនជារដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលថៃ ចង់អោយពលករធ្វើចំណាកស្រុកតាមរយៈក្រុមហ៊ុនជ្រើសរើសពលករ ហេតុនេះចំនួនទីភ្នាក់ងារគួរតែមានច្រើនជាងនេះ ។ បច្ចុប្បន្ននេះ ចំណាយភាគច្រើន រឺពាក់កណ្តាល ត្រូវបាននិយោជកថៃជាអ្នកផ្តល់ឱ្យដោយផ្អែកលើលក្ខខ័ណ្ឌថាទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា នឹងរកពលករថ្មី មកជំនួសពលករដែលបានរត់ចេញពីការងារដោយមិនយកប្រាក់កំរៃសេវាឡើយ ។ រឿងនេះ បានធ្វើអោយទីភ្នាក់ងារកម្ពុជា ស្ថិតនៅក្នុងការប្រថុយប្រថានខ្លាំងក្លាបំផុត ។

វាជារឿងអាចយល់បានថា ពលករភាគច្រើនប្រហែលជាគ្មានប្រាក់៧០០ដុល្លារ ដើម្បីទូទាត់ចំណាយជាមុនទេ ។ ប៉ុន្តែ ពលករមួយចំនួនដែលធ្លាប់ធ្វើការនៅថៃដោយខុសច្បាប់ មានប្រាក់បង់ឱ្យក្លាយជាស្របច្បាប់វិញ ។ ក្រៅពីនេះ គេអាចដោះស្រាយបានដោយការស្វែងរកមធ្យោបាយសំរាប់ពលករដែលមានការតស៊ូពិតប្រាកដ ដើម្បីទទួលបានប្រាក់កំចីពិសេសដែលមាន រឺគ្មានការប្រាក់ ។ ប្រាក់កំចីពិសេសអាចខ្ចីបានតាមរយៈធនាគារ ស្ថាប័នមីក្រូហិរញ្ញវត្ថុ កម្មវិធីឥណទានរបស់អង្គការមិនមែនរដ្ឋាភិបាល រឺតំរោងសន្សំប្រាក់របស់សហគមន៍ ។ ពលករដែលត្រូវការរកប្រាក់ចំណេញឱ្យបានច្រើនពីការធ្វើការនៅក្រៅស្រុក នឹងត្រូវចំណាយប្រាក់ រឺខ្ចីប្រាក់គេដើម្បីបង់អោយទីភ្នាក់ងារជ្រើសរើសពលករ ។

ប្រាក់កំចី នឹងត្រូវបានធានាដោយអាជ្ញាធរមូលដ្ឋានដែលស្គាល់ពលករនោះច្បាស់ រឺការរៀបចំផ្សេងៗដែលអាចធានាការសងប្រាក់ត្រឡប់មកវិញបាន ។

*ការអនុវត្តន៏ MOU រវាងកម្ពុជា និងថៃ*

ជាផ្នែកមួយនៃការអនុវត្តន៏ MOU រវាងថៃ និងកម្ពុជា រដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការអន្តរក្រសួងមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងការបរទេស ដើម្បីផ្តល់លិខិតបញ្ជាក់អត្តសញ្ញាណដល់ពលករកម្ពុជាដែលកំពុងធ្វើការក្នុងប្រទេសថៃដោយមិនស្របច្បាប់ ។ ក្រុមការងារថៃដែលមានសមត្ថកិច្ចប្រហាក់ប្រហែលមានសមាជិកមកពីក្រសួងការងារ (ក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាលថៃ) ជាអ្នកផ្តល់លិខិតអនុញ្ញាតឱ្យធ្វើការ ។ ពលករចំណាកស្រុកត្រូវចំណាយ ១៥០០បាត ទៅឱ្យគណៈកម្មាធិការកម្ពុជា ហើយ ៤០០០បាត ទៅឱ្យគណៈកម្មាធិការថៃ សំរាប់លិខិតអនុញ្ញាតការងារ ដែលទាមទារឱ្យមានការពិនិត្យសុខភាព ដើម្បីដាក់បញ្ចូលទៅក្នុងការធានាសុខភាព ។ តំលៃសរុបនៃការបញ្ជូនពលករម្នាក់ តាមរយៈប្រព័ន្ធ MOU នៅកម្ពុជា គឺ ៧០០ដុល្លារ ដូចរៀបរាប់លំអិតខាងលើ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅកម្ពុជា ជឿថា ក្នុងអំឡុងពេល៥ឆ្នាំកន្លងមកនេះ MOU បាននិងកំពុងជួយពលករកម្ពុជាដែលធ្វើការនៅថៃឱ្យទទួលបាននូវការទទួលស្គាល់ និងការចាត់ចែងមានយុត្តិធម៌ ។ យោងតាមមន្ត្រីកម្ពុជា ក្រុមការងារមានសមត្ថកិច្ច ដែលកំពុងធ្វើការងារសំរាប់ក្រសួងការងារនៅកម្ពុជា និងថៃ បានសហការគ្នាយ៉ាងល្អ ។ កិច្ចប្រជុំរវាងក្រសួងការងារកម្ពុជា និងថៃ នៅសៀមរាប នាខែវិច្ឆិកា ឆ្នាំ២០០៧ បានសំរេចនូវកិច្ចព្រមព្រៀងមួយថា គណៈកម្មាធិការអន្តរក្រសួង ទទួលបន្ទុកផ្តល់លិខិតបញ្ជាក់អត្តសញ្ញាណដល់ពលករកម្ពុជា ដែលធ្វើការនៅថៃ អាចបន្តគំរោងនេះ រហូតដល់ចុងខែមិថុនា ឆ្នាំ២០០៨ ។ មានសេចក្តីប្រកាសអំពីការបង្កើតគណៈកម្មាធិការមួយនៅកម្ពុជាសំរាប់ទទួលពលករមិនស្របច្បាប់ដែលត្រូវគេបញ្ជូនមកវិញ នៅពេលលិខិតអនុញ្ញាតឱ្យស្នាក់នៅ និងធ្វើការនៅថៃបានផុតកំណត់ ។ កិច្ចប្រជុំ ក៏បានសំរេចថា គួរមាន MOU ថ្មីសំរាប់ដោះស្រាយបញ្ហាពលករចូលទៅធ្វើចំការនៅដីថៃនៅជិតព្រំដែន ។

ជាទូទៅ គួរមានគ្រឿងលើកទឹកចិត្តចំពោះនិយោជកថៃណាដែលសហការ និងការដាក់ពិន័យចំពោះនិយោជកណាមិនសហការ ។ អ្នកឆ្លើយសំភាសន៏មួយចំនួនជឿថា និយោជកជនជាតិថៃ ពេញចិត្តជួលពលករដែលគ្មានឯកសារបញ្ជាក់ជាង ពីព្រោះពួកគេទទួលបានប្រយោជន៏ ។ ពួកគេអាចធ្វើបាបពលករទាំងនេះតាមចិត្តចង់ ។ បើរឿងនេះជាការពិត និយោជកថៃ គួរត្រូវបានផ្តល់គ្រឿងលើកទឹកចិត្ត ដើម្បីឱ្យពួកគេផ្តល់ដំណឹងដល់ពលករខុសច្បាប់របស់ខ្លួនទៅចុះឈ្មោះ រឺក៏ត្រូវទទួលពិន័យ ប្រសិនបើពួកគេមិនសហការក្នុងរឿងនេះទេ ។

## សន្និដ្ឋានអនុសាសន៍

ចំណាយសំរាប់ពលករចំណាកស្រុកទៅថៃដោយស្របច្បាប់ គួរត្រូវកាត់បន្ថយពី ៧០០ដុល្លារ មកនៅត្រឹម ៣០០ដុល្លារ ដោយមានការចូលរួមពីរដ្ឋាភិបាលថៃ និងរដ្ឋាភិបាលកម្ពុជា ។ ក្រៅពីនេះ រដ្ឋាភិបាលកម្ពុជា គួរមានវិធានការណ៏មួយចំនួនទៀតដើម្បីអភិវឌ្ឍន៏វិស័យទេសន្តប្រវេស ដូចជា ១) ការរៀបចំខាងស្ថាប័ន គួរមានការកែលំអ ២) ក្រសួងការងារ

និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ គួរមាននាយកដ្ឋានមួយសំរាប់ទទួលខុសត្រូវផ្ទាល់ ទៅលើចំណាកស្រុកពលករ ហើយគួរបន្ថែមបុគ្គលិកមានសមត្ថភាពឱ្យបានច្រើន សំរាប់ដោះស្រាយបញ្ហាចំណាកស្រុក ៣) គោលនយោបាយចំណាកស្រុក និងក្របខណ្ឌច្បាប់សមស្រប ដូចជា ច្បាប់អន្តោប្រវេសន៏គួរត្រូវបានពិនិត្យកែតំរូវ ៤) តំលៃលិខិតឆ្លងដែន គួរកាត់បន្ថយមកត្រឹម ៥0ដុល្លារក្នុងរយៈពេល ១ទៅ២សប្ដាហ៏ និង ៥) ក្រសួងមហាផ្ទៃគួរបង្កើតការិយាល័យបន្ថែមទៀតសំរាប់ទទួលខុសត្រូវធ្វើលិខិតឆ្លងដែន ដោយមានទីតាំងនៅភ្នំពេញ និងនៅតាមខេត្តសំខាន់ៗ ដូចជា បាត់ដំបង សៀមរាប បន្ទាយមានជ័យ និងព្រៃវែង ។

អនុក្រឹត្យលេខ ៥៧ គួរមានការពិនិត្យកែតំរូវឡើងវិញឱ្យសមស្របនឹងការអភិវឌ្ឍថ្មី ។ ចំនួនក្រុមហ៊ុន និង ការិយាល័យជ្រើសរើសពលករ គួរមានបន្ថែមទៀតនៅតាមបណ្ដាខេត្តដែលពលករធ្វើចំណាកស្រុកទៅថៃមានចំនួនច្រើន ។ ប្រាក់តម្កល់សំរាប់បើកទីភ្នាក់ងារជ្រើសរើសពលករ គួរមានការកាត់បន្ថយ ដើម្បីបង្កើនចំនួនទីភ្នាក់ងារប្រភេទនេះ ។ ទីភ្នាក់ងារទាំងនោះ គួរជ្រើសរើសពលករដោយប្រុងប្រយ័ត្ន ដើម្បីជៀសវាងមានពលករច្រើនរត់ចោលការងារ ។ ទន្ទឹមនឹងនេះ គួរមានការអនុញ្ញាតឱ្យទីភ្នាក់ងារ គិតកំរៃសេវាចំពោះពលករដែលចង់ទៅធ្វើការនៅថៃ ពីព្រោះបើធ្វើបែបនេះ វាអាចជួយកាត់បន្ថយចំនួនពលកររត់ចោលការងារបាន ។

ប្រទេសថៃជាអ្នកទទួលប្រយោជន៏ពីពលករចំណាកស្រុក ហេតុនេះរដ្ឋាភិបាលថៃគួរជួយឱ្យពលករទាំងនោះមាន លក្ខណៈផ្លូវការ ។ រដ្ឋាភិបាលថៃ គួរចូលរួមចំណែកកាត់បន្ថយចំណាយរត់ការផ្សេងៗ (សំរាប់លិខិតអនុញ្ញាតការងារនិងទិដ្ឋាការ) និងគួរចាត់វិធានការបញ្ឈប់ការជួលពលករមិនស្របច្បាប់ ។ គ្រឿងលើកទឹកចិត្ត គួរផ្ដល់ឱ្យនិយោជក ដែលជួលពលករស្របច្បាប់ រីឯអ្នកដែលជួលពលករមិនស្របច្បាប់ គួរទទួលការពិន័យ ។ ចំពោះពលករកំពុងធ្វើការនៅថៃ គួរមានវិធីជួយពួកគេឱ្យមានសិទ្ធិធ្វើការនៅទីនោះដោយស្របច្បាប់ ដោយមិនចាំបាច់ឱ្យពួកគេមកធ្វើលិខិតឆ្លងដែន និងសុំទិដ្ឋាការនៅភ្នំពេញទេ ប្រសិនបើចំណាយបញ្ជូនពលករស្របច្បាប់នៅតែខ្ពស់ដដែល ។

*សូមមើលឯកសារយោងក្នុងអត្ថបទជាភាសាអង់គ្លេស*

# បញ្ជីឯកសារបោះពុម្ពផ្សាយរបស់ CDRI


១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជាៈ ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សាលេខ ១) ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិលៈ ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ។

៣. Kannan, K. P. (មករា ១៩៩៧) *កំណែទំរង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធនិងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ។

៤. ជីម-ចិរិយា ស្រ៊ុន-ពិចូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៊ុន-ដូរីណា និងរ៉ូប៊ីន-ប៊ីដឹលវី (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាខ្មែរថ្លៃ ៩.០០០រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និងឡុង-វ៉ូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.០០០រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨) *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ីៈ បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato ឡុង-វ៉ូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជាៈ បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តំលៃ ៦.០០០រៀល ។

៩. តេង-យូគី ប៊ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនឌ្រូ (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១០. Gorman, Siobhan, ជាមួយ ប៊ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជាៈ ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ១០) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃៈ ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វ៉ូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គីមហួន និង ជា-វុធណា (តុលា ១៩៩៨) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍ៈ ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២000) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.000រៀល ។

១៤. Toshiyasu-Kato Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២000) *ប្រទេសកម្ពុជា: លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.000រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២000) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរតំលៃ ១0.000រៀល ។

១៦. ស៊ិក បូរ័ក្ស (ធ្នូ ២000) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា: ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរថ្លៃ ៨.000រៀល ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២00១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.000រៀល ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សារ៉ាវី ប៊ុន-ដូរីណា Claude-Katz Sarthi-Acharya ស៊ីសុវត្ថិ-ឌួង-ចាន់តូ និងហ៊ីង ថូរ៉ាក់ស៊ី (តុលា២00១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា: ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតំរូវចំពោះវិបត្តិ* (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

១៩. ច័ន្ទ-សុផល ទេព-សារ៉ាវី និង Sarthi Acharya (ធ្នូ២00១) *ការកាន់កាប់ដីនៅកម្ពុជា: ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

២0. សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្នមុនី, Brett Ballard និង Sarthi Acharya (មីនា ២00២) *ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២0) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

២១. Bhargavi Ramamurthy ស៊ិក-បូរ័ក្ស, Per Ronnås និងសុក-ហាច (មីនា២00២) *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២000: ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ* (ឯកសារពិភាក្សាលេខ ២១) តំលៃ ៨.000រៀល ។

២២. ច័ន្ទ-សុផល និង Sarthi Acharya (កក្កដា២00២) *ការលក់ដូរដីធ្លីនៅកម្ពុជា: ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តំលៃ ៨.000រៀល ។

២៣. Bruce McKenney និង ព្រុំ-តុលា (កញ្ញា ២00២) *ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា: ការវាយតំលៃជាមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៣) ជាភាសាខ្មែរ តំលៃ ១0.000រៀល ជាអង់គ្លេស ១0ដុល្លារ ។

២៤. ច័ន្ទ-សុផល គីម-សេតារា និង Sarthi Acharya ( ធ្នូ ២០០២) *ជីផ្ទី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា: ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរតំលៃ ៦.០០០រៀល ជាអង់គ្លេសតំលៃ ៧ដុល្លារ ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya ( ធ្នូ ២០០២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទ: ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា* ( ឯកសារពិភាក្សា លេខ២៥) ជាខ្មែរតំលៃ ៨.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៦. Sarthi Acharya គីម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី ( កញ្ញា ២០០៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម: ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ២៦) ជាខ្មែរ ៧.០០០រៀល អង់គ្លេស ៥ដុល្លារ ។

២៧. យឹម-ជា និង Bruce McKenney ( ធ្នូ ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ: ការវិភាគលើ ការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសំរាប់ការលួចលាស់* ( ឯកសារពិភាក្សាលេខ២៧) ជាខ្មែរតំលៃ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៨. ព្រុំ-តុលា និង Bruce McKenney ( ធ្នូ ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា: ការប្រឈម ការគំរាមកំហែង និងឱកាសសំរាប់ពាណិជ្ជកម្មជ័រទឹក* ( ឯកសារពិភាក្សាលេខ២៨) ជាខ្មែរ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៩. យឹម-ជា និង Bruce McKenney ( វិច្ឆិកា ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក: ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ* (ឯកសារពិភាក្សាលេខ២៩) ជាខ្មែរ ៥.០០០រៀល ជាអង់គ្លេស ៥ដុល្លារ ។

៣០. Caroline Hughes និង គីម-សេតារា ( មិថុនា ២០០៤) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា: ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣០) ជាភាសាខ្មែរ ១០.០០០រៀល ជាភាសាអង់គ្លេស ១៣,៥០ដុល្លារ ។

៣១. Robert Oberndorf ( កក្កដា ២០០៤) *សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា* ( ឯកសារពិភាក្សាលេខ៣១) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៦,៥០ដុល្លារ ។

៣២. K.A.S. Murshid និង ទូត-សុខផល្លី (ឧសភា ២០០៥) *សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ប្រទេសកម្ពុជា: ការសិក្សាជំហានដំបូង* ( ឯកសារពិភាក្សាលេខ៣២) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ ។

៣៣. Kasper K. Hansen និង តុប-នេត ( ធ្នូ ២០០៦) ***Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia*** (ឯកសារពិភាក្សាលេខ៣៣) ជាភាសាអង់គ្លេស ៨,០០ដុល្លារ ។

៣៤. ប៉ក់-គីមជឿន ហ៊ុង-វុទ្ធី អេង-នេត្រា អាន-សុវត្ថា គីម-សេតារា, Jenny Knowles និង David Craig ( មីនា ២០០៧) ***Accountability and Neo-patrimonialism in Cambodia: A Critical Literature Review*** ( ឯកសារពិភាក្សាលេខ៣៤) ជាភាសាអង់គ្លេស ៦ដុល្លារ ។

៣៥. គីម-សេតារា និង Joakim Öjendal (ឧសភា ២០០៧) *Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia* (ឯកសារពិភាក្សាលេខ៣៥) ជាភាសាអង់គ្លេស ៤ដុល្លារ ។

៣៦. លឹម-សុវណ្ណារា (វិច្ឆិកា ២០០៧) *Youth Migration and Urbanisation in Cambodia* (ឯកសារពិភាក្សាលេខ៣៦) ជាភាសាអង់គ្លេស ៣,៥ដុល្លារ ។

៣៧. Brett M. Ballard, Christian Sloth, David Wharton, Ingrid FitzGerald, K.A.S Murshid, Kasper K. Hansen, ភីម-រុនស៊ីណារិទ្ធិ និង លឹម-សុវណ្ណារា (មេសា ២០០៧) *"We Are Living with Worry All the Time": A Participatory Poverty Assessment of the Tonle Sap (PPA)* ជាភាសាអង់គ្លេស ១៨ដុល្លារ ។

៣៨. Ingrid FITZGERALD និង សូ-សុវណ្ណារិទ្ធិ (កញ្ញា ២០០៧) *Moving Out of Poverty: Trends in Community Well-Being and Household Mobility in Nine Cambodian Villages (MOPs)* ជាភាសាអង់គ្លេស ២០ដុល្លារ ។

៣៩. CDRI (ធ្នូ ២០០៧) *Cambodia Land Titling Rural Baseline Survey Report* ជាភាសាអង់គ្លេស ៧ដុល្លារ ។

៤០. CDRI (ធ្នូ ២០០៧) *Cambodia Land Titling Urban Baseline Survey Report* ជាភាសាអង់គ្លេស ៧ដុល្លារ ។

៤១. នូ-កែវសុទ្ធា ភីម-រុនស៊ីណារិទ្ធិ និងទួត-សុខផល្លី (ជិតចេញផ្សាយ) *Reviewing Poverty Impact of Regional Economic Integration in the Greater Mekong Sub-Region (RETA)* ជាភាសាអង់គ្លេស ។

តំលៃ ៨.០០០រៀល

9789995052164





វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ផ្ទះលេខ ៥៦ ផ្លូវលេខ ៣១៥ ភ្នំពេញ កម្ពុជា

ប្រអប់សំបុត្រ ៦២២ ភ្នំពេញ កម្ពុជា

(៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ / ០១២ ៨៦៧-២៧៨

(៨៥៥-២៣) ៨៨០-៧៣៤

E-mail: cdrimail@online.com.kh

Website: http://www.cdri.org.kh